**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Science Economiques**

**Royal University of Law and Economics**


**សារណាបញ្ចប់ការសិក្សា**

# នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ ក្នុងរឿងក្តីរដ្ឋប្បវេណីនៅតុលាការកំពូល

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **យាន ស្រីលាប**

កញ្ញា **សាំង សេងហួត**

ណែនាំដោយ

លោកគ្រូ **ហេង ម៉ូរ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Science Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ ក្នុងរឿងក្តីរដ្ឋប្បវេណីទៅតុលាការកំពូល

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **យាន ស្រីលាប**

កញ្ញា **សាំង សេងហួត**

ណែនាំដោយ

លោកគ្រូ **ហេង ម៉ូរ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **សាំង សេងហួត** និងនាងខ្ញុំឈ្មោះ **យាន ស្រីលាប** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២៤ ។

នាងខ្ញុំទាំងពីររូបមានក្តីសោមនស្សយ៉ាងកក់ក្តៅ ដោយមានឱកាសថ្លែងអំណរគុណដល់ លោកឪពុក **ស វៃ** និងអ្នកម្តាយ **ស៊ិន ចាន់ធូ** និងលោកឪពុក **ស៊ិន ផា** និងអ្នកម្តាយ **ឈុំ សាមាន** ដែលលោកជាអ្នកមានគុណយ៉ាងលើសលប់បំផុត គ្មានថ្ងៃណាកូនអាចបំភ្លេចបាន។

ដែលលោកទាំងពីរបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ព្រមទាំងបានផ្តល់នូវការស្រលាញ់មើលថៃយ៉ាងយកចិត្តទុកដាក់អស់ពីដួងចិត្តរបស់លោកទាំងពីរតាំងយើងខ្ញុំទាំងពីរ បានចាប់កំណើតរហូតមកបច្ចុប្បន្ន ដោយលោកបានផ្តល់ថវិកា និងពេលវេលាព្រមទាំងឱកាសឱ្យខ្ញុំបានសិក្សាតាំងពីថ្នាក់មត្តេយ្យ បឋមសិក្សា វិទ្យាល័យ រហូតមកដល់ថ្នាក់បរិញ្ញាបត្រ។ យើងខ្ញុំអាចឈានមកដល់ពេលសព្វថ្ងៃនេះ ដោយសារមានលោកទាំងពីរអប់រំទូន្មាន ប្រៀនប្រដៅណែនាំបង្ហាត់បង្រៀនចរិតលក្ខណៈឱ្យយើងខ្ញុំក្លាយជា កូនល្អ សិស្សល្អ ពលរដ្ឋល្អ នៅក្នុងសង្គម។

យើងខ្ញុំក៏សូមថ្លែងអំណរគុណទៅកាន់លោកឯកឧត្តមបណ្ឌិត **លុយ ចន្ណា** ជាសាកលវិទ្យាធិការ និងព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលលោកគ្រូ អ្នកគ្រូតែងតែជួយចែករំលែកចំណេះដឹងមកកាន់ យើងខ្ញុំទាំងពីរ តាំងពីថ្នាក់មូលដ្ឋានរហូតដល់ឆ្នាំទី៤ ផ្នែកនីតិសាស្ត្រនេះ យើងខ្ញុំនឹងចង់ចាំ និងដឹងគុណដ៏មានតម្លៃមួយនេះជានិរន្តរ៍។

សូមថ្លែងអំណរគុណលោកគ្រូ **ហេង ម៉ូរ៉ា** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការធ្វើឱ្យមានសារណាមួយនេះឡើងប្រកបដោយលទ្ធផលល្អ និងមានប្រសិទ្ធភាព។ លោកគ្រូបានខិតខំប្រឹងប្រែងទាំងកម្លាំងកាយ និងកម្លាំងចិត្ត ពេលវេលាដ៏មានតម្លៃ ដើម្បីជួយកែសម្រួលសារណារបស់យើងខ្ញុំ។ ប្រសិនបើគ្មានលោកគ្រូទេ ក៏ពួកយើងមិនអាចធ្វើកិច្ចការមួយនេះបានល្អដែរ លោកគ្រូបានផ្តល់នៅអនុសាសន៍ល្អៗ និងបទពិសោធន៍ល្អៗជាច្រើន ដែលពួកយើងមិនបានដឹងពីមុនមក ហើយជាហេតុនាំឱ្យយើងធ្វើកិច្ចការនេះបាន។

ជាចុងក្រោយ យើងខ្ញុំទាំងពីរនាក់ក៏សូមអរគុណយ៉ាងជ្រាលជ្រៅម្តងទៀត ទៅកាន់លោកគ្រូ អ្នកគ្រូ លោកឪពុក អ្នកម្តាយ លោកសាស្ត្រាចារ្យ សូមឱ្យជួបពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់ពេលរយៈ ៤ ឆ្នាំរួចមកដោយការខិតខំប្រឹងប្រែង តាំងពីឆ្នាំទី១ រហូតមកដល់ឆ្នាំទី៣ ដោយទទួលបាននូវចំណាត់ថ្នាក់ល្អ ទើបអាចឱ្យពួកយើងខ្ញុំទាំងពីរនាក់ បានទទួលឱកាសក្នុងការសរសេរសារណាក្រោមប្រធានបទ **នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ ក្នុងរឿងក្តីរដ្ឋប្បវេណីនៅតុលាការកំពូល**។ ពួកយើងទាំងពីរពិតជាមានអារម្មណ៍សប្បាយរីករាយជាខ្លាំង ដែលអាចទទួលបាននូវឱកាស ហើយពួកយើងនឹងខិតខំប្រឹងប្រែងធ្វើកិច្ចការស្រាវជ្រាវមួយនេះឱ្យបានល្អ និងអស់ពីសមត្ថភាព។

ដើម្បីយល់ដឹងឱ្យកាន់តែច្បាស់ និងស៊ីជម្រៅពាក់ព័ន្ធទៅនឹងនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខក្នុងរឿងក្តីរដ្ឋប្បវេណី ថានៅក្នុងការប្តឹងសាទុក្ខត្រូវឡើងដោយបុគ្គលណា ហើយមូលហេតុអ្វីបណ្តាលឱ្យមានការធ្វើបណ្តឹងសាទុក្ខនេះ ការអនុវត្តចំពោះនីតិវិធីបណ្តឹងសាទុក្ខនឹងការជំនុំជំម្រះមានលំហូរនីតិវិធីបែបណា ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកស្រាវជ្រាវជំនាន់ក្រោយ ក៏ដូចជាតម្រូវការរបស់មិត្តអ្នកអាន។ លើសពីនេះទៅទៀត សារណាមួយនេះអាចលេចចេញជារូបរាងទៅបាន ដោយសារមានការជួយជ្រោមជ្រែង ផ្តល់អនុសាសន៍ និងកែតម្រូវផ្សេងៗ ដោយលោកគ្រូ **ហេង ម៉ូរ៉ា** បានខិតខំចំណាយពេលវេលាដ៏មានតម្លៃក្នុងការចែករំលែកនូវចំណេះដឹងបទពិសោធន៍ល្អៗ ផ្តល់ដំបូន្មាន ដែលអាចជាស្ពានឈានទៅកាន់ការបញ្ចប់នូវសារណាមួយនេះ។

ទោះបីជាយើងខ្ញុំបានធ្វើការត្រួតពិនិត្យផ្ទៀងផ្ទាត់កិច្ចការមួយនេះ យ៉ាងយកចិត្តទុកដាក់យ៉ាងណាក៏ដោយក៏យើងខ្ញុំជឿថានៅតែមានចំណុចខ្វះខាត និងខុសឆ្គងនៅត្រង់ផ្នែកណាមួយជាមិនខាន។ ហេតុនេះហើយ យើងខ្ញុំទាំងពីរ ក៏សូមខន្តីអភ័យទោសនូវរាល់ចំណុចខុសឆ្គងទាំងឡាយណា ដែលបានសរសេរទៅហើយមានការខ្វះខាត ខុសឆ្គងនៅត្រង់ពាក្យពេចន៍សម្តីណាមួយ ដែលកើតចេញពីកំហុសអចេតនានៅការស្រាវជ្រាវមួយនេះ យើងខ្ញុំសូមទទួលនូវរាល់ការរិះគន់ ដើម្បីស្ថាបនា និងកែលម្អ ដើម្បីកិច្ចការស្រាវជ្រាវមួយនេះមានភាពកាន់តែល្អប្រសើរឡើង និងអាចជាប្រយោជន៍បាន។

ចុងក្រោយយើងខ្ញុំទាំងពីរ ដែលជាអ្នកសរសេរកិច្ចការស្រាវជ្រាវមួយនេះ នឹងសង្ឃឹមថាកិច្ចការស្រាវជ្រាវមួយនេះ ជាប្រទីបដើម្បីបំភ្លឺផ្លូវ ដល់មិត្តអ្នកអាន និងចូលរួមឱ្យប្អូនៗនិស្សិត ដែលសរសេរជំនាន់ក្រោយៗពាក់ព័ន្ធនឹងប្រធានបទ នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ ក្នុងរឿងក្តីរដ្ឋប្បវេណី អាចយកធ្វើជាគំរូនៃការស្រាវជ្រាវជាបន្តបន្ទាប់ទៀតបាន។ ហើយយើងខ្ញុំក៏សូមជូនពរទៅកាន់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ និស្សិត ព្រះសង្ឃ លោក លោកស្រី ឱ្យជួបតែសំណាងល្អ និងមានការយល់ដឹងកាន់តែច្បាស់ពីនីតិវិធីនៃការប្តឹងសាទុក្ខ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** ........................................ ១

**ជំពូកទី១**
**សញ្ញាណទូទៅនៃបណ្ដឹងសាទុក្ខ**

**ផ្នែកទី១៖ ទិដ្ឋភាពទូទៅនៃបណ្ដឹងសាទុក្ខ** ........................................ ៤

១.១. និយមន័យនៃបណ្ដឹងសាទុក្ខ ........................................ ៤

១.២. គោលបំណងនៃការបណ្ដឹងសាទុក្ខ ........................................ ៤

១.៣. មូលហេតុនៃការធ្វើបណ្ដឹងសាទុក្ខ ........................................ ៥

១.៣.១. មូលហេតុទូទៅនៃបណ្ដឹងសាទុក្ខ ........................................ ៥

១.៣.២. មូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខ ........................................ ៦

១.៤. កម្មវត្ថុនៃបណ្ដឹងសាទុក្ខ ........................................ ៨

**ផ្នែកទី២៖ ប្រភេទនៃបណ្ដឹងសាទុក្ខ** ........................................ ៩

២.១. បណ្ដឹងសាទុក្ខទូទៅ ........................................ ៩

២.២. បណ្ដឹងសាទុក្ខឆ្លោះ ........................................ ៩

២.៣. បណ្ដឹងបន្ទាប់បន្សំ ........................................ ៩

**ផ្នែកទី៣៖ លក្ខខណ្ឌនៃបណ្ដឹងសាទុក្ខ** ........................................ ១១

៣.១. អ្នកមានសិទ្ធិធ្វើបណ្ដឹងសាទុក្ខ ........................................ ១១

៣.២. អំឡុងពេលនៃការធ្វើបណ្ដឹងសាទុក្ខ ........................................ ១១

៣.២.១. អំឡុងពេលនៃការដាក់ពាក្យបណ្ដឹងសាទុក្ខ ........................................ ១១

៣.២.២. អំឡុងពេលនៃការដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខ ........................................ ១២

៣.៣. អានុភាពនៃពាក្យបណ្ដឹង ........................................ ១២

៣.៣.១. អានុភាពបង្អាក់ការចូលជាស្ថាពរ ........................................ ១២

៣.៣.២. ការផ្ទេរការជំនុំជម្រះក្ដី ........................................ ១២

៣.៣.៣. អានុភាពអវិភាគនៃបណ្តឹងសាទុក្ខ ........ ១៣

## ជំពូកទី២
## នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ និងការបញ្ជូនទៅតុលាការកំពូល

**ផ្នែកទី១ ៖ នីតិវិធីនៃបណ្តឹងសាទុក្ខនៅតុលាការកំពូល** ........ ១៤
១.១. របៀបប្តឹងសាទុក្ខ ........ ១៤
១.១.១. របៀបដាក់ពាក្យបណ្តឹងសាទុក្ខ ........ ១៤
១.១.២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្តឹងសាទុក្ខ ........ ១៥
១.១.៣. ការពិនិត្យពាក្យបណ្តឹង ........ ១៥
១.១.៤. ប្រាក់ប្រដាប់ក្តី ........ ១៦
១.១.៤.១. ពន្ធដាក់ពាក្យសុំ ........ ១៦
១.១.៤.២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ........ ១៨
១.១.៤.៣. ប្រាក់ប្រដាប់ក្តីភាគី ........ ១៩
១.២. ការបញ្ជូន ........ ១៩
១.២.១. វិធីនៃការបញ្ជូន ........ ២០
១.២.១.១. ការបញ្ជូនដោយប្រគល់ ........ ២០
១.២.១.២. ការបញ្ជូនដោយជួបប្រទះ ........ ២១
១.២.១.៣. ការបញ្ជូនដោយបង្គ្រប់កិច្ច ........ ២១
១.២.១.៤. ការបញ្ជូនដោយទុកចោល ........ ២១
១.៣. ការបញ្ជូនទៅបរទេស ........ ២២
១.៣.១. ការបញ្ជូនតាមការផ្សាយជាសាធារណៈ ........ ២២
១.៣.២. របាយការណ៍នៃការបញ្ជូន ........ ២៤
**ផ្នែកទី២ ៖ ការជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី១ នៃតុលាការកំពូល** ........ ២៦
២.១. គោលការណ៍នៃការជំនុំជម្រះបណ្តឹងសាទុក្ខ ........ ២៦
២.២. ការទាញហេតុផលដោយផ្ទាល់មាត់បណ្តឹងសាទុក្ខលើកទី១ តុលាការកំពូល ........ ២៧

២.២.១. សមាសភាពចៅក្រមជំនុំជម្រះ..............................................................................២៧
២.២.២. សកម្មភាពទាញហេតុផលដោយផ្ទាល់មាត់..............................................................២៧
**ផ្នែកទី៣ ៖ ការទាញហេតុផលដោយផ្ទាល់មាត់លើបណ្តឹងសាទុក្ខលើកទី២** .................. ២៩
៣.១. សមាសភាពចៅក្រមជំនុំជម្រះ.................................................................................. ២៩
៣.២. សកម្មភាពនៃការទាញហេតុផលដោយផ្ទាល់មាត់.......................................................... ២៩
**ផ្នែកទី៤ ៖ ការបញ្ចប់បណ្តឹងសាទុក្ខ នៅតុលាការកំពូល** ............................................. ៣១
៤.១. ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ.............................. ៣១
៤.១.១. ការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ........................................................................ ៣១
៤.១.២. ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី .................................................................. ៣១
៤.១.២.២. ការលះបង់ ឬការទទួលស្គាល់នូវការទាមទារ ........................................................ ៣៣
៤.១.២.៣. ការសះជាតាមផ្លូវបណ្តឹង ................................................................................. ៣៤
៤.២. ការបញ្ចប់បណ្តឹងដោយសេចក្តីសម្រេចរបស់តុលាការ..........................................................៣៥
៤.២.១. ដីកាលើកចោលបណ្តឹងសាទុក្ខ ..........................................................................៣៥
៤.២.២. ដីកាចុងក្រោយ ..................................................................................................៣៥
៤.២.២.១. សាលដីកាច្រានចោលបណ្តឹង............................................................................ ៣៥
៤.២.២.២. សាលដីកាទទួលស្គាល់បណ្តឹងសាទុក្ខ................................................................... ៣៦

## ជំពូកទី៣
## បញ្ហាប្រឈម និងដំណោះស្រាយ

**ផ្នែកទី១៖ បញ្ហាប្រឈម**.......................................................................................៣៩
១.១. ភាពខ្វះចន្លោះនៃនីតិវិធីច្បាប់ ..............................................................................៣៩
១.២. កង្វះការយល់ដឹងរបស់ប្រជាពលរដ្ឋ........................................................................... ៤០
១.៣. ភាពយឺតយ៉ាវរបស់តុលាការកំពូល ...........................................................................៤១
១.៤. ដើមបណ្តឹងសាទុក្ខមិនបង់ប្រាក់ប្រដាប់ក្តី និងការចំណាយសោហ៊ុយបន្ទុករបស់គូភាគី................៤២
១.៥. ការមិនដាក់សារណានៃបណ្តឹងសាទុក្ខរបស់ភាគី ........................................................ ៤៤

១.៦. ភាពខ្វះចន្លោះនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ ................................................ ៤៥

**ផ្នែកទី២ ៖ ដំណោះស្រាយ** ...................................................................................................... ៤៧

២.១. ការបង្កើតច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិ ........................................................................ ៤៧

២.២. ការផ្សព្វផ្សាយច្បាប់ និងបណ្តុះបណ្តាលនីតិវិធីបណ្តឹងសាទុក្ខនៅតុលាការកំពូលឱ្យច្រើន ........... ៤៧

២.៣. ការពន្លឿននីតិវិធីរឿងបណ្តឹងសាទុក្ខ នៅតុលាការកំពូល ...................................................... ៤៧

២.៤. ជម្រុញឱ្យដើមបណ្តឹងសាទុក្ខបង់ប្រាក់ប្រដាប់ក្តី និងកាត់បន្ថយចំណាយបន្ទុកសោហ៊ុយច្រើន ...... ៤៩

២.៥. ជម្រុញឱ្យភាគីនៃបណ្តឹងសាទុក្ខដាក់សារណា និងសារណាតប ........................................... ៥១

២.៦. ការបង្កើតលិខិតបទដ្ឋានគតិយុត្តឱ្យច្បាស់ និងលំហូរនីតិវិធីការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ .. ៥១

**សេចក្តីសន្និដ្ឋាន** ................................................................................................................ ៥៤

**អនុសាសន៍** ........................................................................................................................ ៥៥

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងប្រទេសកម្ពុជាបើប្រជាជនមានវិវាទជាមួយគ្នារវាងបុគ្គលឯកជន និងបុគ្គលឯកជនដែលពាក់ព័ន្ធទំនាស់ញាតិ និងទំនាក់ទំនងទ្រព្យសម្បត្តិហើយបុគ្គលណាដែលមានវិវាទនេះ និងត្រូវដោះស្រាយដោយបណ្តឹងរដ្ឋប្បវេណី បណ្តឹងនេះជាការអនុវត្តសិទ្ធិទាមទារតាមផ្លូវតុលាការចំពោះវិវាទ ទាំងឡាយណាដែលទាក់ទងទៅនឹងវិវាទកើតចេញពីញាតិ និងទំនាក់ទំនងទ្រព្យសម្បត្តិ ហើយបុគ្គលដែលមានវិវាទទៅប្តឹងទៅតុលាការរដ្ឋប្បវេណី ដើម្បីស្វែងរកយុត្តិធម៌ ហើយភាគីដែលដាក់ពាក្យបណ្តឹងហៅថា "ដើមចោទ" រីឯភាគីដែលត្រូវគេប្តឹងហៅថា "ចុងចម្លើយ"។ តែការដោះស្រាយតាមផ្លូវតុលាការតែងតែមានភាពខ្វះខាត ច្បាប់ក៏បង្កើតឱ្យមានការធ្វើបណ្តឹងបានច្រើនប្រភេទដូចជា ការធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់បណ្តឹងនេះទៀតសោតមាន៣ ប្រភេទគឺ បណ្តឹងឧទ្ធរណ៍ បណ្តឹងជំទាស់ និងបណ្តឹងសាទុក្ខ។

ជាក់ស្តែងបណ្តឹងឧបាស្រ័យទាំង ៣ ប្រភេទនេះ គឺមានលក្ខណៈនីតិវិធីខុសៗគ្នា ដោយបណ្តឹងទាំងនោះក៏មានមូលហេតុខុសគ្នាផងដែរ ត្រង់នេះបណ្តឹងជំទាស់ជាបណ្តឹងដែលកើតឡើងពីការមិនយល់ព្រមចំពោះសាលក្រម ឬជាពាក្យតវ៉ាសុំបដិសេធសេចក្តីសម្រេចរបស់ចៅក្រម ដែលត្រូវបើកឱ្យគូក្តីមិនមានវត្តមាននៅពេលជំនុំជម្រះ ធ្វើឡើងនៅតុលាការដើម បណ្តឹងជំទាស់ត្រូវធ្វើនៅក្នុងអំឡុងពេល ១សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីដីកាសម្រេចហើយអំឡុងពេលនេះមិនអាចពន្យារបានឡើយ។ រីឯបណ្តឹងឧទ្ធរណ៍ គឺជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ចំពោះសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូងក្នុងគោលបំណងឱ្យតុលាការជាន់ខ្ពស់លុបចោល ឬផ្លាស់ប្តូរនូវសាលក្រមចុងក្រោយ។ ចំណែកឯបណ្តឹងសាទុក្ខជា ប្រភេទបណ្តឹងឧបាស្រ័យ ដែលធ្វើទៅតុលាការជាន់ខ្ពស់ និងជាបណ្តឹងដែលធ្វើឡើងប្រឆាំងនឹងសេចក្តីសម្រេចចុងក្រោយរបស់សាលាឧទ្ធរណ៍ ឬធ្វើឡើងប្រឆាំងនឹងសាលក្រមរបស់តុលាការ។ ប៉ុន្តែភាគីដែលមានបំណងចង់ប្តឹងសាទុក្ខលុះត្រាតែមានមូលហេតុត្រឹមត្រូវតាមច្បាប់កំណត់ ទើបអាចដាក់ពាក្យបណ្តឹងមានអានុភាពតាមផ្លូវច្បាប់។

បើយើងនិយាយអំពីនីតិវិធីនៃការជំនុំជម្រះលើកទី០១ ឬការបើកសវនាលើកទី០១ ប្រហែលមានប្រជាជនជាច្រើនបានដឹង និងយល់ខ្លះចំពោះការជំនុំជម្រះលើកទី០១ ប៉ុន្តែប្រសិនបើយើងសួរអំពីនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខនៃរឿងក្តីរដ្ឋប្បវេណីប្រហែលជាមិនមានប្រជាពលរដ្ឋច្រើនទេដែលយល់ដឹងអំពីបណ្តឹងសាទុក្ខ មានប្រជាជនតិចណាស់ដែលដឹងអំពីនីតិវិធីនេះព្រោះវាទាមទារឱ្យមានការយល់ដឹងនីតិវិធីនៃការជំនុំជម្រះអំពីបណ្តឹងសាទុក្ខនេះ ហើយអ្នកដែលយល់ដឹងក៏អាចនិយាយបានថាជាអ្នកបានសិក្សា និងស្វែងយល់ច្បាប់

បានជ្រៅជ្រះផងដែរ។ ក្នុងរឿងរដ្ឋប្បវេណីនៅក្រោយពេលដែលសាលាឧទ្ធរណ៍បានចេញសាលដីកា បើភាគីមិនសុខចិត្តនឹងសេចក្ដីសម្រេចនោះដោយខ្លួនយល់ថាសេចក្ដីសម្រេចធ្វើឡើងដោយផ្ទុយច្បាប់ គេអាចដាក់ពាក្យបណ្ដឹងសាទុក្ខទៅតុលាការកំពូល ដើម្បីឱ្យតុលាការកំពូលជំនុំជម្រះតាមការទាមទាររបស់ខ្លួន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាគោលការណ៍ ក្នុងរឿងបណ្ដឹងសាទុក្ខពិតជាមានភាពស្មុគស្មាញជាខ្លាំងសម្រាប់ប្រជាជនដែលមានវិវាទក្នុងរឿងរដ្ឋប្បវេណី ហេតុនេះទើបជម្រុញទឹកចិត្តឱ្យយើងខ្ញុំលើកយកប្រធានបទស្ដីពី "**នីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ ក្នុងរឿងក្ដីរដ្ឋប្បវេណីទៅតុលាការកំពូល**" ដើម្បីយកមកធ្វើការពន្យល់ និងធ្វើការបំភ្លឺ។ ជាងនេះទៅទៀតពេលដែលយើងធ្វើការលើកយកប្រធានបទស្ដីពី នីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ ក្នុងរឿងរដ្ឋប្បវេណីទៅតុលាការកំពូលមកបកស្រាយ ហើយការបកស្រាយនេះពាំនាំ និងចម្ងល់ចោទឡើងមួយចំនួនថា៖

- តើបណ្ដឹងសាទុក្ខជាអ្វី ហេតុអ្វីចាំបាច់ធ្វើបណ្ដឹងសាទុក្ខ?
- តើមានមូលហេតុអ្វីខ្លះដែលអាចប្ដឹងសាទុក្ខបាន ហើយបុគ្គលដែលអាចប្ដឹងសាទុក្ខបានមានលក្ខណៈបែបណា?
- តើការធ្វើបណ្ដឹងសាទុក្ខនេះត្រូវធ្វើឡើងរបៀបណា?
- តើនីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខក្នុងរឿងរដ្ឋប្បវេណីមានបញ្ហាប្រឈម និងដំណោះស្រាយបែបណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវប្រធានបទមួយនេះ ធ្វើឡើងក្នុងគោលបំណង ដើម្បីសិក្សាស្វែងយល់អំពីភាពមិនច្បាស់លាស់ និងចម្ងល់មួយចំនួន ក៏ដូចជាចង់ស្រាយបំភ្លឺអំពីបញ្ហាគតិយុត្តដូចដែលបានលើកឡើងខាងលើ ក៏ដូចជាពង្រឹង និងពង្រីកនូវសមត្ថភាពចំណេះដឹងផ្ទាល់ខ្លួនបន្ថែមទៀត ដែលទាក់ទងនឹងវិស័យរដ្ឋប្បវេណីផងដែរ។

## ៤. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ប្រធានបទនេះមានសារៈប្រយោជន៍ និងក្លាយជាទុនមួយសម្រាប់ជាឯកសារជំនួយស្មារតីដល់អ្នកអានគ្រប់រូប ព្រមទាំងដើម្បីទុកជាឯកសារដល់សិស្សនិស្សិតជំនាន់ក្រោយៗ អាចយល់ដឹងកាន់តែច្បាស់អំពីនីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ ក្នុងរឿងរដ្ឋប្បវេណីទៅតុលាការកំពូល។

## ៥. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

សារណានេះ ត្រូវបានរៀបរៀងដោយប្រើប្រាស់នូវវិធីសាស្ត្របែបពណ៌នា និងវិភាគ។ ចំពោះការប្រមូលទិន្នន័យ និងឯកសារនានាដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវនៃប្រធានបទនេះ យើងខ្ញុំបានស្វះស្វែងរកព័ត៌មាន

និងដកស្រង់ចេញពីប្រភពល្អៗ ព្រមទាំងច្បាប់សំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាឯកសារដែលពាក់ព័ន្ធមួយចំនួនដកស្រង់ចេញពីក្រមនីតិវិធីរដ្ឋប្បវេណី សៀវភៅរបស់សាស្ត្រាចារ្យ និងដកស្រង់ចេញពីច្បាប់ស្តីពីការរៀបចំអង្គការតុលាការជាដើម ដែលប្រភពទាំងអស់នោះជាប្រភពដែលអាចទុកចិត្តបាន។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទសារណាខាងលើនេះ យើងខ្ញុំសូមធ្វើការបែងចែកចេញជា ៣ (បី) ជំពូកធំៗគឺ៖

**ជំពូកទី១ សញ្ញាណទូទៅនៃបណ្តឹងសាទុក្ខ**

**ជំពូកទី២ នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ និងការបញ្ចប់នៅតុលាការកំពូល**

**ជំពូកទី៣ បញ្ហាប្រឈម និងដំណោះស្រាយ។**

# ជំពូកទី១
# សញ្ញាណទូទៅនៃបណ្តឹងសាទុក្ខ

# ជំពូកទី១
# សញ្ញាណទូទៅនៃបណ្ដឹងសាទុក្ខ

## ផ្នែកទី១៖ ទិដ្ឋភាពទូទៅនៃបណ្ដឹងសាទុក្ខ

### ១.១. និយមន័យនៃបណ្ដឹងសាទុក្ខ

ប្រសិនបើនៅក្រោយពេលដែលសាលាឧទ្ធរណ៍បានចេញសាលដីកា ភាគីនៅតែមិនសុខចិត្តទៀត នោះភាគីអាចធ្វើបណ្ដឹងសាទុក្ខទៅតុលាការកំពូលដែលជាតុលាការនៃការជំនុំជម្រះចុងក្រោយ។ យ៉ាងណាមិញ បណ្ដឹងសាទុក្ខ គឺជាបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវគោរពតាមលំហូរនីតិវិធីដូចជា ការដាក់ពាក្យបណ្ដឹងសាកទុក្ខតាមរបៀបនៃការធ្វើបណ្ដឹងសាទុក្ខមានកម្មវត្ថុ និងល័ក្ខខ័ណ្ឌឱ្យគ្រប់គ្រាន់អានុភាពនៃការដាក់ពាក្យបណ្ដឹងសាទុក្ខ និងបន្ថែមជាមួយបណ្ដឹងសាទុក្ខបន្ទាប់បន្សំ ការដកពាក្យបណ្ដឹងសាទុក្ខ នីតិវិធីនឹងការជំនុំជម្រះនៃបណ្ដឹងសាទុក្ខ និងចុងក្រោយចេញសាលដីកានៃការជំនុំជម្រះបណ្ដឹងសាទុក្ខ។ ដើម្បីឱ្យកាន់តែច្បាស់នៅខាងក្រោមនេះនឹងធ្វើការបកស្រាយអំពីលំហូរនីតិវិធីទាំងអស់ដូចជា៖

**និយមន័យនៃបណ្ដឹងសាទុក្ខ** គឺជាប្រភេទមួយនៃបណ្ដឹងឧបាស្រ័យ ដែលធ្វើទៅតុលាការជាន់ខ្ពស់ និងជាបណ្ដឹងដែលធ្វើឡើងប្រឆាំងនឹងសេចក្ដីសម្រេចចុងក្រោយរបស់សាលាឧទ្ធរណ៍ ឬធ្វើឡើងប្រឆាំងនឹងសាលក្រមរបស់សាលាដំបូងរាជធានី/ខេត្ត ក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាមិនប្ដឹងឧទ្ធរណ៍។ សូមបញ្ជាក់ថានៅក្នុងរឿងក្ដីរដ្ឋប្បវេណីគូភាគីបន្ទាប់ពីសាលាដំបូងរាជធានី/ខេត្ត ចេញសេចក្ដីសម្រេចរួចមក គូភាគីអាចធ្វើការព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថា មិនប្ដឹងឧទ្ធរណ៍ ហើយទុកសិទ្ធិប្ដឹងសាទុក្ខទៅតុលាការកំពូលតែម្ដង។

### ១.២. គោលបំណងនៃការបណ្ដឹងសាទុក្ខ

គោលបំណងនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ គឺជាការការពារផលប្រយោជន៍ភាគី ដែលទទួលរងការវិនិច្ឆ័យមិនត្រឹមត្រូវ នូវការខូចខាតប្រយោជន៍ពីការជំនុំជំម្រះដែលមិនត្រឹមត្រូវ ហើយមានគោលដៅធ្វើឱ្យមានឯកភាពចំពោះការបកស្រាយច្បាប់ដោយធ្វើការវិនិច្ឆ័យ ចំពោះសាលដីកាចុងក្រោយ ដែលចេញដោយតុលាការនៃបណ្ដឹងឧទ្ធរណ៍ ថាតើមានភាពផ្ទុយច្បាប់ធម្មនុញ្ញ ឬបទដ្ឋានគតិយុត្ត។[1] សាលាជម្រះក្ដីជាន់ខ្ពស់ មានសមត្ថកិច្ចត្រួតពិនិត្យលើកិច្ចការជម្រះក្ដីរបស់សាលាជម្រះក្ដីជាន់ទាប។ ការត្រួតពិនិត្យនេះប្រព្រឹត្តទៅក្នុងក្របខណ្ឌនៃនីតិវិធីឧបាស្រ័យ ដោយអនុលោមតាមបទបញ្ញត្តិស្ដីពីនីតិវិធីជាធរមាន។[2]

[1] មេធាវី ហេងប៉ូវ៉ា, *មេរៀននីតិវិធីរដ្ឋប្បវេណី* (ឆ្នាំសិក្សា២០២៣ ២០២៤), ទំព័រ១១១។

[2] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា១១ កថាខណ្ឌទី៣។

**សាលក្រម ឬសាលដីកា** ដែលអាចប្តឹងសាទុក្ខបានមានដូចជា សាលដីកាចុងក្រោយដែលត្រូវបានជំនុំជម្រះលើកទី២ ដោយសាលាឧទ្ធរណ៍ គឺជាសាលដីកាដែលសាលាឧទ្ធរណ៍ ចេញបន្ទាប់ពីការពិនិត្យ លើភស្តុតាង និងការទាញហេតុផលដោយផ្ទាល់មាត់ (សវនាការ) សាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី១ តាមបញ្ញត្តិនៃច្បាប់ពិសេសដូចជា សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាគណៈមេធាវី បន្ទាប់ពីសាលាឧទ្ធរណ៍បានជំនុំជម្រះលើកទី១ សាលដីកាចុងក្រោយនេះអាចធ្វើការប្តឹងសាទុក្ខបាន សាលក្រមចុងក្រោយដែលធ្វើការជំនុំជម្រះលើកទី១ ដោយសាលាដំបូងរាជធានី/ខេត្ត ក្នុងករណីដែលគូភាគីបានព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថាមិនប្តឹងឧទ្ធរណ៍ និងរក្សាសិទ្ធិក្នុងការប្តឹងសាទុក្ខទៅតុលាការកំពូលតែម្តង។

## ១.៣. មូលហេតុនៃការធ្វើបណ្តឹងសាទុក្ខ

បណ្តឹងសាទុក្ខមានមូលហេតុសំខាន់ ២ យ៉ាងគឺ មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ និងមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ។

ដើម្បីឱ្យតុលាការនៃបណ្តឹងសាទុក្ខ សម្រេចធ្វើការជំនុំជម្រះទៅតាមពាក្យបណ្តឹងរបស់ខ្លួនលុះត្រាតែក្នុងពាក្យបណ្តឹងរបស់ដើមបណ្តឹងសាទុក្ខនោះ បានសរសេរនូវមូលហេតុត្រឹមត្រូវតាមបទបញ្ញត្តិច្បាប់។ ប៉ុន្តែប្រសិនបើនៅក្នុងពាក្យបណ្តឹងសាទុក្ខនោះ មិនបានសរសេរនូវមូលហេតុនៃបណ្តឹងសាទុក្ខទេ ដើមបណ្តឹងសាទុក្ខត្រូវដាក់នូវលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនោះ ទៅតុលាការនៃបណ្តឹងសាទុក្ខនោះក្នុងរយៈពេលដែលច្បាប់បានកំណត់។ ផ្ទុយមកវិញប្រសិនបើក្នុងពាក្យបណ្តឹងនោះ មិនមានមូលហេតុនៃបណ្តឹងសាទុក្ខទេ ហើយបើខ្លួនមិនបានដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខក្នុងពេលកំណត់ទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវច្រានចោលបណ្តឹងសាទុក្ខនោះ។[3] ចំពោះមូលហេតុនៃបណ្តឹងសាទុក្ខត្រូវបានបែងចែកជាពីរ គឺមូលហេតុទូទៅ និងមូលហេតុដាច់ខាត។

### ១.៣.១. មូលហេតុទូទៅនៃបណ្តឹងសាទុក្ខ

មូលហេតុទូទៅនៃបណ្តឹងសាទុក្ខគឺ ជាភាពផ្ទុយធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្ត ដែលជះឥទ្ធិពលទៅលើសាលក្រម ឬសាលដីកា មានន័យថាភាគីមិនអាចធ្វើបណ្តឹងសាទុក្ខបានដោយគ្រាន់តែផ្អែកទៅលើមូលហេតុថាខ្លួនរងការខូចខាតប្រយោជន៍ពីសាលក្រម ឬសាលដីកាប៉ុណ្ណោះនោះទេ គឺត្រូវអះអាងនូវភាពផ្ទុយនឹងធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀត ដែលជាមូលហេតុនៃបណ្តឹងសាទុក្ខ។

ជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខធ្វើការវិនិច្ឆ័យតែលើអង្គច្បាប់ប៉ុណ្ណោះ ហេតុនេះហើយបានជាមាត្រា ២៨៤ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិអំពីមូលហេតុទូទៅនៃបណ្តឹងសាទុក្ខបានអនុញ្ញាតឱ្យដើម

[3] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៨៥។

បណ្តឹងសាទុក្ខ អាចយកមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឥទ្ធិពលលើសាលដីកា ឬសាលក្រម។[4] ដើមបណ្តឹងសាទុក្ខត្រូវសរសេរបញ្ជាក់អំពីបញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្ត និងមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តនោះ។ ហើយប្រសិនបើមូលហេតុនោះមានទំនាក់ទំនងជាមួយនឹងនីតិវិធីនៃបណ្តឹងត្រូវសរសេរបញ្ជាក់អំពីអង្គហេតុដែលផ្ទុយនោះឱ្យបានច្បាស់លាស់ផងដែរ។

### ១.៣.២. មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ

មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ សំដៅទៅលើការខុសនីតិវិធីធ្ងន់ធ្ងរ ជាទូទៅដើម្បីធ្វើបណ្តឹងសាទុក្ខ ដើមបណ្តឹងសាទុក្ខត្រូវយកមូលហេតុនៃការវិនិច្ឆ័យ ឬការសម្រេចសេចក្តីរបស់តុលាកាសាលាដំបូង ឬសាលាឧទ្ធរណ៍ដែលបានធ្វើឡើងផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តនានា ដែលមានឥទ្ធិពលទៅលើសាលក្រម ឬសាលាដីកានោះ។ ក្នុងចំណោមមូលហេតុមូលហេតុនៃភាពផ្ទុយនឹងច្បាប់ ឬបទដ្ឋានគតិយុត្តនេះផងដែរ ប្រសិនបើពិនិត្យឃើញថាមានកំហុកធ្ងន់ធ្ងរផ្នែកនីតិវិធីនោះ ដើមបណ្តឹងសាទុក្ខអាចយកមូលហេតុនេះ មកធ្វើជាមូលហេតុនៃបណ្តឹងសាទុក្ខបានជាដរាប ដោយពុំចាំបាច់ធ្វើការបញ្ជាក់អំពីឥទ្ធិពលនៃការបំពាននោះមកលើសាលក្រម ឬសាលដីកាដែលតុលាការចេញនោះក៏បាន។ មូលហេតុដែលផ្ទុយនឹងនីតិវិធិនេះហៅថា "មូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ" មូលហេតុទាំងនោះរួមមាន[5]៖

#### ក.តុលាការដែលចេញសាលក្រម ឬសាលដីកាមិនត្រូវបានចាត់តាំងស្របទៅតាមច្បាប់

ដូចជាករណីមានបញ្ហាអំពីចំនួនចៅក្រមនៃក្រុមប្រឹក្សាជំនុំជម្រះដែលធ្វើឡើងផ្ទុយនឹងបញ្ញត្តិនៃមាត្រា ២៣ ឬករណីដែលចៅក្រមមិនត្រូវបានចាត់តាំងជាចៅក្រមជំនុំជម្រះតាមច្បាប់ដូចមានចែងក្នុងមាត្រា ២៦ និង មាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីជាដើម។ ជាឧទាហរណ៍ ចៅក្រម ២ នាក់ ចេញសាលក្រមដែលត្រូវធ្វើដោយក្រុមប្រឹក្សាជំនុំជម្រះ ៣ នាក់។

#### ខ.ចៅក្រមដែលច្បាប់មិនអនុញ្ញាតឱ្យចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាបានចូលរួម៖

តាមច្បាប់មានតែចៅក្រមដែលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលជាមូលដ្ឋាន នៃការចេញសាលក្រម ឬសាលដីកាប៉ុណ្ណោះ ទើបអាចចេញសាលក្រម ឬសាលដីកាបាន។[6] តែក្នុងករណីចៅក្រមដែលមិនបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីជាមូលដ្ឋាននៃការចេញសាលក្រម ឬសាលដីកា បានចេញសាលក្រម ឬសាលដីកា នោះដើមបណ្តឹងសាទុក្ខអាចយកបញ្ហានេះធ្វើជាមូលហេតុនៃបណ្តឹងសាទុក្ខបាន។ ករណីមួយទៀត ប្រសិនបើតុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលដីកា ឬសាលក្រមដើម ហើយ

[4] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៤។
[5] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៥។
[6] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨៥។

បញ្ជូនត្រឡប់ទៅតុលាការដើមវិញ។ ក្នុងករណីនេះ ចៅក្រមនៃតុលាការដើមដែលបានចេញសាលក្រម ឬសាលដីកាលើកមុននោះមិនអនុញ្ញាតឱ្យចូលរួមក្នុងការសម្រេចសេចក្ដីនោះម្ដងទៀតបានឡើយ។[7] ឧទាហរណ៍៖ ចៅក្រមដែលបានវិនិច្ឆ័យ និងចេញសាលដីកា ឬសាលក្រម ទោះបីជាមានមូលហេតុនៃការដកហូតចៅក្រមក៏ដោយ ដូចជាសហព័ទ្ធរបស់ចៅក្រមជាភាគីក្នុងរឿងក្ដី ឬចៅក្រម និងដើមចោទធ្លាប់មានក្ដីពីមុនមក។[8]

**គ.ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការ៖**

សមត្ថកិច្ចផ្ដាច់មុខជាសមត្ថកិច្ចដែលកំណត់ដោយបញ្ញត្តិច្បាប់ ដោយមិនទទួលស្គាល់សមត្ថកិច្ចតុលាការផ្សេងទៀត ហើយក៏មិនអនុញ្ញាតឱ្យផ្ដល់សមត្ថកិច្ចនេះទៅតុលាការណាមួយដោយឆន្ទៈរបស់ភាគីឡើយ។ ជាការឧទាហរណ៍បណ្ដឹងលែងលះគ្នា និងបណ្ដឹងទាមទារឱ្យបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាពនៃបុត្តភាព ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចផ្ដាច់មុខសាលាដំបូងដែលមានសមត្ថកិច្ចនៅលំនៅឋានរបស់ភាគីនៃទំនាក់ទំនងឋានៈបុគ្គលដែលពាក់ព័ន្ធនឹងបណ្ដឹងនោះ ឬលំនៅឋាននាពេលដែលភាគីនោះទទួលមរណភាព។[9]

**ឃ.ការខ្វះសិទ្ធិតំណាងដែលកំណត់ដោយច្បាប់ សិទ្ធិតំណាងដោយអាណត្តិ ឬការប្រគល់សិទ្ធិចាំបាច់សម្រាប់អ្នកតំណាងដើម្បីធ្វើសកម្មភាពបណ្ដឹង៖**

ជាទូទៅសិទ្ធិតំណាងក្នុងការធ្វើសកម្មភាពបណ្ដឹងកើតមានតាមរយៈកិច្ចសន្យា និងការកំណត់ដោយច្បាប់។ ឧទាហរណ៍៖ ថា លោក (ក) បានធ្វើសកម្មភាពក្នុងនាមជាអ្នកអាណាព្យាបាលទូទៅរបស់អនីតិជន (ខ) ទាំងខ្លួនមិនមែនជាអ្នកអាណាព្យាបាលទូទៅរបស់អនីតិជន (ខ) នោះទេ ឬមេធាវីដែលមិនបានទទួលការប្រគល់សិទ្ធិ បានធ្វើសកម្មភាពបណ្ដឹង។

**ង.ភាពផ្ទុយនឹងបញ្ញត្តិស្ដីពីការបើកការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ៖**

ជាទូទៅសវនាការត្រូវបើកជាសាធារណៈដែលអនុញ្ញាតឱ្យសាធារណៈជនអាចចូលស្ដាប់បាន។ ក៏ប៉ុន្តែក្នុងករណីដែលតុលាការធ្វើជាអសាធារណៈដែលផ្ទុយនឹងបញ្ញត្តិមាត្រា១១៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះមានន័យថាផ្ទុយនឹងច្បាប់។ ឧទាហរណ៍៖ ការទាញហេតុផលដោយផ្ទាល់មាត់មិនបានធ្វើនៅសាលសវនាការជាសាធារណៈ ទាំងដែលគ្មានការព្រួយបារម្ភអំពីការប៉ះពាល់ដល់សណ្ដាប់ធ្នាប់សាធារណៈ ឬករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ នោះសាលសវនាការនៃការទាញហេតុផលដោយផ្ទាល់មាត់មិនត្រូវធ្វើជាសាធារណៈទេ។[10]

[7] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៩៩។
[8] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៧។
[9] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១០។
[10] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១១៥ កថាខណ្ឌទី ២។

**ច.សាលក្រម ឬសាលដីកាគ្មានសំអាងហេតុ ឬមានសំអាងហេតុតែផ្ទុយនឹងគ្នា៖**

ក្នុងសាលក្រម ឬសាលដីកាត្រូវតែមានសំអាងហេតុ ហើយសំអាងហេតុនោះត្រូវតែស្របទៅនឹងសេចក្តីសម្រេចផងដែរ។ ប្រសិនបើសំអាងហេតុនោះមិនគាំទ្រសេចក្តីសម្រេចទេនោះមានន័យថា សំអាងហេតុផ្ទុយគ្នា។ ឧទាហរណ៍៖ ខ្លឹមសារសរសេរនៅក្នុងសំអាងហេតុ ផ្ទុយគ្នានឹងចំនួនទឹកប្រាក់ដែលត្រូវបង្គាប់ឱ្យបង់។

## ១.៤. កម្មវត្ថុនៃបណ្តឹងសាទុក្ខ

កម្មវត្ថុនៃបណ្តឹងសាទុក្ខ គឺសំដៅទៅសេចក្តីសម្រេចដែលអាចប្តឹងសាទុក្ខបានមានតែសេចក្តីសម្រេចចុងក្រោយនោះចេញពីសាលាដំបូង ឬសាលាឧទ្ធរណ៍ទាំងអស់ ប៉ុន្តែការចេញសេចក្តីសម្រេចនេះមិនទាន់ចូលជាស្ថាពរ។ ម្យ៉ាងទៀតក្នុងករណីពិសេស ប្រសិនបើភាគីមានការព្រមព្រៀងគ្នាប្តឹងសាទុក្ខទៅតុលាការកំពូលបានតែម្តងដោយមិនចាំបាច់ឆ្លងកាត់សាលាឧទ្ធរណ៍ក៏បាន។ ចំពោះការយល់ព្រមដើម្បីផ្លោះសាលាឧទ្ធរណ៍ទៅតុលាការកំពូលនេះអាចធ្វើបានក្នុងករណីដែលជារឿងក្តីផ្នែករដ្ឋប្បវេណី ឬពាណិជ្ជកម្មដែលតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ៥,០០០,០០០រៀល។ **ដោយឡែកកម្មវត្ថុដែលមិនអាចប្តឹងសាទុក្ខបានមានដូចជា៖**

- សាលក្រមរបៀប ឬដីកាសម្រេច ឬសេចក្តីសម្រេចដែលមិនមែនជាសាលក្រម ឬសាលដីកាមិនអាចយកមកធ្វើបណ្តឹងសាទុក្ខបាននោះឡើយ។ ចំពោះសាលក្រមរបៀបមិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ធ្វើបណ្តឹងសាទុក្ខដោយឯករាជ្យបានឡើយ ការប្តឹងត្រូវផ្អែកលើសាលក្រម ឬសាលដីកាចុងក្រោយ។ប្រសិនបើគេបានប្តឹងសាទុក្ខចំពោះសាលក្រមចុងក្រោយ ឬសាលដីកាចុងក្រោយ សាលក្រមរបៀបនោះក៏ជាកម្មវត្ថុនៃការវិនិច្ឆ័យជាមួយគ្នានៅតុលាការកំពូលផងដែរ។ ដូចគ្នានេះផងដែរចំពោះសេចក្តីសម្រេចលើបន្ទុកនៃប្រាក់ប្រដាប់ក្តី ដែលជាប់ជាមួយនឹងសាលក្រម ឬសាលដីកាចុងក្រោយក៏មិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការធ្វើបណ្តឹងសាទុក្ខដោយឯករាជ្យតែឯងបានឡើយ។[11]
- ដីកាសម្រេចមុនសាលក្រម និងសាលដីកាចុងក្រោយ
- ផ្នែកដែលខកខានវិនិច្ឆ័យ
- សេចក្តីសម្រេចដែលមិនមែនជាសាលក្រម ឬសាលដីកា
- លើតែផ្នែកដែលសម្រេចអំពីបន្ទុកនៃប្រាក់ប្រដាប់ក្តី។

[11] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៨៦។

# ផ្នែកទី២៖ ប្រភេទនៃបណ្តឹងសាទុក្ខ

## ២.១. បណ្តឹងសាទុក្ខទូទៅ

ជាគោលការណ៍ បណ្តឹងសាទុក្ខទូទៅ អាចធ្វើចំពោះសាលដីកាចុងក្រោយនៃការជំនុំជម្រះលើកទី២ ដោយសាលាឧទ្ធរណ៍។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះសាលដីកាចុងក្រោយដែលសាលាឧទ្ធរណ៍ បានជំនុំជម្រះលើកទី១ តាមបញ្ញត្តិនៃច្បាប់ពិសេស។[12] បណ្តឹងសាទុក្ខតុលាការពិនិត្យតែទៅលើអង្គច្បាប់ ប៉ុណ្ណោះ របស់សាលក្រមចុងក្រោយ។

## ២.២. បណ្តឹងសាទុក្ខផ្លោះ

បណ្តឹងសាទុក្ខផ្លោះ គឺជាបណ្តឹងមួយដែលគូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍នៅក្រោយពេលដែល តុលាការបានចេញសាលក្រមចុងក្រោយដែលធ្វើការជំនុំជម្រះលើកទី១ ដោយសាលាដំបូង ដោយរក្សាទុកនូវ សិទ្ធិប្តឹងសាទុក្ខ បណ្តឹងសាទុក្ខអាចធ្វើទៅតុលាការកំពូលដោយផ្ទាល់បាន។ បណ្តឹងសាទុក្ខអាចធ្វើចំពោះ សាលក្រមចុងក្រោយរបស់សាលាដំបូងបាន លើកលែងតែករណីដែលបានកំណត់ខាងក្រោមនេះ៖

គូភាគីបានព្រមព្រៀងគ្នាមិនប្តឹងឧទ្ធរណ៍ ដោយរក្សាសិទ្ធិប្តឹងសាទុក្ខក្រោយពេលតុលាការបានចេញ សាលក្រមចុងក្រោយដោយរំលងការវិនិច្ឆ័យបណ្តឹងឧទ្ធរណ៍។

សេចក្តីព្រមព្រៀងដែលមិនប្តឹងឧទ្ធរណ៍ខាងលើនេះពុំមានអានុភាពឡើយ ប្រសិនបើមិនបានធ្វើលិខិតជា លាយលក្ខណ៍អក្សរ។

ភាគីទាំងសងខាងមិនមានវិវាទអំពីការទទួលស្គាល់អង្គហេតុទេ នៅក្នុងសាលក្រមជំនុំជម្រះលើកទី១។ បានសេចក្តីថាគូភាគីមិនមានទំនាស់ អំពីការទទួលស្គាល់អង្គហេតុនៅក្នុងសាលក្រមជំនុំជម្រះលើកទី១ទេ អាច ប្តឹងសាទុក្ខបាន ដោយសារតែតុលាការនៃបណ្តឹងសាទុក្ខវិនិច្ឆ័យតែអង្គច្បាប់តែប៉ុណ្ណោះ។

## ២.៣. បណ្តឹងបន្ទាប់បន្សំ

បណ្តឹងបន្ទាប់បន្សំ គឺជាបណ្តឹងមួយដែលធ្វើឡើងដោយឆ្លៀតឱកាសនៅពេលមានបណ្តឹងសាទុក្ខ។ មានន័យថានៅក្រោយពេលដែលដើមបណ្តឹងសាទុក្ខចំពោះសាលក្រម ឬសាលដីកាដែលចេញដោយតុលាការ ដើមនោះ ចុងបណ្តឹងសាទុក្ខបានឆ្លៀតឱកាសពេលនឹងធ្វើបណ្តឹងឧបាស្រ័យជាមួយនឹងបណ្តឹងសាទុក្ខរបស់ដើម បណ្តឹងសាទុក្ខ ដើម្បីទាមទារនូវចំណុចដែលខ្លួនចាញ់នៅក្នុងសាលក្រម ឬសាលដីការបស់តុលាការដើម។ ជា ឧទាហរណ៍៖ សាលាឧទ្ធរណ៍បានចេញសាលដីកាឱ្យដើមបណ្តឹងឧទ្ធរណ៍ឈ្នះ ២ចំណុចក្នុងចំណោម ៣ចំណុច ដែលគាត់បានទាមទារ ហើយដើមបណ្តឹងឧទ្ធរណ៍មិនធ្វើបណ្តឹងសាទុក្ខទេនោះទេ ប៉ុន្តែបើចុងបណ្តឹងឧទ្ធរណ៍

[12] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៨៣ កថាខណ្ឌទី១។

បានធ្វើបណ្តឹងសាទុក្ខឧបាស្រ័យនឹងសាលដីកា(ដំណាក់កាលបណ្តឹងឧទ្ធរណ៍ តុលាការចេញសាលដីកា) ដែលតុលាការឧទ្ធរណ៍បានចេញសេចក្តីសម្រេចបញ្ចប់។ ពេលនោះដើមបណ្តឹងឧទ្ធរណ៍ក៏បានធ្វើបណ្តឹងសាទុក្ខដែរ ដែលបណ្តឹងសាទុក្ខនោះជាបណ្តឹងសាទុក្ខបន្ទាប់បន្សំ ដែលអមទៅជាមួយបណ្តឹងសាទុក្ខរបស់ចុងបណ្តឹងឧទ្ធរណ៍។

អំឡុងពេលធ្វើបណ្តឹងសាទុក្ខបន្ទាប់បន្សំ ដូចគ្នានឹងបណ្តឹងសាទុក្ខដែរ ពោលគឺ០១ខែ គិតចាប់ពីថ្ងៃទទួលបានលិខិតសាលក្រម ឬថ្ងៃដែលជូនដំណឹងអំពីការសម្រេចប្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខចំពោះអំឡុងពេល ០១ខែ មិនអាចពន្យាពេលបានទេ។ ប៉ុន្តែក្នុងករណីបើបណ្តឹងសាទុក្ខបន្ទាប់បន្សំនោះធ្វើឡើងមិនហួសអំឡុងពេលប្តឹងសាទុក្ខ និងមានល័ក្ខខ័ណ្ឌនៃបណ្តឹងសាទុក្ខគ្រប់គ្រាន់ ករណីនេះហៅថាបណ្តឹងសាទុក្ខបន្ទាប់បន្សំ រមែងត្រូវអនុលោមទៅតាមបញ្ញត្តិនៃបណ្តឹងឧទ្ធរណ៍ គឺត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងសាទុក្ខបន្ទាប់បន្សំ។

# ផ្នែកទី៣៖ លក្ខខណ្ឌនៃបណ្តឹងសាទុក្ខ

## ៣.១. អ្នកមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ

ភាគីដែលមានសិទ្ធិធ្វើបណ្តឹងសាទុក្ខ គឺជាភាគីដែលមិនពេញចិត្ត និងការបាត់បង់ផលប្រយោជន៍ទាំងស្រុង ឬមួយផ្នែកក្នុងសាលក្រមចុងក្រោយនៃការជំនុំជម្រះលើកទី១ របស់សាលាដំបូង ឬសាលដីកាចុងក្រោយនៃការជំនុំជម្រះលើកទី២ របស់សាលាឧទ្ធរណ៍ ឬសាលដីការចុងក្រោយក្នុងនាមការជំនុំជម្រះលើកទី១ របស់សាលាឧទ្ធរណ៍ដែលមិនទាន់ចូលជាស្ថាពរ។ ដោយឡែក ភាគីដែលអាចធ្វើបណ្តឹងសាទុក្ខ អាចធ្វើឡើងដោយដើមចោទ ចុងចម្លើយ ដើមបណ្តឹងឧទ្ធរណ៍ ឬចុងបណ្តឹងឧទ្ធរណ៍។ នៅក្នុងនីតិវិធីនៃបណ្តឹងសាទុក្ខ ត្រូវបានហៅថា ដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខ។ សិទ្ធិប្តឹងសាទុក្ខកើតឡើង ក្នុងករណីដែលមានការព្រមព្រៀងរវាងភាគីទាំងសងខាងជាមុន ថាមិនប្តឹងឧទ្ធរណ៍ការព្រមព្រៀងមិនប្តឹងឧទ្ធរណ៍នោះ គឺជាការប្តឹងផ្លោះទៅបណ្តឹងសាទុក្ខតែម្តង។ ចំពោះការយល់ព្រមដើម្បីផ្លោះសាលាឧទ្ធរណ៍ទៅតុលាការកំពូលនេះ អាចធ្វើបានក្នុងករណីដែលជារឿងក្តីផ្នែករដ្ឋប្បវេណី ឬពាណិជ្ជកម្មដែលតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ៥,០០០,០០០ (ប្រាំលាន) រៀល។[13]

## ៣.២. អំឡុងពេលនៃការធ្វើបណ្តឹងសាទុក្ខ

អំឡុងពេលនៃបណ្តឹងសាទុក្ខត្រូវបែងចែកជាពីរគឺ៖

- អំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ និង
- អំឡុងពេលនៃការដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ។

### ៣.២.១. អំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ

អំឡុងពេលនៃការដាក់ពាក្យបណ្តឹងសាទុក្ខ យោងតាមមាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថា នីតិវិធីបណ្តឹងសាទុក្ខអនុវត្តដូចគ្នានឹងនីតិវិធីបណ្តឹងឧទ្ធរណ៍ ដូច្នេះមានរយៈពេល ១ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រម ឬសាលដីកា ឬថ្ងៃដែលបានជូនដំណឹងអំពីការសម្រេចច្រានចោល ឬលើកចោលនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ។[14]

---

[13] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៣ កថាខណ្ឌទី២។

[14] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៦០, មាត្រា២៨៦។

### ៣.២.២. អំឡុងពេលនៃការដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ

អំឡុងពេលនៃការដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ មានរយៈពេល ៣០ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូននូវលិខិតទទួលពាក្យបណ្តឹងសាទុក្ខ។[15] អំឡុងពេលនេះគឺ ដើម្បីកំណត់អំពីការដាក់មូលហេតុបណ្តឹងសាទុក្ខជាដាច់ខាត ដើម្បីកុំឱ្យមានការយឺតយ៉ាវលើនីតិវិធីដោយសារដាក់មូលហេតុនៃបណ្តឹងសាទុក្ខជាបន្តបន្ទាប់ ប្រសិនបើមិនបានសរសេរបញ្ជាក់ឱ្យបានច្បាស់លាស់នូវមូលហេតុនៃបណ្តឹងសាទុក្ខក្នុងពាក្យបណ្តឹងសាទុក្ខ ហើយនៅតែមិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃទេ តុលាការនៃបណ្តឹងសាទុក្ខអាចលើកចោលនូវបណ្តឹងសាទុក្ខនោះបាន ដោយមិនបាច់ធ្វើការទាញហេតុផលដោយផ្ទាល់មាត់។[16]

## ៣.៣. អានុភាពនៃពាក្យបណ្តឹង

នៅក្រោយពេលដែលពាក្យបណ្តឹងសាទុក្ខបានដាក់ទៅតុលាការដើមបណ្តឹងសាទុក្ខ នោះវានឹងបង្កើតឱ្យមានអានុភាពបង្អាក់នូវការចូលជាស្ថាពរនៃសាលដីកា ឬសាលក្រមរបស់តុលាការដើម អានុភាពនៃការផ្ទេរការជម្រះក្តី និងអានុភាពអវិភាគនៃបណ្តឹងសាទុក្ខ។

### ៣.៣.១. អានុភាពបង្អាក់ការចូលជាស្ថាពរ

នៅក្រោយពេលដែលបណ្តឹងសាទុក្ខត្រូវបានធ្វើឡើងត្រឹមត្រូវតាមអំឡុងពេលកំណត់ នោះវានឹងរារាំងអានុភាពនៃការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកា។ បានសេចក្តីថានៅពេលដែលដើមបណ្តឹងសាទុក្ខបានធ្វើបណ្តឹងក្នុងអំឡុងពេលមួយខែ បន្ទាប់ពីបានទទួលលិខិតសាលក្រម ឬសាលដីកា ទោះបីជារយៈពេលនៃការចូលជាស្ថាពរនៃសាលក្រម ឬសាលដីកាបានចូលមកដល់ ឬបានកន្លងផុតក៏ដោយក៏សាលក្រម ឬសាលដីកាមិនអាចចូលជាស្ថាពរដែរ។[17]

### ៣.៣.២. ការផ្ទេរការជំនុំជម្រះក្តី

នៅពេលដែលមានពាក្យបណ្តឹងសាទុក្ខ នោះការជំនុំជម្រះដោយតុលាការថ្នាក់ក្រោម (សាលាដំបូង ឬសាលឧទ្ធរណ៍) និងត្រូវផ្ទេរទៅតុលាការនៃបណ្តឹងសាទុក្ខជាអ្នកមានសមត្ថកិច្ចក្នុងការវិនិច្ឆ័យ និងចេញសេចក្តីសម្រេច។

[15] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៦០, មាត្រា២៨៩។
[16] សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ មាត្រា២៨៩។
[17] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៦, មាត្រា២៧៣, មាត្រា១៩៣ កថាខណ្ឌទី២។

### ៣.៣.៣. អានុភាពអវិភាគនៃបណ្តឹងសាទុក្ខ

ទោះបីជាដើមបណ្តឹងសាទុក្ខ បានធ្វើឧបាស្រ័យតែផ្នែកណាមួយនៃសាលក្រម ឬសាលដីកាដើមក៏ដោយ ក៏បណ្តឹងនោះអានុភាពបង្អាក់ការចូលជាស្ថាពរ និងមានការជំនុំជម្រះត្រូវកើតមានឡើងទៅលើការទាមទារទាំងអស់ដែលមាននៅក្នុងសាលក្រម ឬសាលដីកានោះ។ នេះគេហៅភាពអវិភាគនៃបណ្តឹងសាទុក្ខ បានសេចក្តីថា ទោះបីជាដើមបណ្តឹងសាទុក្ខ ធ្វើបណ្តឹងតែមួយផ្នែកនៅក្នុងសាលក្រម ឬសាលដីកាដើមផ្នែកដែលមិនបានធ្វើឧបាស្រ័យមិនអាចចូលជាស្ថាពរហើយក៏មិនអាចយកទៅអនុវត្តបានឡើយ លើកលែងតែមានការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្នដោយតុលាការដើម ឬក៏ដោយតុលាការនៃបណ្តឹងសាទុក្ខ ទើបផ្នែកដែលមិនអាចធ្វើឧបាស្រ័យនោះអាចអនុវត្តបាន។[18]

[19] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩៣ កថាខណ្ឌទី២ មាត្រា១៩៦, មាត្រា១៩៨។

# ជំពូកទី២

# នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ និង ការបញ្ជាប់នៅតុលាការកំពូល

# ជំពូកទី២

# នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ និងការបញ្ជូនទៅតុលាការកំពូល

## ផ្នែកទី១ ៖ នីតិវិធីនៃបណ្តឹងសាទុក្ខនៅតុលាការកំពូល

### ១.១. របៀបប្តឹងសាទុក្ខ

របៀបប្តឹងសាទុក្ខ ដើម្បីធ្វើការប្តឹងសាទុក្ខភាគីត្រូវដាក់ពាក្យបណ្តឹងទៅតុលាការដើម ក្នុងករណីនេះពាក្យបណ្តឹងសាទុក្ខត្រូវដាក់នៅសាលាឧទ្ធរណ៍ ប្រសិនបើធ្វើការប្តឹងប្រឆាំងនឹងសាលដីកាចុងក្រោយរបស់សាលាឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខត្រូវដាក់នៅសាលាដំបូងរាជធានី/ខេត្ត ចំពោះករណីដែលភាគីព្រមព្រៀងជាលាយលក្ខណ៍អក្សរមិនប្តឹងឧទ្ធរណ៍។

នៅពេលដែលមាន បណ្តឹងសាទុក្ខ ច្បាប់តម្រូវឱ្យតុលាការដើម (សាលាឧទ្ធរណ៍, សាលាដំបូងរាជធានី/ខេត្ត) ធ្វើការបញ្ជូនឱ្យឆាប់រហ័ស នូវពាក្យបណ្តឹងសាទុក្ខ និងសំណុំរឿងទៅតុលាការ នៃបណ្តឹងសាទុក្ខ (តុលាការកំពូល)។ ចំពោះអាជ្ញាយុកាលនៃការប្តឹងសាទុក្ខ ភាគីមានអំឡុងពេល ០១ (មួយ) ខែ ដែលត្រូវគិតចាប់ពីថ្ងៃដែលទទួលការបញ្ជូនលិខិតសាលក្រម ឬសាលដីកា។

#### ១.១.១. របៀបដាក់ពាក្យបណ្តឹងសាទុក្ខ

ដើម្បីធ្វើបណ្តឹងសាទុក្ខ ភាគីដែលមិនសុខចិត្តនឹងសាលក្រម ឬសាលដីកាដែលតុលាការបានចេញនោះ ត្រូវសរសេរពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរ ហើយត្រូវយកពាក្យបណ្តឹងសាទុក្ខនោះទៅដាក់នៅក្នុងតុលាការដែលបានចេញសាលក្រម ឬសាលដីកានោះក្នុងអំឡុងពេលកំណត់សម្រាប់ធ្វើបណ្តឹងសាទុក្ខ។ បន្ទាប់មកតុលាការដើមត្រូវធ្វើការផ្ទេរឱ្យបានឆាប់រហ័សនូវពាក្យបណ្តឹងសាទុក្ខនោះ និងសំណុំរឿងទៅតុលាការនៃបណ្តឹងសាទុក្ខ។[19]

តុលាការនៃបណ្តឹងសាទុក្ខ ដែលបានទទួលពាក្យបណ្តឹងសាទុក្ខ ត្រូវពិនិត្យពាក្យបណ្តឹងសាទុក្ខ ហើយប្រសិនបើពាក្យបណ្តឹងនោះមានចំណុចខ្វះខាត តុលាការត្រូវលើកចោលពាក្យបណ្តឹងសាទុក្ខនោះ ដោយដីកាសម្រេច។[20]

[19] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៨៥ វាក្យខណ្ឌទី១ និងវាក្យខណ្ឌទី២។

[20] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៦, មាត្រា២៦៦។

### ១.១.២. ចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងសាទុក្ខ

ដើម្បីធ្វើបណ្ដឹងសាទុក្ខទៅតុលាកាដើមនៃបណ្ដឹងសាទុក្ខ ត្រូវសរសេរពាក្យបណ្ដឹងសាទុក្ខជាលាយលក្ខណ៍អក្សរដាក់ទៅតុលាការដើម ភាគីមិនអាចធ្វើបណ្ដឹងសាទុក្ខដោយផ្ទាល់មាត់បានទេ ដូចនីតិជីនៃរឿងក្ដីចំនួនទឹកប្រាក់តិចតួចបានឡើយ។ ចំពោះពាក្យបណ្ដឹងត្រូវសរសេរនូវចំណុចមួយចំនួនដូចជាៈ

- ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ការសរសេរឈ្មោះ និងអាសយដ្ឋានរបស់ភាគីពិតជាមានសារៈសំខាន់ណាស់ដើម្បីឱ្យតុលាការធ្វើការបញ្ជូនដីកាកោះ និងលិខិត ឬឯកសារផ្សេងៗទៅភាគីនោះ។
- សញ្ញាណនៃសាលក្រម ឬដីកាចុងក្រោយដែលតុលាការដើមបានចេញនោះ និងសេចក្ដីដែលប្ដឹងសាទុក្ខនោះ។ ការសរសេរបែបនេះ គឺចង្អុលបង្ហាញអំពីអ្វីដែលខ្លួនមិនសុខចិត្ត និងអ្វីដែលខ្លួនទាមទារ ដើម្បីឱ្យតុលាការយកមកធ្វើការវិនិច្ឆ័យ ដោយហេតុថាតុលាការមិនអាចធ្វើការវិនិច្ឆ័យនូវអ្វីដែលភាគីមិនបានធ្វើឧបាស្រ័យឡើយ ៉គោលការណ៍តុលាការអកម្ម៉។
- មូលហេតុនៃបណ្ដឹងសាទុក្ខ វាជាចំណុចសំខាន់នៃពាក្យបណ្ដឹងសាទុក្ខព្រោះតុលាការនៃបណ្ដឹងសាទុក្ខវិនិច្ឆ័យទៅលើអង្គច្បាប់ ហេតុនេះពាក្យបណ្ដឹងត្រូវសរសេរអំពីមូលហេតុនៃបណ្ដឹងនោះ។[21] ការដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខមិនផ្ទុយនឹងមាត្រា ២៨៩ (ការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ) កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណីដោយត្រូវសរសេរមូលហេតុទូទៅនៃបណ្ដឹងសាទុក្ខដែលមានចែងក្នុងមាត្រា ២៨៤ និងមូលហេតុដាច់ខាតនៃបណ្ដឹងសាទុក្ខមានចែងក្នុងមាត្រា ២៨៥។

### ១.១.៣. ការពិនិត្យពាក្យបណ្ដឹង

នៅពេលដែលទទួលបាននូវពាក្យបណ្ដឹងសាទុក្ខ តុលាការនឹងធ្វើការពិនិត្យលើពាក្យបណ្ដឹងដោយ អនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីបណ្ដឹងឧទ្ធរណ៍ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្ដឹងសាទុក្ខ និងនីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ លើកលែងតែមានបញ្ញត្តិពិសេស។[22] អនុលោមតាម មាត្រា ២៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះសិទ្ធិពិនិត្យពាក្យបណ្ដឹងសាទុក្ខរបស់តុលាការនៃបណ្ដឹងសាទុក្ខ ពេលដែលបានទទួលពាក្យបណ្ដឹងសាទុក្ខ ត្រូវធ្វើការត្រួតពិនិត្យពាក្យបណ្ដឹងនោះ។ ក្នុងករណីដែលពិនិត្យឃើញថាពាក្យបណ្ដឹងនោះមិនបានសរសេរនូវចំណុចដែលត្រូវសរសេរ ដែលបានរៀបរាប់ខាងលើនេះទេ តុលាការនៃបណ្ដឹងសាទុក្ខត្រូវកំណត់អំឡុងពេលសមរម្យមួយ និងបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនោះ បញ្ញត្តិនេះក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែល ពន្ធសម្រាប់ដាក់ពាក្យបណ្ដឹងសាទុក្ខ មិនត្រូវបានបង់តាមបញ្ញត្តិនៃកថាខណ្ឌទី៤ មាត្រា ៦១

[21] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៦៥ កថាខណ្ឌទី២ និងកថាខណ្ឌទី៣។

[22] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៨៦។

(ពន្ធដាក់ពាក្យសុំ) នៃក្រមនេះដដែល។ តែបើដើមបណ្តឹងសាទុក្ខមិនបានកែតម្រូវចំណុចខ្វះខាតនោះក្នុងរយៈពេលកំណត់ទេ តុលាការនៃបណ្តឹងសាទុក្ខត្រូវលើកចោលពាក្យបណ្តឹងសាទុក្ខ ដោយដីកាសម្រេច។[23] ប៉ុន្តែប្រសិនបើដើមបណ្តឹងសាទុក្ខមិនបានដាក់លិខិតបញ្ជាក់អំពីមូលហេតុក្នុងអំឡុងពេលនេះទេ ឬមួយក៏បានដាក់លិខិតបញ្ជាក់អំពីមូលហេតុ តែសរសេរមិនត្រឹមត្រូវតាមការកំណត់នៃមូលហេតុទូទៅនៃបណ្តឹងសាទុក្ខ ឬមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខ នោះតុលាការនៃបណ្តឹងសាទុក្ខត្រូវលើកចោលបណ្តឹងសាទុក្ខនោះ។[24]

### ១.១.៤. ប្រាក់ប្រដាប់ក្តី

ប្រាក់ប្រដាប់ក្តី គឺជាប្រាក់ពន្ធ ឬសោហ៊ុយដែលភាគីត្រូវបង់សម្រាប់ចាត់ការរឿងក្តីរបស់ខ្លួនទៅតុលាការតាមបញ្ញាត្តិច្បាប់។ ប្រាក់ប្រដាប់ក្តីរួមមានពន្ធដាក់ពាក្យសុំប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ និងប្រាក់ប្រដាប់ក្តីភាគី។

ជាគោលការណ៍រដ្ឋត្រូវចំណាយ ដើម្បីធានាសិទ្ធិពឹងពាក់តុលាការរបស់បុគ្គល ប៉ុន្តែដោយសារបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងផលប្រយោជន៍របស់បុគ្គលឯកជន ដូចនេះភាគីត្រូវទទួលបន្ទុកនូវចំនួនណាមួយ នៃចំណាយសម្រាប់កិច្ចការបណ្តឹងរដ្ឋប្បវេណី។ ហេតុនេះហើយភាគី ដែលជាដើមចោទ ដែលបានដាក់ពាក្យបណ្តឹងត្រូវមានកាតព្វកិច្ចបង់ប្រាក់ប្រដាប់ក្តី ដើម្បីចូលជាថវិការរដ្ឋ និងសោហ៊ុយក្នុងការទៅលើនីតិវិធីក្នុងតុលាការរដ្ឋប្បវេណី។

ការបង់ប្រាក់ប្រដាប់ក្តីដែល ភាគី ឬបុគ្គលផ្សេងៗត្រូវទទួលបន្ទុក ក្រោយពីមានការសម្រេចសេចក្តីដោយសាលក្រម របស់តុលាការ ទៅលើបន្ទុកប្រាក់ប្រដាប់ក្តីដែលត្រូវបង់។

#### ១.១.៤.១. ពន្ធដាក់ពាក្យសុំ

ពន្ធដាក់ពាក្យសុំ គឺជាពន្ធដែលតុលាការតម្រូវឱ្យបង់ជាមុននៅពេលដែលដាក់ពាក្យសុំ។ ពន្ធនេះអាចជាពន្ធនៃការដាក់ពាក្យបណ្តឹង ឬពន្ធដាក់ពាក្យសុំផ្សេងៗ (ពាក្យសុំរាប់បញ្ចូលផងដែរនូវពាក្យបណ្តឹងជិតចិត្ត ចំពោះចៅក្រម ពាក្យបណ្តឹងតវ៉ាចំពោះសាលក្រមស្ថាពរ អំពីរឿងក្តីចំនួនទឹកប្រាក់តិច ពាក្យបណ្តឹងទាមទារឱ្យថែរក្សាការពារភស្តុតាង និងពាក្យបណ្តឹងជំទាស់) ទៀតដែលទាក់ទងនឹងសកម្មភាពនៃបណ្តឹង។[25]

ការបង់ពន្ធដាក់ពាក្យសុំត្រូវធ្វើឡើងដោយការបង់ប្រាក់នៅកន្លែងទទួលពាក្យនៃតុលាការនោះ។ ពាក្យសុំដែលមិនបានបង់ពន្ធនៅពេលដាក់ពាក្យទេ ត្រូវចាត់ទុកថាពាក្យសុំមិនស្របច្បាប់។[26]

តម្លៃកម្មវត្ថុនៃបណ្តឹង ត្រូវបានគណនាដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ ដែលបានទាមទារក្នុងបណ្តឹងនោះ ហើយក្នុងករណីមានការទាមទារច្រើនចំណុចតែមួយតម្លៃសរុបនៃការទាមទារនោះ ត្រូវចាត់ទុកជា

[23] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៦៦ កថាខណ្ឌទី១ និងកថាខណ្ឌទី២។

[24] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៦៦ កថាខណ្ឌទី៣។

[25] មេធាវី ហេងប៉ូរ៉ា, *មេរៀននីតិវិធីរដ្ឋប្បវេណី* (ឆ្នាំសិក្សា២០២៣ ២០២៤), ទំព័រ៣៥។

[26] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦១ កថាខណ្ឌទី៧។

តម្លៃកម្មវត្ថុនៃបណ្ដឹង។[27] ប៉ុន្តែក្នុងករណីដែលមានការពិបាក ក្នុងការគណនាមិនបានទេនោះត្រូវចាត់ទុកថាតម្លៃកម្មវត្ថុនៃបណ្តឹង តុលាការត្រូវកំណត់តម្លៃកម្មវត្ថុដោយឆន្ទានុសិទ្ធិ ឬប្រសិនបើតម្លៃនោះ មិនអាចគណនាបានទេនោះត្រូវចាត់ទុកថាតម្លៃកម្មវត្ថុនៃបណ្ដឹងមានចំនួន ៥.៥០០.០០០(ប្រាំលានប្រាំសែនរៀល)។[28]

ប៉ុន្តែចំពោះបុគ្គលដែលគ្មានលទ្ធភាព ឬទ្រព្យធនសម្រាប់ការបង់ប្រាក់ដែលចាំបាច់ដើម្បីរៀបចំ និងប្រព្រឹត្តទៅនៃនីតិវិធីបណ្ដឹងនោះបានទេ ឬបុគ្គលដែលអាចមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាពដោយសារការបង់ប្រាក់នេះ តុលាការអាចចេញដីកាសម្រេចឱ្យជួយសង្គ្រោះលើបណ្ដឹង តាមពាក្យសុំបាន។ ការផ្តល់ជំនួយសង្គ្រោះអាចជាដីកាសម្រេចពន្យាពេលបង់ប្រាក់ប្រដាប់ក្ដីតុលាការ ឬការអនុគ្រោះមិនបាច់ឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការតែម្ដង។ តែទោះជាយ៉ាងនេះក្ដី ប្រសិនបើអាចដឹងច្បាស់ថាគ្មានលទ្ធភាពនឹងឈ្នះក្ដីសោះ តុលាការមិនអាចផ្ដល់ជំនួយសង្គ្រោះលើបណ្ដឹងបានឡើយ។[29] ការផ្ដល់ជំនួយសង្គ្រោះលើបណ្ដឹង គឺដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន និងគោរពនូវគោលការណ៍សិទ្ធិពឹងពាក់តុលាការរបស់បុគ្គលដែលមានជីវភាពក្រីក្រ ឬមានការលំបាកយ៉ាងខ្លាំង ក្នុងការចិញ្ចឹមជីវិតដោយសារការបង់ប្រាក់នោះ។

ពន្ធដាក់ពាក្យសុំត្រូវបានគេគណនាជាភាគ តាមតម្លៃនៃកម្មវត្ថុនៃបណ្ដឹងនោះ បើយោងតាមបញ្ញត្តិនៃមាត្រា ៦១ កថាខណ្ឌទី១ នៃនីតិវិធីរដ្ឋប្បវេណីពន្ធត្រូវបានបែងចែកជា ៤ ភាគដូចជា[30]៖

| **ម.៦១(១)** | **កម្មវត្ថុនៃបណ្ដឹង(A)** | **រូបមន្តក្នុងការគណនា** |
|---|---|---|
| **ក** | តិចជាង ឬស្មើនឹង ១លានរៀល | A x 10/1,000 |
| **ខ** | លើសពី ១០លានរៀល ដល់ ១០០លានរៀល | 100,000៛ + [(A-10,000,000) x 7/1,000] |
| **គ** | លើសពី ១០០លានរៀល ដល់ ១០០០លានរៀល | 730,000៛ +[(A-100,000,000) x 3/1000] |
| **ឃ** | លើសពី ១០០០លានរៀល | 3,430,000៛ [(A -1,000,000,000) x 1/1,000] |

ចំពោះរូបមន្តដែលបានបង្ហាញខាងលើនេះ ជារូបមន្តសម្រាប់គណនាតម្លៃពន្ធដាក់ពាក្យសុំនៃនីតិវិធីជំនុំជម្រះលើកទី១ ប៉ុណ្ណោះ។ ចំណែកឯពន្ធដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ត្រូវបង់ ១,៥ ដងនៃតម្លៃដែលបានគណនា

[27] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦០ កថាខណ្ឌទី២។
[28] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៦០ កថាខណ្ឌទី៣។
[29] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦៩។
[30] រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, *សៀវភៅ ស្ដីពី ការពន្យល់អំពីនីតិវិធីជម្រះក្ដីលើកទី១* (បោះពុម្ពលើកទី២ ឆ្នាំ២០០៩), ទំព័រ១៣។

ខាងលើ ចំពោះការគណនាតម្លៃនៃពន្ធដាក់ពាក្យបណ្តឹងសាទុក្ខវិញត្រូវស្មើ ២ ដងនៃតម្លៃដែលគណនាឃើញខាងលើនេះ។[31] ឧទាហរណ៍កម្មវត្ថុនៃបណ្តឹងមានចំនួន ១០,០០០.០០០(ដប់លាន) រៀលនោះ ៖

- ពន្ធដាក់ពាក្យសុំនៅក្នុងនីតិវិធីជំនុំជម្រះលើកទី១ = ១០,០០០,០០០ x ១០/១,០០០ = ១០០,០០០ រៀល
- ពន្ធដាក់ពាក្យសុំនៅក្នុងនីតិវិធីបណ្តឹងឧទ្ធរណ៍ = ១០០,០០០៛ x ១.៥ = ១៥០.០០០ រៀល
- ពន្ធដាក់ពាក្យសុំនៅក្នុងនីតិវិធីបណ្តឹងសាទុក្ខ = ១០០,០០០៛ x ២ = ២០០,០០០ រៀល។

### ១.១.៤.២. ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ

ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ ជាប្រាក់ប្រដាប់ក្តីដែលភាគី ឬបុគ្គលដែលទាក់ទងទៅនឹងរឿងក្តីត្រូវបង់ជាមុនទៅតាមការកំណត់របស់តុលាការសម្រាប់ការចំណាយរបស់តុលាការ ដើម្បីឱ្យតុលាការធ្វើសកម្មភាពតាមនីតិវិធីប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធដូចជា[32]៖

- ចំនួនទឹកប្រាក់ចាំបាច់ដើម្បីឱ្យតុលាការធ្វើការបញ្ជូនឯកសារ ឬសកម្មភាពផ្សេងៗទៀត។
- ចំនួនទឹកប្រាក់ស្មើនឹងសោហ៊ុយធ្វើដំណើរ និងស្នាក់នៅរបស់ចៅក្រម និងក្រឡាបញ្ជី ក្នុងករណីដែលដែលធ្វើការពិនិត្យភស្តុតាង ការស្រាវជ្រាវអង្គហេតុ ឬសកម្មភាពផ្សេងៗទៀតដែលប្រព្រឹត្តទៅនៅក្រៅតុលាការ។

សកម្មភាពតាមនីតិវិធី ក្នុងបណ្តឹងរបស់តុលាការអាចត្រូវបានធ្វើឡើងតាមពាក្យសុំរបស់ភាគីដែលទាក់ទងនឹងរឿងក្តី ឬដោយឆន្ទានុសិទ្ធិរបស់តុលាការ។ ក្នុងករណីដែលសកម្មភាពនេះត្រូវបានធ្វើឡើង ដោយពាក្យសុំនោះជនដែលបានដាក់ពាក្យសុំ ត្រូវបង់ប្រាក់ប្រដាប់ក្តី មុនតាមការបង្គាប់របស់តុលាការ។ ក្នុងករណីដែលសកម្មភាពនៅក្នុងនីតិវិធី ត្រូវបានធ្វើឡើងដោយឆន្ទានុសិទ្ធិរបស់តុលាការនោះ តុលាការអាចកំណត់ឱ្យភាគី ឬបុគ្គលដែលទាក់ទងនឹងរឿងក្តីបង់មុន។

តុលាការអាចពិនិត្យលើលទ្ធភាព ស្ថានភាពសេដ្ឋកិច្ច ដើម្បីកំណត់ឱ្យជនណាមួយបង់ប្រាក់នេះមុនសម្រាប់សកម្មភាពនីតិវិធី។

ក្នុងករណីដែលមិនបានបង់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធនេះជាមុនទេ តុលាការអាចប្រមូលពីអ្នកដែលទទួលបន្ទុកលើប្រាក់ប្រដាប់ក្តី។[33] ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីដែលចាញ់ក្តី ក្នុងករណីដែលភាគីចាញ់ក្តីតែមួយភាគទេ តុលាការត្រូវសម្រេចនូវបន្ទុកដែលភាគីម្នាក់ៗត្រូវទទួលខុសត្រូវដោយឆន្ទានុសិទ្ធិ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក៏តុលាការអាចសម្រេចឱ្យភាគីដែលឈ្នះក្តី ទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីទាំងអស់ ឬមួយភាគបានដែរ បើសិនបើភាគីដែលឈ្នះក្តីនោះបានប្រព្រឹត្តសកម្មភាពបណ្តឹងណាមួយដែលមិនចាំបាច់ក្នុងការតទល់ ឬការ

[31] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦១ កថាខ័ណ្ឌទី៣។
[32] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦២។
[33] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦២ កថាខ័ណ្ឌទី៥។

ការពារខ្លួន ឬបានធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីនៃបណ្តឹងចំពោះអ្នកធ្វើសហបណ្តឹងត្រូវទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីទៅតាមភាគស្មើស្មើគ្នា។ ប៉ុន្តែតុលាការអាចសម្រេចទៅតាមកាលៈទេសៈឱ្យភាគីដែលធ្វើសហបណ្តឹងទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីដោយសាមគ្គី ឬឱ្យភាគីណាមួយដែលបានប្រព្រឹត្តសកម្មភាពបណ្តឹងណាដែលមិនចាំបាច់ក្នុងការតទល់ ឬការការពារខ្លួនជាអ្នកទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តីច្រើនជាងភាគីដែលបានធ្វើសហបណ្តឹងផ្សេងទៀតបាន។ ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកតំណាងដោយអាណត្តិ ឬក្រឡាបញ្ជីបានធ្វើឱ្យចំនួនទឹកប្រាក់ប្រដាប់ក្តីដែលគ្មានប្រយោជន៍កើនឡើងដោយចេតនា ឬដោយកំហុសធ្ងន់ធ្ងររបស់ខ្លួនតុលាការដែលទទួលពាក្យបណ្តឹងអាចបង្គាប់ឱ្យអ្នកនោះសងនូវចំនួននៃប្រាក់ប្រដាប់ក្តីនោះវិញបាន។ ការសម្រេចនេះត្រូវធ្វើដោយដីកាសម្រេចតាមពាក្យសុំ ឬដោយឆន្ទានុសិទ្ធិរបស់ខ្លួន។[34]

#### ១.១.៤.៣. ប្រាក់ប្រដាប់ក្តីភាគី

ប្រាក់ប្រដាប់ក្តីភាគី គឺជាប្រាក់ប្រដាប់ក្តីដែលកំណត់ដោយ តុលាការដោយពិចារណាលើលក្ខណៈនៃរឿងក្តី ឬលក្ខភាពទ្រព្យធនរបស់ភាគីជាអាទិ៍។ ប្រាក់ប្រដាប់ក្តីភាគីមានដូចជាៈ

- ថ្លៃធ្វើលិខិតមានដូចជា លិខិតមានដូចជា លិខិតពាក្យបណ្តឹង លិខិតពាក្យសុំផ្សេងៗទៀត ឬឯកសារផ្សេងៗដូចជា ឯកសារត្រៀមជាដើម និងថ្លៃដាក់ឯកសារនោះទៅតុលាការ។
- សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងសោហ៊ុយស្នាក់នៅសម្រាប់ភាគី និងអ្នកតំណាង ដើម្បីបង្ហាញខ្លួនតាមកាលបរិច្ឆេទដែលបានកំណត់។
- សោហ៊ុយផ្សេងៗទៀត ដែលតុលាការទទួលស្គាល់ថា ជាសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តនូវនីតិវិធីបណ្តឹង។

### ១.២. ការបញ្ជូន

ការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹងអំពីខ្លឹមសារនៃឯកសារដែលត្រូវធ្វើការបញ្ជូន តាមផ្លូវបណ្តឹងចំពោះភាគីនិងអ្នកដទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍។ រីឯការជូនដំណឹង គឺជាវិធីដែលមានលក្ខណៈទូលាយ និងងាយស្រួលជាងវិធីនៃការបញ្ជូនដោយសារហេតុថាការជូនដំណឹងមន្ត្រីប្រតិបត្តិការបញ្ជូនអាចប្រើគ្រប់មធ្យោបាយដូចជា(តាមទូរស័ព្ទ អ៊ីមែល សំបុត្រជាដើម) ដើម្បីឱ្យអ្នកដែលត្រូវទទួលការបញ្ជូនបានដឹងក្នុងនោះនីតិវិធីនៃការបញ្ជូនក៏ជាមធ្យោបាយមួយនៃការបញ្ជូនផងដែរ។

នៅក្រោយពេលដែលបានទទួលបណ្តឹងពីតុលាការដើម តុលាការនៃបណ្តឹងសាទុក្ខ ត្រូវធ្វើការពិនិត្យពាក្យបណ្តឹងនោះនឹងធ្វើការបញ្ជូនលិខិត ឬដីកា ឬក៏ឯកសារផ្សេងៗទៅភាគីតាមភាពចាំបាច់ដែលត្រូវធ្វើការ

[34] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៦៤។

បញ្ជូនប្រសិនបើមិនចាំបាច់ទេតុលាការគ្រាន់តែធ្វើការជូនដំណឹងជាការគ្រប់គ្រាន់។ ចំពោះភាគីដែលត្រូវធ្វើការបញ្ជូននៅពេលនេះមានពីរ គឺការបញ្ជូនទៅភាគីខាងដើមបណ្តឹងសាទុក្ខ និងការបញ្ជូនទៅភាគីខាងចុងបណ្តឹងសាទុក្ខ។

បន្ទាប់ពីបានទទួលពាក្យបណ្តឹងសាទុក្ខ និងពិនិត្យឃើញថាពាក្យបណ្តឹងនោះត្រឹមត្រូវតាមច្បាប់ហើយ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបញ្ជូននូវលិខិតទទួលពាក្យបណ្តឹងសាទុក្ខ និងដីកាកោះ ឬឯកសារផ្សេងទៀតទៅដើមបណ្តឹងសាទុក្ខ។[35] ប្រសិនបើពិនិត្យឃើញថាពាក្យបណ្តឹងនោះមិនត្រឹមត្រូវ ឬមិនបានសរសេរនៅចំណុចដែលត្រូវសរសេរតាមការកំណត់ដោយច្បាប់នោះតុលាការត្រូវចេញដីកាបង្គាប់ឱ្យកែតម្រូវពាក្យបណ្តឹងនោះ ហើយត្រូវជូនដំណឹងទៅដើមបណ្តឹងសាទុក្ខ។[36]

ពាក្យបណ្តឹងសាទុក្ខ និងដីកាកោះ ឬឯកសារផ្សេងៗទៀត ក៏ត្រូវតែធ្វើការបញ្ជូនទៅចុងបណ្តឹងសាទុក្ខ ការកំណត់បែបនេះគឺដើម្បីធានានូវគោលការណ៍ចំពោះមុខដែលត្រូវធ្វើការកោះហៅភាគី និងការសាកសួរមុនធ្វើការកាត់សេចក្តី។[37]

### ១.២.១. វិធីនៃការបញ្ជូន

ដើម្បីធ្វើការបញ្ជូនត្រឹមត្រូវតាមច្បាប់ លុះត្រាតែវិធីនៃការបញ្ជូននោះធ្វើឡើងស្របទៅតាមច្បាប់។ នៅក្នុងបញ្ញត្តិច្បាប់ វិធីនៃការបញ្ជូនមាន ៣ បៀបសំខាន់ៗ គឺ ការបញ្ជូនដោយប្រគល់ ការបញ្ជូនទៅបរទេស និងការបញ្ជូនតាមផ្សាយសាធារណៈ។

#### ១.២.១.១. ការបញ្ជូនដោយប្រគល់

ជាគោលការណ៍ការបញ្ជូនដោយប្រគល់ ត្រូវធ្វើឡើងដោយការប្រគល់នូវឯកសារដែលត្រូវធ្វើការបញ្ជូនទៅឱ្យជនដែលត្រូវទទួលការបញ្ជូននោះ។[38] ហើយការប្រគល់នោះ ត្រូវធ្វើឡើងនៅលំនៅឋាន ឬទីស្នាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូននោះ។ ពាក្យថាលំនៅឋាន គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ក្នុងករណីដែលទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីស្នាក់ត្រូវចាត់ទុកជាលំនៅឋាន។[39] ចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់អាចធ្វើទៅនៅទីកន្លែងអាជីវកម្ម ឬទីស្នាក់ការ ឬលំនៅឋានរបស់អ្នកតំណាងនោះ។

---

[35] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៨៨។

[36] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៨៦,២៦៦ វាក្យខ័ណ្ឌទី១ កថាខ័ណ្ឌទី១។

[37] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៦៧។

[38] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៤៧ កថាខ័ណ្ឌទី១។

[39] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៤៩។

ទោះជាយ៉ាងនេះក្តី ប្រសិនបើមានការជូនដំណឹងអំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬជូនដំណឹងអំពីការផ្លាស់ប្តូរទីកន្លែងនោះត្រូវធ្វើការបញ្ជូនទៅទីកន្លែងដែលជូនដំណឹងនោះ។ ការជូនដំណឹងខាងលើនេះត្រូវធ្វើជាលាយលក្ខណ៍អក្សរ ក្នុងករណីដែលពាក្យបណ្តឹងដែលបានបញ្ជាក់អំពីទីកន្លែងដែលត្រូវធ្វើការបញ្ជូន ឬអ្នកដែលទទួលការបញ្ជូន ក៏ត្រូវចាត់ទុកថាភាគីបានជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីទីកន្លែង។[40] ការជូនដំណឹងនេះត្រូវមានអានុភាពចាប់ពីពេលនីតិវិធីជំនុំជម្រះលើកទី១ រហូតដល់តុលាការជាន់ខ្ពស់លើកលែងតែមានការជូនដំណឹងអំពីការផ្លាស់ប្តូរទីកន្លែងដែលត្រូវធ្វើការបញ្ជូន។ ការបញ្ជូនដោយប្រគល់ត្រូវបែងចែកជា ៣ គឺការបញ្ជូនដោយជួបប្រទះការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោល។

**១.២.១.២. ការបញ្ជូនដោយជួបប្រទះ**

ការបញ្ជូនដោយជួបប្រទះ ជាការប្រគល់នូវឯកសារដែលត្រូវបានបញ្ជូននោះ ទៅអ្នកដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលជួបប្រទះជននោះ។ ជាគោលការណ៍ការបញ្ជូនត្រូវធ្វើឡើងនៅទីកន្លែងដែលបានជូនដំណឹង ប៉ុន្តែប្រសិនបើជនដែលត្រូវទទួលការបញ្ជូននោះពុំច្បាស់លាស់ថាមានលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេការបញ្ជូនអាចធ្វើបាននៅទីកន្លែងដែលជួបប្រទះជននោះ។ ការបញ្ជូនដោយជួបប្រទះនេះអាចធ្វើទៅបានក្នុងករណីដែលជននោះមិនបានប្រកែកទទួលការបញ្ជូននោះ។[41]

**១.២.១.៣. ការបញ្ជូនដោយបង្គ្រប់កិច្ច**

ការបញ្ជូនដោយបង្គ្រប់កិច្ច ជាការបញ្ជូនដោយប្រគល់នូវឯកសារដែលត្រូវធ្វើការបញ្ជូនទៅជនដទៃទៀតផ្សេងពីអ្នកដែលត្រូវទទួលការបញ្ជូន នៅទីកន្លែងដែលត្រូវទទួលបានការបញ្ជូននោះ។ ក្នុងករណីដែលមិនបានជួបអ្នកដែលត្រូវទទួលការបញ្ជូនអាចប្រគល់ឯកសារដែលត្រូវធ្វើការបញ្ជូនទៅអ្នកបម្រើ ឬអ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬអ្នកដែលនៅជាមួយដែលមានការយល់ដឹងសមរម្យក្នុងការទទួលការប្រគល់ឯកសារនោះបាន។[42] អ្នកដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារដែលបានទទួលឯកសារ គឺជាអ្នកដែលអាចយល់ដឹងច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន និងអត្ថន័យនៃឯកសារដែលបានទទួល ហើយមានសមត្ថភាពអាចយកឯកសារនោះ ទៅប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូននោះ។

**១.២.១.៤. ការបញ្ជូនដោយទុកចោល**

ការបញ្ជូនដោយទុកចោល ជាការបញ្ជូនដោយទុកឯកសារដែលត្រូវធ្វើការបញ្ជូននៅកន្លែងបញ្ជូននោះ។ ប្រសិនបើជនដែលត្រូវទទួលការបញ្ជូន អ្នកបម្រើ ឬអ្នកផ្សេងដែលធ្វើការនៅទីនោះ ឬអ្នកដែលនៅជាមួយដែល

[40] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥០។

[41] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥១។

[42] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥២ កថាខណ្ឌ១។

មានការយល់ដឹងសមរម្យ បានប្រកែកមិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវ មន្ត្រីប្រតិបត្តិកិច្ចការបញ្ជូនអាចទុកឯកសារនេះនៅកន្លែងដែលត្រូវបញ្ជូននោះបាន។[43]

## ១.៣. ការបញ្ជូនទៅបរទេស

ករណីជនដែលត្រូវទទួលការបញ្ជូនមានទីលំនៅ នៅបរទេសហើយពុំមានទីសំណាក់ ទីកន្លែងអាជីវកម្ម ឬទីស្នាក់ការដែលអាចបញ្ជូនបាននៅក្នុងប្រទេសកម្ពុជាទេការបញ្ជូននេះអាចធ្វើបានតាមវិធី៖

- ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិបរទេស គប្បីបញ្ជូនដល់ប្រគល់ឱ្យទៅក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៃប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន។
- ករណីជនដែលត្រូវទទួលការបញ្ជូន ជាជនជាតិខ្មែរតែរស់នៅបរទេស គប្បីបញ្ជូនដោយប្រគល់ឱ្យអគ្គរាជទូត ភារធារី ឬកុងស៊ុលរបស់ប្រទេសកម្ពុជាប្រចាំប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន។

មុននឹងបញ្ជូនតុលាការគប្បីមើល សន្ធិសញ្ញា ឬអនុសញ្ញា ឬកិច្ចព្រមព្រៀងផ្សេងៗទៀតរវាងប្រទេសនោះ និងប្រទេសកម្ពុជាអំពីការជួយគ្នាផ្នែកច្បាប់ជាមុនសិន ព្រោះករណីខ្លះក្នុងលិខិតុបករណ៍អន្តរជាតិទាំងនោះមានចែងអំពីនីតិវិធីការបញ្ជូន។[44]

### ១.៣.១. ការបញ្ជូនតាមការផ្សាយជាសាធារណៈ

ការបញ្ជូនតាមការផ្សាយជាសាធារណៈ អាចធ្វើឡើងដោយការបិទប្រកាសនៅទីកន្លែងបិទប្រកាសរបស់តុលាការ ឬកន្លែងដែលតុលាការទទួលស្គាល់ថាសមស្របអាចជា ប៉ុស្តិ៍នគរបាល សាលាឃុំ ឬសាលាសង្កាត់ជាដើមដែលត្រូវប្រកាសថាក្រឡាបញ្ជីជាអ្នករក្សាទុកនៅឯកសារដែលត្រូវធ្វើការបញ្ជូន ហើយអាចប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូននោះនៅពេលណាក៏បាន(ក្នុងម៉ោងធ្វើការ)។

#### ក. ល័ក្ខខ័ណ្ឌនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ

ដើម្បីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន លុះត្រាតែមានល័ក្ខខ័ណ្ឌដូចខាងក្រោម៖

- ទោះបីប្រឹងប្រែងស្រាវជ្រាវរកលំនៅឋាន ឬទីសំណាក់របស់ភាគី ឬទីកន្លែងផ្សេងទៀត។ យ៉ាងណាក៏មិនអាចរកឃើញ។
- ដឹងពីទីកន្លែងដែលត្រូវបញ្ជូន ប៉ុន្តែការបញ្ជូនមិនអាចធ្វើបានទោះជាព្យាយាមបញ្ជូនតាមរបៀប នៃការបញ្ជូនដោយបង្គ្រប់កិច្ច និងការបញ្ជូនដោយទុកចោលក៏ដោយ។
- តុលាការមិនបានទទួលលិខិតបញ្ជាក់ ពីការបញ្ជូនពីក្រសួង ឬស្ថាប័នដែលមានសមត្ថកិច្ចនៅបរទេសក្នុងអឡុងពេល ៦ខែ ចាប់ពីពេលបញ្ជូននោះ។

---

[43] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥២ កថាខ័ណ្ឌទី២។

[44] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥៣។

- មានពាក្យសុំពីភាគី ដែលស្នើសុំឱ្យតុលាការធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ហើយត្រូវបានតុលាការអនុញ្ញាត។

ដើម្បីជៀសវាងការយឺតយ៉ាវតុលាការក៏អាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិបានទោះបីជាគ្មានពាក្យសុំក៏ដោយ។

ចំពោះការបញ្ជូនជាលើកទី២ តាមការផ្សាយជាសាធារណៈទៅភាគីដដែលត្រូវធ្វើឡើងដោយឆន្ទានុសិទ្ធិ។[45] ប្រសិនបើធ្លាប់បានបញ្ជូនទៅភាគីណាមួយតាមការបញ្ជូនតាមការផ្សាយជាសាធារណៈនោះការបញ្ជូនលើកក្រោយៗទៀតតុលាការអាចសម្រេចធ្វើការបញ្ជូនតាមពិធីផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិ។[46] ប៉ុន្តែចំពោះការបញ្ជូនទៅបរទេសត្រូវតែមានពាក្យសុំរបស់ភាគីរាល់លើកនៃការផ្សាយជាសាធារណៈ។ ឧទាហរណ៍ប្រសិនបើនៅក្នុងនីតិវិធីជំនុំជម្រះលើកទីមួយ និងនីតិវិធីជំនុំជម្រះបណ្តឹងលើទី២ តុលាការបានធ្វើកាបញ្ជូនទៅលោក "ក" ដោយវិធីនៃការបញ្ជូនតាមការផ្សាយជាសាធារណៈដោយឆន្ទានុសិទ្ធិ មិនចាំបាច់មានពាក្យសុំពីភាគីឡើយ។ ប៉ុន្តែប្រសិនបើលោក "ក" រស់នៅបរទេសត្រូវតែមានពាក្យសុំពីភាគីទើបអាចធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈបាន។

**ខ. របៀបបញ្ជូនតាមការផ្សាយជាសាធារណៈ**

ការបញ្ជូនតាមការផ្សាយជាសាធារណៈត្រូវធ្វើឡើងតាមវិធីដូចតទៅ៖

- ក្រឡាបញ្ជីត្រូវបិទប្រកាសនៅកន្លែងប្រកាសរបស់តុលាការ ឬកន្លែងដែលតុលាការទទួលស្គាល់ថាសមរម្យ ត្រូវប្រកាសថាក្រឡាបញ្ជីរក្សាទុកនៅឯកសារដែលត្រូវធ្វើការបញ្ជូន និងអាចប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូននោះនៅពេលណាក៏បាន។
- ចំពោះការបញ្ជូនដីកាកោះត្រូវបិទដីកាកោះនោះ នៅកន្លែងសម្រាប់បិទប្រកាសតែម្តង។
- តុលាការអាចចុះក្នុងរាជកិច្ច ឬក្នុងសារព័ត៌មានដោយផ្សាយថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ។
- ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈ ដែលត្រូវធ្វើនៅបរទេសក្រឡាបញ្ជីមិនចាំបាច់ផ្សាយក្នុងរាជកិច្ច ឬសារព័ត៌មានក៏បាន។ ដោយគ្រាន់តែជូនដំណឹងថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈរួចហើយ។[47]

[45] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥៥។
[46] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥៥ កថាខណ្ឌទី៤។
[47] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥៦។

**គ. អានុភាពនៃការបញ្ជូនតាមការផ្សាយជាសាធារណៈ**

ការបញ្ជូនតាមការផ្សាយជាសាធារណៈ និងមានអានុភាពនៅក្រោយអំឡុងពេលពីរសប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានបិទប្រកាសនោះ។ ក៏ប៉ុន្តែការបញ្ជូនតាមការផ្សាយសាធារណៈជាលើកទី២ និងមានអានុភាពនៅថ្ងៃបន្ទាប់នៃថ្ងៃបិទប្រកាសនោះ។ អានុភាពនៅទីនេះមានន័យថាការបញ្ជូនមានសុពលភាពហើយត្រូវចាត់ទុកថាអ្នកដែលត្រូវទទួលការបញ្ជូនបានទទួលការបញ្ជូននោះ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈដែលត្រូវធ្វើនៅបរទេស និងមានអានុភាពជាការបញ្ជូននៅក្រោយអទ្បុងពេល ៦ សប្តាហ៍បន្ទាប់ពីថ្ងៃបិទប្រកាស។[48]

**១.៣.២. របាយការណ៍នៃការបញ្ជូន**

នៅក្រោយពេលដែលបានប្រតិបត្តិការបញ្ជូនត្រឹមត្រូវតាមនីតិវិធីរួចរាល់ហើយ មន្ត្រីប្រតិបត្តិការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីការបញ្ជូននោះហើយផ្ញើទៅតុលាការ។ របាយការណ៍នៃការបញ្ជូនត្រូវតែសរសេរនៅចំណុចដូចជា៖[49]

- សញ្ញាណនៃរឿងក្តី និងឯកសារដែលបានធ្វើការបញ្ជូនត្រូវសរសេរអំពីឈ្មោះសំណុំរឿងលេខ និងការបរិច្ឆេទដែលបានចុះ ហើយក៏ត្រូវសរសេរ រាយឈ្មោះឯកសារដែលបានធ្វើការបញ្ជូននោះផងដែរ។
- ឈ្មោះជនដែលត្រូវទទួលការបញ្ជូន ដោយហេតុថាឯកសារនៃការបញ្ជូនត្រូវធ្វើទៅ ចំពោះបុគ្គលណាមួយច្បាស់លាស់ហេតុនេះហើយ ត្រូវសរសេរចង្អុលបង្ហាញឱ្យចំឈ្មោះអ្នកដែលត្រូវទទួលការបញ្ជូននោះ។
- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន។
- វិធីនៃការបញ្ជូននៅក្រោយពេលដែលបានធ្វើការបញ្ជូន មន្ត្រីប្រតិបត្តិការបញ្ជូនត្រូវសរសេរចង្អុលប្រាប់ពីវិធីដែលខ្លួនបានបញ្ជូនតាមវិធីដូចជាបញ្ជូនដោយជួបប្រទះ ឬទុកចោលជាដើម។
- ចំណាត់ការរបស់មន្ត្រីប្រតិបត្តិការបញ្ជូន ក្នុងករណីដែលជូនដែលត្រូវទទួលការបញ្ជូនមិនចេះអក្សរ ត្រូវសរសេរបញ្ជាក់ថាខ្លួនបានអានឱ្យជនមនុស្សស្តាប់ និងបានពន្យល់។
- ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដែលទទួលឯកសារ ការធ្វើបែបនេះ គឺដើម្បីបង្ការការប្រកែកថាមិនបានទទួលឯកសារដែលនាំឱ្យបាត់បង់ឯកសារហើយក៏ជាការបញ្ជាក់អំពីភាពត្រឹមត្រូវនៃការបញ្ជូនផងដែរ។
- ហេតុការណ៍ដែលមិនព្រមទទួលការបញ្ជូន ជនដែលត្រូវទទួលការបញ្ជូន ឬអ្នកដែលត្រូវទទួលការប្រគល់ឯកសារបញ្ជូនដោយបង្គ្រប់កិច្ចប្រកែកមិនព្រមទទួលក្នុងករណីដែលជនដែលត្រូវទទួលការបញ្ជូន ឬអ្នកដែរត្រូវទទួលការប្រគល់ឯកសារបញ្ជូន ដោយបង្គ្រប់កិច្ចប្រកែកមិនព្រមទទួលត្រូវសរសេរអំពីមូលហេតុនៃការប្រកែកនោះ។

[48] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥៧។
[49] ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ២៥៤។

- ហេតុការណ៍នៅក្នុងករណីដែរបានធ្វើការបញ្ជូនដោយបង្គ្រប់កិច្ច ឬបញ្ជូនដោយទុកចោលត្រូវសរសេរអំពីមូលហេតុដែលធ្វើការបញ្ជូនតាមការបញ្ជូនដោយបង្គ្រប់កិច្ច ឬការបញ្ជូនដោយទុកចោល។
- ហត្ថលេខារបស់អ្នកដែលបានប្រតិបត្តិការបញ្ជូន។

ក្នុងករណីដែលបានព្យាយាមធ្វើការបញ្ជូនតែមិនអាចសម្រេចបាន មន្ត្រីទទួលបន្ទុកការបញ្ជូនត្រូវធ្វើរបាយការណ៍អំពីហេតុការណ៍នោះ និងសរសេរអំពីវិធីនៃការបញ្ជូន និងចុះហត្ថលេខារបស់អ្នកដែរបានប្រតិបត្តិការបញ្ជូនហើយដាក់ជូនទៅតុលាការ។ ការបញ្ជូន គឺជានីតិវិធីដ៏មានសារសំខាន់ ដល់ដំណើរការក្នុងដោះស្រាយវិវាទរដ្ឋប្បវេណី ដែលអាចឱ្យភាគីទាំងសងខាង បានដឹងអំពីដំណើរការនៃរឿងក្តីនៅតុលាការ និងអាចចូលរួមតាមកាកោះហៅ ហើយជៀសវាងអំពីការជំនុំជម្រះក្តីដោយមិនមានវត្តមានភាគីណាមួយ ដែលនាំឱ្យខូចខាត ឬបាត់បង់ប្រយោជន៍របស់ខ្លួន។

# ផ្នែកទី២ ៖ ការជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី១ នៃតុលាការកំពូល

**ការជំនុំជម្រះបណ្តឹងសាទុក្ខ** គឺជាការជំនុំជម្រះលើអង្គច្បាប់ ដែលតុលាការកំពូលវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយក្នុងនាមជាតុលាការនៃបណ្តឹងសាទុក្ខ ហេតុដូច្នេះនៅក្នុងការជំនុំជម្រះបណ្តឹងសាទុក្ខ តុលាការធ្វើការពិនិត្យមើលជាថ្មីម្តងទៀតទៅលើសាលក្រម ឬសាលដីកាដើម ដោយផ្អែកលើធនធានសម្រាប់ការវិនិច្ឆ័យនៅក្នុងសាលក្រម ឬសាលដីការដើមនោះ។ តុលាការនៃបណ្តឹងសាទុក្ខមិនធ្វើការទទួលស្គាល់នូវអង្គហេតុឡើងវិញទេ គឺគ្រាន់តែវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះអង្គហេតុ ដោយផ្អែកលើការទទួលស្គាល់នូវអង្គហេតុដោយតុលាការដើម។[50] ក្នុងន័យនេះជាគោលការណ៍ តុលាការនៃបណ្តឹងសាទុក្ខ ត្រូវចងដោយអង្គហេតុដែលត្រូវទទួលស្គាល់ជាស្ថាពរ ដោយស្របច្បាប់ក្នុងសាលក្រម សាលដីកាដើម។[51] ប៉ុន្តែ ចំពោះចំណុចដែលតុលាការ ស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួនមិនមានអានុភាពឡើយ។[52]

នៅដំណាក់កាលជំនុំជម្រះលើកចុងក្រោយ ត្រូវគោរពតាមគោលការណ៍នៃការជំនុំជម្រះបណ្តឹងសាទុក្ខ និងមានការទាញហេតុផលដោយផ្ទាល់មាត់ចំនួនពីរលើក។

## ២.១. គោលការណ៍នៃការជំនុំជម្រះបណ្តឹងសាទុក្ខ

ជាគោលការណ៍ដើម្បីធ្វើការវិនិច្ឆ័យ និងចេញសាលដីកានៃបណ្តឹងសាទុក្ខ តុលាការត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់ លើកលែងតែករណីដែលតុលាការ ច្រានចោលបណ្តឹងសាទុក្ខដោយមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់។ ការទាញហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងត្រឹមទំហំដែលភាគីបានទាមទារឱ្យផ្លាស់ប្តូរក្នុងសាលក្រម ឬសាលដីកានៃតុលាការដើមតែប៉ុណ្ណោះ។ ការទាញហេតុផលដោយផ្ទាល់មាត់ត្រូវធ្វើតែលើចំណុចណាដែលបានធ្វើការឧបាស្រ័យតែប៉ុណ្ណោះ ចំពោះចំណុចណាដែលភាគីមិនបានធ្វើឧបាស្រ័យទេ តុលាការមិនអាចធ្វើការវិនិច្ឆ័យបានទេ។ ការកំណត់បែបនេះ គឺទាញចេញពីគោលការណ៍ហាមឃាត់មិនឱ្យផ្លាស់ប្តូរដែលធ្វើឱ្យខូចប្រយោជន៍ភាគី មានន័យថាការផ្លាស់ប្តូរសាលក្រម ឬសាលដីការបស់តុលាការដើម អាចធ្វើបានត្រឹមតែកម្រិតដែលបានបាស្រ័យបណ្តឹងសាទុក្ខតែប៉ុណ្ណោះ។ ប៉ុន្តែប្រសិនបើមានពាក្យបណ្តឹងសាទុក្ខបន្ទាប់បន្សំ ការវិនិច្ឆ័យរបស់តុលាការនៃបណ្តឹងសាទុក្ខក៏ត្រូវតែប្រែប្រួលតាមការទាមទាមនោះដែរ។

[50] មេធាវី ហេងប៉ូ៉, *មេរៀននីតិវិធីរដ្ឋប្បវេណី* (ឆ្នាំសិក្សា២០២៣ ២០២៤), ទំព័រ១១១។

[51] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៩៦។

[52] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា២៩៧។

## ២.២. ការទាញហេតុផលដោយផ្ទាល់មាត់បណ្តឹងសាទុក្ខលើកទី១ តុលាការកំពូល

តុលាការនៃបណ្តឹងសាទុក្ខ ត្រូវធ្វើការជំនុំជម្រះលើកចុងក្រោយចំពោះសាលក្រម ឬសាលដីកាដើម ដែលការជំនុំជម្រះបណ្តឹងសាទុក្ខ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការទាញហេតុផលដោយផ្ទាល់មាត់។

### ២.២.១. សមាសភាពចៅក្រមជំនុំជម្រះ

ក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ករណីបណ្តឹងសាទុក្ខលើកទី១ មានសមាសភាពចៅក្រមជំនុំជម្រះពោលគឺ សភារដ្ឋប្បវេណីនៃតុលាការកំពូល មានសមត្ថកិច្ចជំនុំជម្រះលើបណ្តឹងសាទុក្ខ ចំពោះសាលដីកាផ្នែករដ្ឋប្បវេណីរបស់សាលាឧទ្ធរណ៍ ឬសាលក្រមរដ្ឋប្បវេណីសាលាដំបូង។ ដូច្នេះការជំនុំជម្រះក្តីត្រូវធ្វើឡើងដោយមានចៅក្រម ០៥ រូប ក្នុងនោះមានចៅក្រម ០១ រូប ត្រូវបានចាត់តាំងឱ្យធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ ដើម្បីធ្វើជាអ្នកដឹកនាំកិច្ចដំណើរការនៃនីតិវិធី។[53]

### ១.២.២. សកម្មភាពទាញហេតុផលដោយផ្ទាល់មាត់

នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ របស់តុលាការនៃបណ្តឹងសាទុក្ខ គឺជាការវិនិច្ឆ័យតែទៅលើអង្គច្បាប់ប៉ុណ្ណោះ។ តុលាការនៃបណ្តឹងសាទុក្ខ ធ្វើការពិនិត្យ និងវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីកាចុងក្រោយលើកាអនុវត្តច្បាប់ប៉ុណ្ណោះ។ ការវិនិច្ឆ័យនេះ គឺផ្អែកទៅលើការអះអាងរបស់ភាគី និងភស្តុតាងដែលបានដាក់នៅតុលាការដើម តាមរយៈការវិនិច្ឆ័យលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវក្នុងការអនុវត្តច្បាប់ចំពោះអង្គហេតុដែលបានទទួលស្គាល់នៅតុលាការដើម ហើយតុលាការនៃបណ្តឹងសាទុក្ខមិនទទួលស្គាល់អង្គហេតុឡើងវិញទេ។ ការវិនិច្ឆ័យលើអង្គច្បាប់របស់តុលាការនៃបណ្តឹងសាទុក្ខ គឺដើម្បីឱ្យមានឯកភាពគ្នារបស់តុលាការថ្នាក់ក្រោមក្នុងការបកស្រាយច្បាប់ និងអនុវត្តច្បាប់។ ដោយហេតុថាសេចក្តីសម្រេចនេះ អាចក្លាយទៅជាយុត្តិសាស្ត្រសម្រាប់ឱ្យតុលាការថ្នាក់ក្រោមធ្វើការអនុវត្តតាម។

#### ក. ដំណើរការសកម្មភាពទាញហេតុផលដោយផ្ទាល់មាត់

សកម្មភាពទាញហេតុផលដោយផ្ទាល់មាត់ត្រូវបានចាប់ផ្តើមដោយ ប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រកាសបើកនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ លើបណ្តឹងសាទុក្ខ ដោយមានប្រកាសពីសមាសភាពនៃសមាជិកក្រុមប្រឹក្សាជំនុំជម្រះ ដែលបានចូលរួមធ្វើការវិនិច្ឆ័យ ក្រឡាបញ្ជី និងតំណាងអយ្យការ (ករណីមានតំណាងអយ្យការចូលរួម)។ បន្ទាប់មកប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រកាស អំពីសញ្ញាណនៃសំណុំរឿងដែលត្រូវធ្វើការជំនុំជម្រះ ដោយបង្ហាញឈ្មោះដើមបណ្តឹងសាទុក្ខ មេធាវីរបស់ដើមបណ្តឹងសាទុក្ខ ចុងបណ្តឹងសាទុក្ខ មេធាវីរបស់ចុងបណ្តឹងសាទុក្ខ តតិយជន និងកម្មវត្ថុនៃបណ្តឹងសាទុក្ខ។ ក្រោយមកប្រធានក្រុមប្រឹក្សាជំនុំជម្រះ បង្គាប់

[53] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៥៩ និងមាត្រា៦៥។

ឱ្យ ក្រឡាបញ្ជីរាយការណ៍ អំពីវត្តមានរបស់ជនដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង។ ប្រធានក្រុមប្រឹក្សាជំនុំជម្រះបង្គាប់ឱ្យចៅក្រម ទទួលបញ្ជាអានរបាយការណ៍នៃសំណុំរឿងដោយមានរៀបរាប់អំពី ការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះរបស់ប្រធានតុលាការកំពូល ឈ្មោះ និងអាសយដ្ឋានរបស់គូភាគី អ្នកតំណាងរបស់គូភាគី (ករណីមានអ្នកតំណាង) តតិយជនដែលពាក់ព័ន្ធ កម្មវត្ថុនៃបណ្ដឹងសាទុក្ខ អង្គហេតុ និងដំណើរការនៃនីតិវិធីព្រមទាំងសេចក្ដីសម្រេចរបស់តុលាការថ្នាក់ក្រោម ទម្រង់ច្បាប់នៃបណ្ដឹងសាទុក្ខ លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ និងឯកសារត្រៀមដែលចុងបណ្ដឹងសាទុក្ខ បានដាក់មកតុលាការជាលើកដំបូង។ ក្រោយពីចៅក្រមទទួលបញ្ជាអានរបាយការណ៍ចប់ ប្រធានក្រុមប្រឹក្សាជំនុំជម្រះសួរយោបល់ តំណាងមហាអយ្យការ ចំពោះសំណុំរឿង (ករណីមានតំណាងមហាអយ្យការចូលរួម)។

### ខ. នីតិវិធីពិនិត្យមូលហេតុនៃបណ្ដឹងសាទុក្ខ

ប្រធានក្រុមប្រឹក្សាអញ្ជើញដើមបណ្ដឹងសាទុក្ខ មកឈរពីមុខតុលាការឱ្យប្រាប់អំពីសាវតាជាតិរបស់ខ្លួន មូលហេតុនៃការប្ដឹងសាទុក្ខចំពោះសាលដីកាដើម ឬសាលក្រមដើម និងឱ្យធ្វើសេចក្ដីថ្លែងការបន្ថែមលើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខដែលខ្លួនបានដាក់ជូនមកតុលាការ។ បន្ទាប់មកប្រធានក្រុមប្រឹក្សាអញ្ជើញចុងបណ្ដឹងសាទុក្ខ មកឈរពីមុខតុលាការឱ្យប្រាប់អំពីសាវតារបស់ខ្លួន និងសេចក្ដីថ្លែងការណ៍តបទៅនឹងសេចក្ដីថ្លែងការដើមបណ្ដឹងសាទុក្ខ។ ប្រសិនបើមានភាគីណាមួយអវត្តមាន ឬភាគីទាំងពីរអវត្តមាន ប្រធានក្រុមប្រឹក្សាឱ្យក្រឡាបញ្ជី អានមូលហេតុនៃបណ្ដឹងសាទុក្ខ ឬឯកសារត្រៀមរបស់ភាគីដែលអវត្តមាននោះ។

ប្រធានក្រុមប្រឹក្សាអាចអនុញ្ញាតឱ្យភាគីធ្វើការអះអាងបន្ថែមទៀតបាន បើយល់ឃើញថាចាំបាច់ ក្រោយមកប្រធានក្រុមប្រឹក្សាអញ្ជើញមេធាវីរបស់ដើមបណ្ដឹងសាទុក្ខ ធ្វើសេចក្ដីថ្លែងការណ៍ចុងក្រោយ។ ពេលមេធាវីដើមបណ្ដឹងសាទុក្ខធ្វើសេចក្ដីថ្លែងការណ៍ចប់ ប្រធានក្រុមប្រឹក្សាអញ្ជើញមេធាវីចុងបណ្ដឹងសាទុក្ខ ធ្វើសេចក្ដីថ្លែងការណ៍ចុងក្រោមម្ដង។ ពេលមេធាវីរបស់គូភាគីបានធ្វើសេចក្ដីថ្លែងការណ៍ចប់ហើយ ប្រធានក្រុមប្រឹក្សាជំនុំជម្រះប្រកាសបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយថយទៅពិភាក្សាក្នុងបន្ទប់របស់តុលាការ។

នៅដំណាក់កាលប្រកាសសាលដីកានេះ សំឡេងស្នូរកណ្ដឹងរោទិ៍ម្ដងតំណាងអយ្យការ ចូលក្នុងបន្ទប់ជំនុំជម្រះ (ករណីមានតំណាងមហាអយ្យការចូលរួមសវនាការ) ស្នូរកណ្ដឹងរោទិ៍ពីរដង ក្រុមប្រឹក្សាចូលបន្ទប់ជំនុំជម្រះ ហើយប្រធានក្រុមប្រឹក្សាបង្គាប់ឱ្យដើមបណ្ដឹងសាទុក្ខ និងចុងបណ្ដឹងសាទុក្ខ មកឈរនៅចំពោះមុខតុលាការ រួចប្រធានក្រុមប្រឹក្សា ឬចៅក្រមណាម្នាក់ប្រកាសសាលដីកា ។ ក្រោយពេលប្រកាសសាលដីកាប្រធានក្រុមប្រឹក្សាប្រកាសបិទសវនាការ។

## ផ្នែកទី៣ ៖ ការទាញហេតុផលដោយផ្ទាល់មាត់បណ្តឹងសាទុក្ខលើកទី២

ការទាញហេតុផលដោយផ្ទាល់មាត់ករណីបណ្តឹងសាទុក្ខលើកទី២ គឺជាករណីដែលតុលាការនៃបណ្តឹងសាទុក្ខបានបដិសេធនៃសាលក្រមដើម ហើយបានបញ្ជូនរឿងក្តីនោះត្រឡប់ទៅតុលាការដើមវិញ ឬផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា ដើម្បីឱ្យធ្វើការជំនុំជម្រះរឿងក្តីនោះម្តងទៀត បន្ទាប់មកនៅពេលដែលតុលាការដើមដែលទទួលការបញ្ជូនរឿងក្តីត្រឡប់មកវិញ ឬតុលាការដែលបានទទួលការផ្ទេររឿងក្តីនោះបានចេញសាលដីកា ហើយបើមានភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ ហើយបានប្តឹងសាទុក្ខម្តងទៀតនោះ នីតិវិធីតុលាការនៃបណ្តឹងសាទុក្ខលើកទី២ នឹងធ្វើការជំនុំជម្រះដោយសភាពេញអង្គ។

### ៣.១. សមាសភាពចៅក្រមជំនុំជម្រះ

ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខ បានបដិសេធនូវសាលដីកាដើម ហើយបានបញ្ជូនរឿងក្តីនោះត្រឡប់ទៅតុលាការដើមវិញ ឬផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា ដើម្បីធ្វើការជំនុំជម្រះរឿងក្តីនោះម្តងទៀត បន្ទាប់មកនៅពេលដែលតុលាការដើម បានទទួលការបញ្ជូនរឿងក្តីត្រឡប់មកវិញ ឬតុលាការដែលបានទទួលការផ្ទេររឿងក្តីនោះបានចេញសាលដីកា ហើយបើមានភាគីណាមួយមិនសុខចិត្តនឹងសេចក្តីសម្រេចនោះ ហើយបានប្តឹងសាទុក្ខម្តងទៀតពេលនោះ នីតិវិធីតុលាការនៃបណ្តឹងសាទុក្ខនឹងធ្វើការជំនុំជម្រះដោយសភាពេញអង្គ។ សភាពេញអង្គត្រូវបង្កើតឱ្យមានដំណើរការដោយដីកាសម្រេចរបស់ប្រធានតុលាការកំពូល ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខលើកទី២ និងបណ្តឹងជំនុំជម្រះសាជាថ្មី ក្នុងករណីដែលមានការស្នើសុំឱ្យមានពិនិត្យ និងសម្រេចឡើងវិញ ចំពោះរឿងក្តីណាមួយពីព្រះមហាក្សត្រដែលជាព្រះប្រធានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមរយៈរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ សភាពេញអង្គប្រព្រឹត្តទៅតាមការកោះអញ្ជើញរបស់ប្រធានតុលាការកំពូល សភានេះត្រូវមានសមាសភាពចៅក្រមយ៉ាងតិច ០៩ (ប្រាំបួន) រូបដែលមានចៅក្រមជាតំណាងនៃសភាទាំងអស់នៃតុលាការកំពូល ហើយសភាពេញអង្គដំណើរការក្រោមអធិបតីភាពរបស់ប្រធានតុលាការកំពូល។[54]

### ៣.២. សកម្មភាពនៃការទាញហេតុផលដោយផ្ទាល់មាត់

សកម្មភាពទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងករណីបណ្តឹងសាទុក្ខលើកទីពីរនេះ គឺធ្វើទៅតាមលំដាប់លំដោយដូចគ្នានឹងសកម្មភាពទាញហេតុផលដោយផ្ទាល់មាត់ នៅក្នុងបណ្តឹងសាទុក្ខលើកដំបូងដែរ ប៉ុន្តែអាចមានសាក្សី និងអ្នកជំនាញចូលរួមក្នុងសវនាការដែរ ដោយប្រធានក្រុមប្រឹក្សាអាចអញ្ជើញសាក្សី និងអ្នកជំនាញនោះមកឈរមុខតុលាការ ដើម្បីឱ្យអ្នកទាំងនោះជួយបំភ្លឺដល់រឿងក្តី ដើម្បីឱ្យតុលាការងាយស្រួលក្នុងការ

[54] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤, មាត្រា៦២។

វិនិច្ឆ័យ និងចេញសាលដីកា។ ករណីមានបន្ថែមសាក្សី និងអ្នកជំនាញនេះដោយសារតែបណ្តឹងសាទុក្ខលើកទីពីរនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការពិនិត្យឡើងវិញទាំងអង្គហេតុ និងអង្គច្បាប់។

## ផ្នែកទី៤ ៖ ការបញ្ចប់បណ្តឹងសាទុក្ខ នៅតុលាការកំពូល

បន្ទាប់ពីការធ្វើការជំនុំជម្រះដោយទាញហេតុផលដោយផ្ទាល់មាត់រួច តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបញ្ចប់បណ្តឹងសាទុក្ខដោយមានពីរយ៉ាងគឺ ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ ឬការបញ្ចប់បណ្តឹងសាទុក្ខដោយឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ។

### ៤.១. ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ

ការបញ្ចប់បណ្តឹងសាទុក្ខដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការ អាចធ្វើឡើងក្នុងទម្រង់ពីរយ៉ាងគឺ អាចជាការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ ឬការបញ្ចប់ដោយសកម្មភាពភាគី។[55]

#### ៤.១.១. ការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិ

ការបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិមានន័យថា កាលណាភាគីមួយបានទទួលមរណភាពហើយគ្មានអ្នកណាទទួលបន្តនូវសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងនាំឱ្យបណ្តឹងនោះត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិ។ តាមធម្មតាបើទោះបីជា មានភាគីណាម្ខាងទទួលមរណភាពក៏ដោយ ក៏សន្តតិជនរបស់ភាគីនោះនឹងត្រូវទទួលបន្តនូវនីតិវិធីនៃបណ្តឹងដែលបានធ្វើពីមុនមក ហើយនីតិវិធីបណ្តឹងសាទុក្ខនោះមិនត្រូវបានបញ្ចប់ទេ។ ក្នុងករណីដែលសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងបានរលត់ដោយសារ ការរួមបញ្ចូលគ្នានៃនីតិបុគ្គលនាំឱ្យសិទ្ធិ ឬកាតព្វកិច្ចដែលជាកម្មវត្ថុនៃបណ្តឹងត្រូវធ្លាក់ទៅលើបុគ្គលតែម្នាក់ ហើយដើមបណ្តឹងសាទុក្ខ និងចុងចម្លើយសាទុក្ខបានក្លាយទៅជាបុគ្គលតែមួយដោយសារតែភាគីណាម្ខាងបានទទួលនូវឋានៈ តាមផ្លូវបណ្តឹងរបស់ភាគីម្ខាងទៀតដោយសារការរួមបញ្ចូលគ្នានៃនីតិបុគ្គល ដូច្នេះតុលាការនឹងចេញសាលដីកាបញ្ចប់បណ្តឹងដោយស្វ័យប្រវត្តិដោយសារតែមានភាគីជាបុគ្គលតែមួយ។[56]

#### ៤.១.២. ការបញ្ចប់បណ្តឹងដោយសកម្មភាពភាគី

ការបញ្ចប់បណ្តឹងដោយសកម្មភាពរបស់ភាគី ក្នុងនេះជាសកម្មភាពនៃការដកពាក្យបណ្តឹងការលះបង់ ឬការទទួលស្គាល់ការទាមទារ និងការសះជាតាមផ្លូវបណ្តឹងរបស់ភាគីនឹងធ្វើឱ្យសកម្មភាពនៃបណ្តឹងត្រូវបានបញ្ចប់ផងដែរ។

---

[55] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៨៦ និងមាត្រា ១៧៩។

[56] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៨៦ និងមាត្រា ១៧៣។

### ៤.១.២.១. ការដកពាក្យបណ្តឹង

ការដកពាក្យបណ្តឹង ទោះបីជានីតិវិធីបណ្តឹងកំពុងដំណើរការក៏ដោយ ក៏ដើមបណ្តឹងសាទុក្ខអាចធ្វើការដកពាក្យបណ្តឹងទាំងអស់ ឬមួយផ្នែកបានដែររហូតដល់ពេលតុលាការនៃបណ្តឹងចេញសាលដីកាចុងក្រោយ។[57] ដោយហេតុថាបណ្តឹង ជាសកម្មភាពរបស់ដើមបណ្តឹងក្នុងការទាមទារឱ្យតុលាការនៃបណ្តឹងសាទុក្ខចេញសេចក្តីសម្រេចលុបចោល ឬកែប្រែសាលក្រម ឬសាលដីកាដើម ដូច្នេះក្នុងការដកពាក្យបណ្តឹងត្រូវធ្វើឡើងតាមឆន្ទៈរបស់ដើមបណ្តឹងប៉ុណ្ណោះ ហេតុនេះចុងបណ្តឹងសាទុក្ខ ពុំមានសិទ្ធិដកពាក្យបណ្តឹងឡើយ។ ក៏ប៉ុន្តែក្រោយពីចុងបណ្តឹងសាទុក្ខ បានដាក់ឯកសាត្រៀមតាមការបង្គាប់របស់តុលាការ ឬបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់រួចហើយ ការដកពាក្យបណ្តឹងសាទុក្ខដោយផ្អែកតែទៅលើឆន្ទៈរបស់ដើមបណ្តឹងសាទុក្ខពុំមានអានុភាពឡើយ លើកលែងតែមានការយល់ព្រមពីចុងបណ្តឹងសាទុក្ខផងដែរ ពីព្រោះថាចុងបណ្តឹងសាទុក្ខបានឆ្លើយតបនឹងការទាមទាររបស់ដើមបណ្តឹងសាទុក្ខ ហើយចុងបណ្តឹងសាទុក្ខក៏មានផលប្រយោជន៍ក្នុងការទទួលបានសាលដីកាឈ្នះក្តីដែរ។[58] ចំណែកឯលក្ខខ័ណ្ឌនៃការដកពាក្យបណ្តឹងវិញនោះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ប៉ុន្តែការដកពាក្យបណ្តឹងរបស់ដើមបណ្តឹងសាទុក្ខ អាចធ្វើឡើងដោយផ្ទាល់មាត់ក៏បាន នៅកាលបរិច្ឆេទការទាញហេតុផលដោយផ្ទាល់មាត់។ នៅពេលដែលមានការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវចុះអំពីការដកពាក្យបណ្តឹងនោះក្នុងកំណត់ហេតុនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើម្បីកុំឱ្យមានវិវាទនៅពេលក្រោយ។

ប្រសិនបើការដកពាក្យបណ្តឹងធ្វើឡើងជាលាយលក្ខណ៍អក្សរ តុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនពាក្យបណ្តឹងនោះទៅចុងបណ្តឹងសាទុក្ខ។ បើចុងបណ្តឹងសាទុក្ខ មិនបណ្តឹងក្នុងអំឡុងពេល ២សប្តាហ៍ បន្ទាប់ពីបានទទួលការបញ្ជូនលិខិតដកពាក្យបណ្តឹងទេ ត្រូវបានចាត់ទុកថាចុងបណ្តឹងសាទុក្ខបានយល់ព្រមនឹងការដកពាក្យបណ្តឹងនេះ។ បើដើមបណ្តឹងសាទុក្ខ ធ្វើការដកពាក្យបណ្តឹងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ប៉ុន្តែចុងបណ្តឹងសាទុក្ខបានអនុវត្តមាននៅកាលបរិច្ឆេទនោះ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបញ្ជូនឯកសារចម្លងនៃកំណត់ហេតុ ដែលបានចុះអំពីការដកពាក្យបណ្តឹងសាទុក្ខមិនបានធ្វើការតវ៉ាទេ ត្រូវចាត់ទុកថាខ្លួនបានយល់ព្រមចំពោះការដកពាក្យបណ្តឹងសាទុក្ខផងដែរ។ ប៉ុន្តែបើដើមបណ្តឹងសាទុក្ខធ្វើការដកពាក្យបណ្តឹងសាទុក្ខដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលភាគីចុងបណ្តឹងសាទុក្ខមានវត្តមាននៅកាលបរិច្ឆេទនោះដែរ បើចុងបណ្តឹងសាទុក្ខមិនបានតវ៉ាក្នុងអំឡុងពេល ០២សប្តាហ៍ គិតពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ នោះក៏ត្រូវចាត់ទុកថាចុងបណ្តឹងបានយល់ស្រប ចំពោះការដកពាក្យបណ្តឹងនោះដែរ។ ត្រូវចាត់ទុកថាដកពាក្យបណ្តឹងផងដែរ ក្នុងករណីដែលភាគីទាំងសងខាងមិនបាន

[57] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៦៩ និងមាត្រា ២៨៦។

[58] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២១៧ កថាខណ្ឌ១។

បង្ហាញខ្លួននៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ហើយភាគីទាំងសងខាងមិនបានដាក់ពាក្យសុំឱ្យតុលាការនៃបណ្តឹងសាទុក្ខកំណត់កាលបរិច្ឆេទជាថ្មីម្តងទៀត ក្នុងអំឡុងពេល ១ខែ ទេនោះ ក៏ត្រូវចាត់ទុកថាបានដកពាក្យបណ្តឹងសាទុក្ខដែរ។ ហើយបើភាគីទាំងសងខាងមិនបានបង្ហាញខ្លួននៅកាលបរិច្ឆទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីរដងជាប់គ្នា ក៏ត្រូវចាត់ទុកថាបានដកពាក្យបណ្តឹងសាទុក្ខផងដែរ។[59] ដូចនេះការដកពាក្យបណ្តឹងសាទុក្ខអាចដកបានតែមួយផ្នែក ឬទាំងមូលនៅពេលដែលមានការដកពាក្យបណ្តឹងនោះត្រូវបានធ្វើឡើង ផ្នែកដែលត្រូវបានដក ឬបណ្តឹងទាំងមូលត្រូវបានចាត់ទុកថាមិនបានចាត់តាំងពីដំបូង ហើយរឿងក្តីត្រូវបានរលត់ដោយអានុភាពប្រតិសកម្ម។ ពោល គឺត្រូវបានចាត់ទុកថាតុលាការមិនបានចាត់តាំងបណ្តឹងនោះតាំងពីដំបូងមកម្ល៉េះ ចំណែកសកម្មភាពរបស់តុលាការ និងភាគីដែលបានធ្វើកន្លងមករហូតដល់ពេលដកពាក្យបណ្តឹងសាទុក្ខក៏ត្រូវបានបាត់បង់អានុភាពដែរ។ ប្រសិនបើមានការដកពាក្យបណ្តឹងសាទុក្ខ នោះនាំឱ្យមានអានុភាពនៃសាលដីកាដើម ឬសាលក្រមដើមត្រូវចូលជាស្ថាពរ ក្នុងអំឡុងពេលសម្រាប់ធ្វើបណ្តឹងសាទុក្ខកន្លងផុតទៅ ក៏ប៉ុន្តែដើមបណ្តឹងសាទុក្ខមិនអាចធ្វើការដកពាក្យបណ្តឹងសាទុក្ខបានឡើយ បើតុលាការនៃបណ្តឹងសាទុក្ខបានប្រកាសសាលដីកា។ យ៉ាងណាមិញនៅពេលដែលដើមបណ្តឹងសាទុក្ខបានធ្វើការដកពាក្យបណ្តឹងនៅមុនពេលចប់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដើមបណ្តឹងសាទុក្ខអាចដាក់ ឬសុំតុលាការនៃបណ្តឹងសាទុក្ខ សងវិញនៅចំនួនពាក់កណ្តាលនៃពន្ធដាក់ពាក្យបណ្តឹងដែលខ្លួនបានបង់ទៅតុលាការរួចហើយ។[60]

### ៤.១.២.២. ការលះបង់ ឬការទទួលស្គាល់នូវការទាមទារ

#### ក. និយមន័យ

ការលះបង់ ឬការទទួលស្គាល់នូវការទាមទារជាសេចក្តីថ្លែងការណ៍តាមផ្លូវបណ្តឹងដែលភាគីម្ខាងទទួលស្គាល់ភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃការទាមទារ ហើយវិវាទទាំងសងខាងត្រូវដោះស្រាយដោយសេចក្តីថ្លែងការណ៍នេះ សកម្មភាពទាំងនេះនាំឱ្យបណ្តឹងត្រូវបានបញ្ចប់ដោយមិនចាំបាច់សាលដីកាទេ។

#### ខ. លក្ខខ័ណ្ឌចាំបាច់នៃការលះបង់ ឬការទទួលស្គាល់នូវការទាមទារ

ចំពោះលក្ខខ័ណ្ឌចាំបាច់ក្នុងការទទួលស្គាល់នូវការទាមទារ ភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹង។

---

[59] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២១៩។

[60] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៨៦ និងមាត្រា ២៦៩។

**គ. អានុភាពនៃការលះបង់ ឬការទទួលស្គាល់នូវការទាមទារ**

យ៉ាងណាមិញចំពោះអានុភាពនៃការបោះបង់ ឬការទទួលស្គាល់នៅការទាមទារតុលាការនៃបណ្តឹងសាទុក្ខត្រូវពិនិត្យអំពីល័ក្ខខ័ណ្ឌនៃបណ្តឹង បើឃើញថាភាគីមានល័ក្ខខ័ណ្ឌគ្រប់គ្រាន់ក្នុងការលះបង់ ឬទទួលស្គាល់នូវការទាមទារ ក្រឡាបញ្ជីត្រូវចុះក្នុងការកំណត់ហេតុ នោះនាំឱ្យបណ្តឹងត្រូវបានបញ្ចប់ ហើយកំណត់ហេតុនោះមានអានុភាពដូចគ្នានឹងដីកាស្ថាពរដែរ។[61]

**៤.១.២.៣. ការសះជាតាមផ្លូវបណ្តឹង**

**ក. និយមន័យ**

ការសះជាតាមផ្លូវបណ្តឹង គឺជាសកម្មភាពមួយដែលដើមបណ្តឹងសាទុក្ខ និងចុងបណ្តឹងសាទុក្ខបានធ្វើការសម្រុះសម្រួលគ្នាបញ្ចប់នូវនីតិវិធីបណ្តឹង ដោយផ្លូវបង្ហាញខ្លួននៅចំពោះមុខតុលាការនៃបណ្តឹងសាទុក្ខនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។

**ខ. ល័ក្ខខ័ណ្ឌចាំបាច់នៃការសះជាតាមផ្លូវបណ្តឹង**

ចំពោះល័ក្ខខ័ណ្ឌចាំបាច់នៃការសះជាតាមផ្លូវបណ្តឹង ក៏ភាគីចាំបាច់ត្រូវតែជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្តឹងសាទុក្ខ ដូច្នេះបើមានភាគីណាមួយជាបុគ្គលដែលត្រូវបានកម្រិតសមត្ថភាពបានធ្វើការសះជានោះពុំមានអានុភាពឡើយ។ អានុភាពនៃការសះជា មានអានុភាពបញ្ចប់បណ្តឹងដោយការសះជា ដែលបានកត់ត្រានៅក្នុងកំណត់ហេតុ ហើយលទ្ធផលនៃការសះជាតាមផ្លូវបណ្តឹងនេះនាំឱ្យនីតិវិធីនៃបណ្តឹងសាទុក្ខត្រូវបានបញ្ចប់ផងដែរ និងមានអានុភាពដូចគ្នាផងដែរនឹងសាលដីកាស្ថាពរ។[62] ប្រសិនបើក្នុងកំណត់ហេតុនេះមានចុះ អំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកជាក់ស្តែង ដោយមានការកំណត់ពេលអនុវត្ត ដូច្នេះកំណត់ហេតុសះជាមានអានុភាពអនុវត្តក្លាយទៅជាលិខិតអនុវត្ត។ ប៉ុន្តែអានុភាពអាជ្ញាអស់ជំនុំ ជាលក្ខណៈសារធាតុមិនមានឡើយ ទោះបីជាកំណត់ហេតុសះជាមានអានុភាពដូចគ្នានឹងសាលដីកាស្ថាពរក៏ដោយ ដោយសារតែការសះជាតាមផ្លូវបណ្តឹង គឺជាការបញ្ចប់វិវាទដែលមានខ្លឹមសារនៃទំនាក់ទំនងគតិយុត្តផ្អែកលើការព្រមព្រៀងរបស់ភាគី ដែលមានលក្ខណៈខុសពីសាលដីកាដែលធ្វើការសម្រេចចិត្តដោយផ្អែកលើភស្តុតាងដែលច្បាប់អនុវត្តចំពោះអង្គហេតុនោះ។ បើការសះជាតាមផ្លូវបណ្តឹងមានវិការៈ ភាគីអាចអះអាងអំពីមោឃភាព ឬការលុបចោលការសះជា នោះនីតិវិធីនៃការដោះស្រាយជម្លោះនេះមិនមែនជាការសុំជំនុំជម្រះសាជាថ្មីដូចករណីសាលដីកាទេ គឺគ្រាន់តែជាការស្នើសុំឱ្យតុលាការនៃបណ្តឹងសាទុក្ខ កំណត់នូវកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់សាជាថ្មីប៉ុណ្ណោះ។ បើសិនជាមានពាក្យសុំឱ្យតុលាការនៃបណ្តឹងសាទុក្ខត្រូវកំណត់នូវកាលបរិច្ឆេតជាថ្មី ដោយមានមូលហេតុមានវិការៈ

[61] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២២២។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ៣៥០។

ក្នុងការសះជា។ បើការវិនិច្ឆ័យឃើញថាការសះជានោះមានមានវិការៈ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបញ្ជាក់ថាបណ្តឹងនោះមិនទាន់ត្រូវបានបញ្ចប់ទេ ហើយត្រូវបន្តធ្វើការវិនិច្ឆ័យលើបណ្តឹងនោះ។[63] ប៉ុន្តែបើវិនិច្ឆ័យឃើញថា ការសះជាដែលបានធ្វើពីមុនមកនោះមានសុពលភាព តុលាការនៃបណ្តឹងសាទុក្ខត្រូវចេញសាលដីកាដែលប្រកាសអំពីការបញ្ចប់បណ្តឹងដោយការសះជានោះ។ ចំពោះបន្ទុកនៃប្រាក់ប្រដាប់ក្តី ភាគីដែលត្រូវទទួលបន្ទុកនៃប្រាក់ប្រដាប់ក្តី គឺអាស្រ័យទៅលើការព្រមព្រៀងរបស់ភាគីនោះ ប៉ុន្តែប្រសិនបើភាគីគ្មានការព្រមព្រៀងគ្នាអំពីប្រាក់ប្រដាប់ក្តីទេ ភាគីនីមួយៗ ត្រូវទទួលបន្ទុកក្នុងការបង់រៀងៗខ្លួន។ បើការសះជាបានសម្រេចលទ្ធផលមុនពេលធ្វើការទាញហេតុផលដោយផ្ទាល់មាត់ ដើមបណ្តឹងសាទុក្ខទទួលបានការសងមកវិញ នូវចំនួនពាក់កណ្តាលនៃពន្ធដែលបានបង់រួចមកហើយ។

## ៤.២. ការបញ្ចប់បណ្តឹងដោយសេចក្តីសម្រេចរបស់តុលាការ

ផ្ទុយមកវិញបើមានការបញ្ចប់បណ្តឹងសាទុក្ខ ដោយមិនឆ្លងកាត់សេចក្តីសម្រេចរបស់តុលាការនោះទេ តុលាការនៃបណ្តឹងសាទុក្ខ និងបញ្ចប់បណ្តឹងសាទុក្ខដោយចេញសាលដីកា ឬការលើកចោលនៃបណ្តឹងសាទុក្ខដោយដីកាសម្រេច ឬសាលដីកាច្រានចោលបណ្តឹងសាទុក្ខ ឬសាលដីកាទទួលស្គាល់នូវបណ្តឹងសាទុក្ខ។[64]

### ៤.២.១. ដីកាលើកចោលបណ្តឹងសាទុក្ខ

ការលើកចោលនូវបណ្តឹងសាទុក្ខមានន័យថា បណ្តឹងសាទុក្ខនោះមិនបាន ធ្វើស្របទៅតាមច្បាប់ ឬផ្ទុយនឹងច្បាប់ ហើយមិនអាចកែប្រែបាន ឬលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខមិនត្រូវបានដាក់នៅតុលាការតាមចិរវេលាដែលច្បាប់បានកំណត់ ឬមួយលិខិតបញ្ជាក់អំពីមូលហេតុនោះមិនបានដាក់ទៅតុលាការនៃបណ្តឹងសាទុក្ខ។ ហើយការលើកចោលមួយនេះ តុលាការនៃបណ្តឹងសាទុក្ខត្រូវលើកចោលដោយចេញដីកាសម្រេច។ បន្ថែមពីនេះប្រសិនបើតុលាការនៃបណ្តឹងសាទុក្ខមិនបានចេញនូវដីកាសម្រេចនៃលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ចុងបណ្តឹងសាទុក្ខ ហើយការធ្វើបែបនេះក្នុងគោលបំណងផ្តល់ឱកាសឱ្យចុងបណ្តឹងសាទុក្ខដាក់នូវឯកសារត្រៀម។[65]

### ៤.២.២. ដីកាចុងក្រោយ

#### ៤.២.២.១. សាលដីកាច្រានចោលបណ្តឹង

ក្នុងការជំនុំជម្រះលើអង្គសេចក្តី តុលាការត្រូវមើល ជាបឋមទៅលើឯកសារជាលាយលក្ខណ៍អក្សរដែលមានដូចជា លិខិតបណ្តឹង លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ឯកសារត្រៀមដំបូងដែលចុងបណ្តឹងសាទុក្ខ

[63] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២២២។

[64] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ៣០០។

[65] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៨៤ និងមាត្រា ២៩២។

បានដាក់ និងឯកសារផ្សេងៗទៀត។ ប្រសិនបើតុលាការរកឃើញដោយផ្អែកលើឯកសារទាំងអស់នោះថាគ្មានមូលហេតុប្តឹងសាទុក្ខ តុលាការនៃបណ្តឹងសាទុក្ខអាចចេញដីកាច្រានចោលនូវបណ្តឹងសាទុក្ខ ដោយមិនចាំបាច់ឆ្លងកាត់ការទាញហេតុផលដោយផ្ទាល់មាត់។ តុលាការនៃបណ្តឹងសាទុក្ខនៅតែអាចច្រានចោលពាក្យបណ្តឹងសាទុក្ខនោះ ទោះបីជាបានទាញហេតុផលដោយផ្ទាល់មាត់ហើយ ព្រោះថាបើតុលាការពិនិត្យ និងយល់ឃើញថាពុំមានមូលហេតុសម្រាប់ធ្វើបណ្តឹងសាទុក្ខទេ។[66]

### ៤.២.២.២. សាលដីកាទទួលស្គាល់បណ្តឹងសាទុក្ខ

តុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់ពាក្យបណ្តឹងសាទុក្ខ មានន័យថាពាក្យបណ្តឹងនោះធ្វើឡើងត្រឹមត្រូវតាមច្បាប់។ ដូច្នេះកាលដែលតុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់នូវបណ្តឹងសាទុក្ខ ហើយតុលាការត្រូវលុបចោលនូវសាលក្រម និងសាលដីកាដើម។ ការបដិសេធចោលត្រឹមនេះ មានន័យថាតុលាការនៃការជំនុំជម្រះលើអង្គច្បាប់ លុបចោលនូវសាលក្រមដើម ឬសាលដីកាដើម។[67]

### ក. ការបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញ

ក្នុងករណីដែលតុលាការនៃបណ្តឹងសាទុក្ខទទួលស្គាល់ថា ពាក្យបណ្តឹងសាទុក្ខនោះមានមូលហេតុត្រឹមត្រូវ តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើការបដិសេធនូវសាលក្រម ឬសាលដីកាដើម ហើយត្រូវបញ្ជូនរឿងក្តីនោះត្រឡប់ទៅតុលាការដើមវិញ។ ការបដិសេធរឿងក្តីនៃបណ្តឹងសាទុក្ខ គឺមានភាពខុសគ្នាពីការលុបចោលរឿងក្តី ដោយតុលាការនៃបណ្តឹងឧទ្ធរណ៍ ព្រោះថាក្រោយការបដិសេធជាថ្មី លើអង្គហេតុនៃរឿងក្តីនោះទេ គ្រាន់តែបញ្ជូនរឿងក្តីទៅតុលាការដើមវិញ។ ជាបឋមក្នុងករណីដែលមិនបានធ្វើការទទួលស្គាល់អង្គហេតុសារជាថ្មីមិនអាចធ្វើការជំនុំជម្រះចំពោះសាលក្រម ឬសាលដីកាដើមទេតុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីនោះទៅតុលាការដើមវិញ ឬក្នុងករណីដែលយល់ឃើញថាការបញ្ជូនត្រឡប់នោះមិនសមស្របទេត្រូវផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា។[68] ហើយតុលាការដែលបានទទួលនូវការបញ្ជូនត្រឡប់មកវិញ ឬដែលបានទទួលការផ្ទេរនោះត្រូវធ្វើការជំនុំជម្រះដោយធ្វើការហេតុផលដោយផ្ទាល់មាត់សារជាថ្មី ចំពោះរឿងក្តីនោះតាមនីតិវិធីនៃថ្នាក់ជំនុំជម្រះនោះ។ ការទាញហេតុផលដោយផ្ទាល់មាត់នេះទៀតសោត គឺជាការបើកឡើងវិញ និងបន្តនូវការទាញហេតុផលដោយផ្ទាល់មាត់ដែលត្រូវបានធ្វើពីមុនមក ហើយចៅក្រមដែលពាក់ព័ន្ធនឹងសាលដីកាដើម ឬសាលក្រមដើម មិនអាចចូលរួមក្នុងការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍នូវលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក។ ក្នុងការផ្លាស់ប្តូរចៅក្រមដូចនេះ ព្រោះថាប្រសិនបើ

[66] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៧៧ និងមាត្រា ២៨៦។

[67] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ៣០០។

[68] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៩៩។

តុលាការដើមនៅតែធ្វើការនៅតែធ្វើការវិនិច្ឆ័យដូចមុន ឬធ្វើការចាត់ចែងដូចមុន ទោះតុលាការនៃបណ្តឹងសាទុក្ខបានបញ្ជូនត្រឡប់ទៅវិញប៉ុន្មានក៏ដោយ ក៏រឿងក្តីនោះមិនអាចដោះស្រាយចប់ឡើយ។[69] សេចក្តីវិនិច្ឆ័យលើអង្គហេតុដែលមានអានុភាពត្រូវបានកម្រិត តែសេចក្តីវិនិច្ឆ័យអំពី អង្គហេតុដោយតុលាការនៃបណ្តឹងសាទុក្ខអាចវិនិច្ឆ័យបានដូចជា អង្គហេតុដែលទាក់ទងទៅនឹងចំណុចដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិប៉ុណ្ណោះ។ ជារួមមកវិញដើម្បីក្នុងការវិនិច្ឆ័យនោះបាន គឺចៅក្រមណាដែលមានការពាក់ព័ន្ធនឹងសាលក្រម ឬសាលដីកាដើមដែលត្រូវបានបដិសេធចោល មិនត្រូវអនុញ្ញាតចូលរួមក្នុងការសម្រេចសេចក្តីក្រោយបាននោះទេ។[70]

### ខ. ការផ្ទេររឿងក្តីទៅតុលាការផ្សេង

ជាគោលការណ៍តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនៃសាលដីកាដើម ឬសាលដីកាដើមតុលាការនៃបណ្តឹងសាទុក្ខត្រូវបញ្ជូនរឿងក្តីនោះត្រឡប់ទៅតុលាការដើមវិញ ក៏ប៉ុន្តែក្នុងករណីដូចជាតុលាការអាចរកចៅក្រមផ្សេងមកជំនួសចៅក្រមដែលមានការទាក់ទងនឹងការចេញសាលក្រម ឬសាលដីកាដើម ដែលត្រូវបានតុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនោះ ដោយសារតែចំនួនចៅក្រមនៅក្នុងតុលាការដើមនោះមិនគ្រប់គ្រាន់ តុលាការនៃបណ្តឹងសាទុក្ខត្រូវផ្ទេររឿងក្តីនោះទៅតុលាការផ្សេងដែលមានថ្នាក់ដូចគ្នា។ ការកំណត់បែបនេះក្នុងគោលបំណងជៀសវាងការយឺតយ៉ាវ ឬការរាំងស្ទះដល់ដំណើរនីតិវិធីបណ្តឹង។[71] ចំពោះតុលាការដែលទទួលការផ្ទេររឿងក្តីនេះ ត្រូវធ្វើការសម្រេចដោយផ្អែកទៅលើការទាញហេតុផលដោយផ្ទាល់មាត់សារជាថ្មី ហើយចំនួនចៅក្រមត្រូវអនុវត្តដូចគ្នានឹងករណីដែលបញ្ជូនរឿងក្តីត្រឡប់ទៅតុលាការដើមវិញដែរ។ ចំណែកឯភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍អំពីលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានធ្វើពីមុនមក។

### គ. ការបដិសេធចោល ហើយធ្វើការវិនិច្ឆ័យដោយខ្លួនឯង

តុលាការនៃបណ្តឹងសាទុក្ខត្រូវធ្វើសេចក្តីសម្រេចអំពីរឿងក្តីដោយផ្ទាល់ក្នុងករណីដូចខាងក្រោម៖

តុលាការនៃបណ្តឹងសាទុក្ខបានបដិសេធចោលនៃសាលក្រម ឬសាលដីកាដើមដោយហេតុថា តុលាការនៃការជំនុំជម្រះដើមមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្ត ចំពោះអង្គហេតុដែលបានចូលជាស្ថាពរ ហើយតុលាការនៃបណ្តឹងសាទុក្ខអាចសម្រេចសេចក្តីអំពីរឿងនោះដោយផ្អែកទៅលើអង្គហេតុនោះបាន។ មានន័យថាតុលាការនៃបណ្តឹងសាទុក្ខអាចធ្វើការវិនិច្ឆ័យដោយខ្លួនឯងទៅលើសាលក្រម ឬសាលដីកាដើមនោះបានក្នុងករណីដែលសាលក្រម ឬសាលដីកានោះធ្វើឡើងដោយមានកំហុសក្នុងការអនុវត្តរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្តលើអង្គហេតុដែលបានកំណត់ជាស្ថាពរនៅក្នុងសាលក្រម ឬសាលដីកាដើមនោះប៉ុណ្ណោះ។

[69] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៨។

[70] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៨៥។

[71] សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៧ មាត្រា២៩៩ ។

តុលាការនៃបណ្តឹងសាទុក្ខបដិសេធចោលនូវសាលក្រម ឬសាលដីកាដោយយកមូលហេតុថា រឿងក្តីនោះមិនស្ថិតនៅក្រោមសិទ្ធិជម្រះក្តីរបស់តុលាការ។ មានន័យថាតុលាការដើមបានធ្វើការជំនុំជម្រះ លើរឿងក្តីដោយខ្លួនឯង។

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

## ផ្នែកទី១៖ បញ្ហាប្រឈម

### ១.១. ភាពខ្វះចន្លោះនៃនីតិវិធីច្បាប់

នៅក្នុងប្រទេសកម្ពុជា គឺមានច្បាប់ជាច្រើនដោយរដ្ឋសភាពេលទទួលបានយោបល់យល់ព្រមលើសេចក្តីព្រាងច្បាប់ ឬសេចក្តីស្នើច្បាប់ពីព្រឹទ្ធសភា ត្រូវបញ្ជូនទៅរាជរដ្ឋាភិបាលដើម្បីបន្តនីតិវិធីបង្គំទូលថ្វាយព្រះមហាក្សត្រឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើ។ ជាងនេះទៅទៀត រដ្ឋសភាបានដាក់ច្បាប់ឱ្យអនុវត្តយ៉ាងច្រើន តែយ៉ាងណាមិញភាពចន្លោះខ្វះខាតនៅតែមានចន្លោះប្រហោង ជាក់ស្តែងដូចជាក្រមនីតិវិធីរដ្ឋប្បវេណី នៃបណ្តឹងសាទុក្ខសង្កេតឃើញថាមានចែងនៅក្នុង ក្រមនីតិវីធីរដ្ឋប្បវេណីចាប់ពីមាត្រា ២៨៣ ដល់ មាត្រា ៣០០ តែប៉ុណ្ណោះខ្វះចន្លោះច្រើន ដោយបញ្ញត្តិនៃមាត្រានីមួយៗ មិនបានពន្យល់ឱ្យបានក្បោះក្បាយពាក់ព័ន្ធទៅនឹងរបៀបដាក់ពាក្យបណ្តឹងសាទុក្ខ របៀបសរសេរលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ របៀបសរសេរបណ្តឹង របៀបដាក់សារណា ឬសារណាតប ការធ្វើសេចក្តីថ្លែងការណ៍ និងមូលហេតុនៃបណ្តឹងសាទុក្ខ មានត្រឹមតែមូលហេតុទូទៅនៃបណ្តឹងសាទុក្ខ និងមូលហេតុដាច់ខាតនៃបណ្តឹងសាទុក្ខថ្វីតែមាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានចែងអំពី **ការដកហូតចៅក្រមពីសមត្ថកិច្ចជំនុំជម្រះ** ក៏ពិតមែនតែវាមិនទាន់គ្រប់គ្រាន់នោះទេ ព្រោះគ្មានទម្រង់គំរូណាមួយច្បាស់លាស់នោះទេ មិនបានចែងបញ្ជាក់ឱ្យបានច្បាស់ពីការប្តឹងសាទុក្ខ មិនរៀបរាប់អំពីបណ្តឹងសាទុក្ខគួរដាក់បណ្តឹងបែបណា ហើយបណ្តឹងសាទុក្ខណាមិនត្រូវតាមច្បាប់ចែងអំពីមូលហេតុនៃបណ្តឹងសាទុក្ខតុលាការនឹងច្រានចោលបណ្តឹងសាទុក្ខ។ មួយវិញទៀត ចំពោះការអនុវត្តជាក់ស្តែងនៅពេលនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ឃើញថាភាគីដែលសុំពន្យាពេលនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការមិនងាយនឹងធ្វើការពន្យាពេលជូនភាគីនោះទេ។

មួយវិញទៀត ចំពោះបណ្តឹងសាទុក្ខ ទៅកាន់តុលាការកំពូល បើភាគីដើមបណ្តឹងសាទុក្ខបានដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ មិនត្រូវល័ក្ខខ័ណ្ឌច្បាប់កំណត់ទេ តុលាការនឹងច្រានចោលបណ្តឹង ឬបង្វិលសំណុំទៅកាន់តុលាការដើមវិញ នេះជាបញ្ហាមួយដែលនឹងធ្វើឱ្យភាគីនៃដើមបណ្តឹងសាទុក្ខងាយចាញ់ក្តីព្រោះតុលាការកំពូលបង្វិលសំណុំរឿង ឱ្យតុលាការដើមជំនុំជម្រះក្តីម្តងទៀត។ បញ្ហានេះក៏ជាមូលហេតុដែលធ្វើឱ្យសំណុំរឿងកកស្ទះវាបង្កទៅជាភាពយឺតយ៉ាវ ចំពោះនីតិវិធីច្បាប់ ហើយប្រជាជនដែលមកពឹងពាក់តុលាការក៏មានការសង្ស័យមកកាន់តុលាការកំពូល។

ជាគោលការណ៍នីតិវិធីច្បាប់តែងតែមានភាពខ្វះចន្លោះ ទាមទារឱ្យភាគីនៃបណ្តឹងមានភាពដឹងអំពីនីតិវិធីស្វែងយល់នីតិវិធីតាមផ្លូវបណ្តឹងនៅតុលាការកំពូល តុលាការកំពូលជាតុលាការជាន់ខ្ពស់ចុងក្រោយគេ ច្បាស់ណាស់ នីតិវិធីបណ្តឹងនៅដំណាក់ការតុលាការកំពូលតែងតែមានភាពក្រឹត្យក្រម។ តែដោយនីតិវិធីមានភាពស្មុគស្មាញពិបាកក្នុងការធ្វើបណ្តឹង ដូចការធ្វើបណ្តឹងសាទុក្ខពុំមានមូលហេតុដែលច្បាប់បានកំណត់ទេតុលាការកំពូល និងច្រានចោលបណ្តឹង ឬឱ្យកែតម្រូវពាក្យបណ្តឹងករណីការសរសេរបណ្តឹងខុស ប៉ុន្តែយ៉ាងណាមិញការដាក់ពាក្យបណ្តឹងវាមិនងាយស្រួលនោះទេ សម្រាប់ប្រជាជនធម្មតាដែលពុំមែនជាអ្នកច្បាប់ កុំថាឡើយតែប្រជាជនធម្មតា សូម្បីតែអ្នកសិក្សាច្បាប់មួយចំនួន ក៏ពិបាកយល់ពុំចេះអំពីនីតិវិធីបណ្តឹងទៅតុលាការកំពូលច្បាស់លាស់ផងដែរ។ ម្យ៉ាងទៀតករណីបណ្តឹងសាទុក្ខដែលធ្វើទៅតុលាការកំពូល បើតុលាការលើកចោលនូវពាក្យបណ្តឹងសាទុក្ខហើយ ភាគីនៃរឿងបណ្តឹងសាទុក្ខពុំអាចធ្វើបណ្តឹងជំទាស់បានដែរ ក្នុងបណ្តឹងសាទុក្ខច្បាប់មិនបើកសិទ្ធិដល់ភាគីនៃបណ្តឹងសាទុក្ខអាចធ្វើបណ្តឹងជំទាស់បានទេ។

## ១.២. កង្វះការយល់ដឹងរបស់ប្រជាពលរដ្ឋ និងភាគីនៃបណ្តឹងសាទុក្ខ

នៅប្រទេសកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ដែលទើបតែមានការរួចផុតពីសង្គ្រាម បែបនេះហើយប្រជាពលរដ្ឋគឺ ពុំសូវមានការយល់ដឹងអំពីច្បាប់នោះទេ។ ប៉ុន្តែរាល់ពេលបុគ្គលឯកជនមានវិវាទកើតឡើងត្រូវពឹងតុលាការ តែវាមិនស្រួលនោះទេសម្រាប់ប្រជាពលរដ្ឋណាដែលគាត់ខ្វះការយល់ដឹងទៅលើវិស័យច្បាប់ នៅកម្ពុជាកត្តាទាំងនេះ និងបង្កឱ្យមានភាពស្មុគស្មាញក្នុងការដំណើរការនីតិវិធីបណ្តឹង ហើយបុគ្គលនោះងាយនឹងរងគ្រោះក្នុងការស្វែងរកយុត្តិធម៌។ ណាមួយកម្រិតនៃការយល់ដឹងប្រជាជនមួយចំនួនពុំទាន់យល់ដឹងស៊ីជម្រៅ ចំពោះផ្លូវច្បាប់នោះទេ វាជាកត្តាមួយដែលធ្វើឱ្យពួកគាត់ ងាយនឹងរងគ្រោះពុំមានសិទ្ធិសមស្របតាមផ្លូវច្បាប់។ បើនិយាយអំពីការចែករំលែកផ្នែកច្បាប់នៅកម្ពុជានេះវិញគឺ ឃើញថានៅមានកម្រិតក្នុងការផ្សព្វផ្សាយ និងចែករំលែកចំណេះដឹងក្នុងវិស័យច្បាប់ ដោយយើងដឹងហើយថាច្បាប់ខ្មែរដូចជា ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណីទើបប្រកាសឱ្យប្រើនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ រីឯក្រមនីតិវិធីរដ្ឋប្បវេណីក៏ទើបតែប្រកាសឱ្យប្រើក្នុងថ្ងៃ០៦ ខែកក្កដា ឆ្នាំ២០០៦។ ម្យ៉ាងទៀតចំពោះប្រព័ន្ធការផ្សព្វផ្សាយ ឬបច្ចេកទេសនៃការផ្សាយជាសាធារណៈ ពុំអនុវត្តបានពេញលេញនូវឡើយទេ ដោយមានកត្តាជាច្រើនដូចជា ប្រជាជនមួយចំនួនមិនចេះអក្សរ ជីវភាពខ្វះខាត ការរស់នៅដាច់ស្រយាល ការផ្សព្វផ្សាយច្បាប់ក៏សង្កេតឃើញថាអនុវត្តបានច្រើន និងយល់ដឹងច្រើនតែប្រជាជនដែលរស់នៅក្នុងទីក្រុងប៉ុណ្ណោះ។ ការផ្សព្វផ្សាយប្រព័ន្ធច្បាប់ចំពោះតុលាការកំពូលឃើញថា ពុំទាន់មានភាពទូលំទូលាយនៅឡើយទេ ការស្វែងយល់ព្រឹត្តការណ៍ ឬខ្លឹមសារពាក់ព័ន្ធការជំនុំជម្រះក្តីនៅកំពូល ជុំវិញតុលាការកំពូលពិបាកក្នុងការស្វែងរក ជាពិសេសបញ្ហាដែលផ្សព្វផ្សាយអំពីលំហូរនីតិវិធីបណ្តឹងសាទុក្ខនៃការជំនុំជម្រះក្តី

ចំពោះរឿងរដ្ឋប្បវេណី ពុំសូវមានឯកសារគ្រប់គ្រាន់បង្ហាញតាមរយៈការផ្សព្វផ្សាយជាសាធារណៈ ដើម្បីឱ្យជាភាពងាយស្រួលដល់និស្សិត ឬអ្នកសិក្សាមួយចំនួនអាចងាយស្រួលស្វែងរកបាននោះទេ។

ជាពិសេសភាគីក្នុងរឿងបណ្តឹងសាទុក្ខនៃតុលាការកំពូល មានភាពពិបាកចំពោះការយល់ដឹងអំពីលំហូរនីតិវិធីនៃបណ្តឹងសាទុក្ខមានភាពពិបាកសម្រាប់ភាគី ភាគីមិនយល់អំពីការដាក់ពាក្យបណ្តឹងសាទុក្ខ មិនយល់អំពីការសរសេរពាក្យបណ្តឹងសាទុក្ខ មិនយល់ពីការបង់ពន្ធ ឬបង់ពន្ធប្រាក់ប្រដាប់ក្តី មិនយល់ពីរបៀបនៃការដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ការធ្វើសេចក្តីថ្លែងការណ៍ ឬថ្លែងការតបបែបណាផង។ ដោយឡែកនៅក្នុងការដាក់ពាក្យបណ្តឹងសាទុក្ខទៅកាន់តុលាការកំពូល កាន់តែមានភាពស្មុកស្មាញ ព្រោះមានភាពតឹងរឹងចំពោះបញ្ហាច្បាប់។ បែបនេះភាគីនៃបណ្តឹងសាទុក្ខមានភាពប្រឈមពិបាកខ្លាំងចំពោះការធ្វើបណ្តឹងសាទុក្ខរបស់ខ្លួន វាជាហេតុមួយនាំឱ្យតុលាការកំពូល ងាយនឹងច្រានចោលបណ្តឹងព្រោះតែភាគីមិនចេះអំពីការធ្វើបណ្តឹងនាំឱ្យពួកគាត់អាចធ្វើសេចក្តីថ្លែងការណ៍ដែលផ្ទុយទៅនឹងច្បាប់កំណត់ ឬការដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខដែលផ្ទុយនឹងច្បាប់ចែងនាំឱ្យតុលាការកំពូលច្រានចោលបណ្តឹងសាទុក្ខ។

## ១.៣. ភាពយឺតយ៉ាវរបស់តុលាការកំពូល

នៅពេលដែលភាគី នៃបណ្តឹងសាទុក្ខបានដាក់ពាក្យបណ្តឹងសាទុក្ខចូលមកកាន់រដ្ឋបាលសាលាដំបូង ឬសាលាឧទ្ធរណ៍ ហើយរដ្ឋបាលបញ្ជូនពាក្យបណ្តឹងសាទុក្ខចូលកាន់តុលាការកំពូលយូរ ហើយនាំតែតុលាការកំពូលអាចធ្វើការទាញហេតុផលដោយផ្ទាល់មាត់បាន គឺប្រើរយៈយូរព្រោះថាតុលាការកំពូល មានតែមួយស្ថាប័នការទទួលសំណុំរឿងច្រើនទទួលសំណុំរឿងពីសាលាដំបូងផង និងសាលាឧទ្ធរណ៍ផង។ ប្រសិនបើតុលាការកំពូលទទួលបានពាក្យបណ្តឹងពីតុលាការដើម ដែលភាគីនៃបណ្តឹងសាទុក្ខមិនសុខចិត្តចំពោះសាលដីការបស់សាលាឧទ្ធរណ៍ ក្នុងករណីដែលតុលាការកំពូលពិនិត្យទៅលើសាលដីកា របស់សាលឧទ្ធរណ៍មានការកាត់សេចក្តីដែលផ្ទុយនឹងមាត្រាណាមួយ ឬច្បាប់ណាមួយ តុលាការកំពូលច្រើនតែបង្វែលសំណុំរឿងទៅកាន់តុលាការដើមវិញនាំឱ្យនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់យឺតយ៉ាវ ណាមួយនាំតែកោះហៅភាគីក៏ប្រើពេលយូរនៅការបញ្ជូនពាក្យបណ្តឹងទៅកាន់ភាគីព្រមតែងកំណត់ការទាញហេតុផលដោយផ្ទាល់មាត់រយៈពេលនៃនីតិវិធីបណ្តឹងប្រើពេលវេលាយូរដែលនាំឱ្យមានភាពយឺតយ៉ាវនៃនីតិវិធីនៃការជំនុំជម្រះនៅតុលាការកំពូល។

តុលាការកំពូលរាល់ពាក្យបណ្តឹងសាទុក្ខ គឺជំនុំជម្រះតែទៅលើអង្គច្បាប់ប៉ុណ្ណោះ។ ពាក្យបណ្តឹងសាទុក្ខក្នុងករណីភាគីដើមបណ្តឹងសាទុក្ខបានដាក់ពាក្យបណ្តឹងសាទុក្ខ ដើមបណ្តឹងសាទុក្ខត្រូវដាក់នៅតុលាការដើមនៃបណ្តឹងសាទុក្ខ គឺសាលាឧទ្ធរណ៍ដែលមានរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានការបញ្ជូនលិខិតពាក្យបណ្តឹងសាទុក្ខ ឃើញថារយៈពេល ៣០ (សាមសិប) ថ្ងៃជាពេលមួយដែលលឿន ហើយតាមភាព

ដាក់ស្តែងក្នុងដំណាក់ការសាលាឧទ្ធរណ៍ ការបញ្ជូនពាក្យបណ្តឹងសាទុក្ខទៅតុលាការកំពូលមានមានភាពយឺតយ៉ាវ ការយឺតយ៉ាវនេះទៀតសោត គឺកើតចេញពីការបញ្ជូនពាក្យបណ្តឹងសាទុក្ខពីរដ្ឋបាលនូវតុលាការដើម ទៅតុលាការកំពូល ដែលមានសមត្ថកិច្ចជំនុំជម្រះបណ្តឹងសាទុក្ខ (តុលាការកំពូល) យើងឃើញថាភាពយឺតយ៉ាវក៏ភាពអយុត្តិធម៌ដល់ភាគីដែរ។

ម្យ៉ាងទៀតនីតិវិធីរដ្ឋប្បវេណី គឺមានភាពស្មុគស្មាញរាល់នីតិវិធីនីមួយៗ ចប់សព្វគ្រប់គឺ ចំណាយរយៈពេលច្រើនខែ ដែលនាំតែដឹងថាបុគ្គលណាឈ្នះបុគ្គលណាចាញ់ក្តី ការយឺតយ៉ាវរបស់តុលាការបង្កឱ្យភាគីនៃបណ្តឹងសាទុក្ខពុំទទួលយុត្តិធម៌តាមផ្លូវច្បាប់ ការយឺតយ៉ាវរបស់តុលាការបង្កឱ្យមានភាពពិបាកទៅដល់តុលាការកាត់ក្តី និងដល់ភាគីដែលមានវិវាទ ព្រោះនីតិវិធីនៅក្នុងតុលាការរដ្ឋប្បវេណី តុលាការមានរឿងក្តីច្រើនជារៀងរាល់ថ្ងៃរឿងក្តីនីមួយៗតុលាការត្រូវការពេលវេលា ដើម្បីធ្វើការដោះស្រាយឱ្យមានតម្លាភាពស្របច្បាប់។ បើក្រឡេកមកមើលរឿងបណ្តឹងសាទុក្ខក្នុងរឿងរដ្ឋប្បវេណីទៅកាន់តុលាការកំពូលទៀត សួរថាត្រូវចំណាយពេលប៉ុន្មានដើម្បីបញ្ចប់នីតិវិធីនេះបាន គឺច្បាស់ណាស់ត្រូវទាមទារពេលវេលាយូរ ដើម្បីឱ្យតុលាការអាចធ្វើការតាមលំហូរនីតិវិធីបានល្អិតល្អន់ ប៉ុន្តែវាបង្កឱ្យកកស្ទះសំណុំរឿង។ ភាពយឺតយ៉ាវទាំងនេះ ក៏កើតចេញពីការជំនុំជម្រះក្តី តែបែបគ្មានភាគីចូលរួម ក៏ជាភាពពិបាកដល់តុលាការជម្រះក្តី និងធ្វើការពន្យាពេលវេលាឱ្យភាគីចូលខ្លួនក្នុងនីតិវិធីជំនុំជម្រះក្តី ការទាញហេតុផលដោយផ្ទាល់មាត់។ ជាងនេះទៅទៀតបណ្តឹងសាទុក្ខ តុលាការកំពូលច្រើនបង្វិលសំណុំរឿងមកកាន់តុលាការដើមជំនុំជម្រះសារជាថ្មី បើបង្វិលសំណុំរឿងបែបនេះតុលាការដើមគឺ មានបន្ទុករឿងក្តីច្រើន ហើយការកាត់សេចក្តីក៏ប្រហាក់ប្រហែលនឹងការកាត់សេចក្តីដំបូងដែរ។ ជាធម្មតាភាគីដើមបណ្តឹងសាទុក្ខដាក់ពាក្យបណ្តឹងសាទុក្ខ ទៅតុលាការកំពូលព្រោះចង់ឱ្យតុលាការកំពូលវិនិច្ឆ័យក្តីរបស់ខ្លួន ចំពោះសាលដីកាតុលាការដើម តែបើកំពូលបង្វិលមកតុលាការដើមវិញដដែលដើមបណ្តឹងសាទុក្ខ ពុំទទួលបានការកាត់សេចក្តីដែលឆាប់រហ័សនោះទេ។

## ១.៤. ដើមបណ្តឹងសាទុក្ខមិនបង់ប្រាក់ប្រដាប់ក្តី និងការចំណាយសោហ៊ុយបន្ទុករបស់គូភាគី

នៅពេលមានបណ្តឹងសាទុក្ខកើតឡើងដោយដើមបណ្តឹងសាទុក្ខ បានដាក់ពាក្យបណ្តឹងនៅសាលាឧទ្ធរណ៍ដែលជាតុលាការដើម (ករណីការប្តឹងសាទុក្ខចំពោះដីកាសម្រេចចុងក្រោយរបស់សាលាឧទ្ធរណ៍) ហើយតុលាការសាលាឧទ្ធរណ៍ទទួលសិទ្ធិពីតុលាការកំពូលឱ្យចេញដីកាបង្គាប់ឱ្យបង់ពន្ធដែលមានរយៈពេល ១ខែ ប៉ុន្តែដើមបណ្តឹងសាទុក្ខខ្លះពុំមានលទ្ធិភាពក្នុងការបង់ពន្ធនៃប្រាក់ប្រដាប់ក្តីនោះទេ ជាងនេះពន្ធនៃរឿងបណ្តឹងសាទុក្ខត្រូវបង់ពន្ធ ២ ដង (ពីរដង) ក្នុងការចំណាយប្រាក់ប្រដាប់ក្តីក្នុងបណ្តឹងសាទុក្ខ។

ដោយឡែក ចំពោះពន្ធដាក់ពាក្យសុំក្នុងការដាក់ពាក្យបណ្ដឹងឧបាស្រ័យត្រូវកំណត់ ការដាក់បណ្ដឹងឧទ្ធរណ៍ត្រូវបង់ពន្ធ ១,៥ ដង (មួយក្បៀសប្រាំដង) នៃពន្ធដែលបានបង់នៅសាលាដំបូង បណ្ដឹងសាទុក្ខត្រូវបង់ពន្ធ ២ ដង (ពីរដង) ការចំណាយប្រាក់ប្រដាប់ក្ដីក្នុងបណ្ដឹងសាទុក្ខគឺ ច្រើនជាងបណ្ដឹងផ្សេងៗ។ នៅក្នុងការអនុវត្តជាក់ស្ដែងប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ ចៅក្រមខ្លះកំណត់តម្លៃ ១០០.០០០ (មួយរយពាន់) រៀល រីឯចៅក្រមខ្លះទៀតកំណត់តម្លៃ ៣០០.០០០ (ពីររយពាន់) រៀល។ ការកំណត់តម្លៃខុសៗគ្នានេះ ដោយសារតែគ្មានការកំណត់តម្លៃឱ្យមានលក្ខណៈជាស្តង់ដារនៅឡើយនៅកម្ពុជា ប៉ុន្តែករណីនៅប្រទេសជប៉ុនគេបានកំណត់ជាស្តង់ដារតែម្ដង។ ប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ តម្រូវឱ្យភាគីធ្វើការបង់ជាមុន ដើម្បីឱ្យតុលាការធ្វើសកម្មភាពណាមួយ ប៉ុន្តែករណីដែលភាគីមិនបានបង់ពន្ធនោះទេ នោះតុលាការនឹងមិនធ្វើនូវសកម្មភាពដែលតម្រូវឱ្យបង់ប្រាក់ប្រដាប់ក្ដីនោះឡើយ។ ជាទូទៅរឿងក្ដីរដ្ឋប្បវេណី គឺជាវិវាទរវាងបុគ្គលឯកជន ដោយប្រើប្រាស់តាមរយៈប្រព័ន្ធតុលាការរបស់រដ្ឋ ហេតុដូចនេះនៅក្នុងរឿងក្ដីរដ្ឋប្បវេណី យើងឃើញថាតុលាការតែងតែតម្រូវឱ្យដើមបណ្ដឹងសាទុក្ខធ្វើការបង់ប្រាក់ថ្លៃពន្ធ និងសោហ៊ុយចំណាយផ្សេងៗ ដើម្បីដំណើរការនីតិវិធីនៃរឿងក្ដីនោះ ហើយប្រាក់ដែលត្រូវបង់នេះ ហៅថាប្រាក់ប្រដាប់ក្ដី។ ប្រាក់ប្រដាប់ក្ដី គឺជាពន្ធសរុប និងចំណាយផ្សេងៗ ដែលត្រូវបង់សម្រាប់ដំណើរការនៃរឿងក្ដីនីមួយៗ ដែលត្រូវបានកំណត់ដោយតុលាការ ដោយការគណនាតាមកំណត់ច្បាប់។ យោងតាមច្បាប់កម្ពុជា ប្រាក់ប្រដាប់ក្ដី ចំពោះរឿងក្ដីព្រហ្មទណ្ឌពុំមានឡើយ គឺមានតែប្រាក់ប្រដាប់ក្ដីក្នុងរឿងក្ដីរដ្ឋប្បវេណីតែប៉ុណ្ណោះ។ ជាទូទៅទំហំចំនួននៃប្រាក់ប្រដាប់ក្ដីរដ្ឋប្បវេណី និងបុគ្គលដែលត្រូវទទួលបន្ទុកនៃប្រាក់ប្រដាប់ក្ដីរដ្ឋប្បវេណី គឺប្រែប្រួលទៅតាមប្រភេទនៃបណ្ដឹង តម្លៃកម្មវត្ថុនៃការទាមទារជាក់ស្ដែងនៅក្នុងបណ្ដឹង និងស្ថានភាពផ្សេងៗនៃរឿងក្ដីរដ្ឋប្បវេណីនីមួយៗ។ បើក្នុងកត្តាដើមបណ្ដឹងសាទុក្ខមិនបង់ពន្ធចំពោះពាក្យបណ្ដឹងសាទុក្ខទេ តុលាការចាំបាច់ទាមទារឱ្យបង់ពន្ធចំពោះប្រាក់ប្រដាប់ក្ដី បើមិនដូចនេះទេតុលាការ និងលើកចោលបណ្ដឹងសាទុក្ខ វាការចាំបាច់តម្រូវឱ្យដើមបណ្ដឹងសាទុក្ខត្រូវបង់ពន្ធ មុនពេលដំណើរការនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ វាអាចជាបញ្ហាចំពោះដើមបណ្ដឹងសាទុក្ខដែលពុំមានលទ្ធភាពក្នុងការបង់ប្រាក់ប្រដាប់ក្ដីទេ ដំណើរការនៃពាក្យបណ្ដឹងពុំមានការជនុំជម្រះតាមប្រព័ន្ធតុលាការឡើយ ព្រោះរឿងរដ្ឋប្បវេណីតុលាការជាតុលាការអកម្ម។

ការធ្វើបណ្ដឹងនីមួយៗរបស់ភាគីត្រូវចំណាយប្រាក់ច្រើនណាស់សម្រាប់ភាគី នៅត្រង់នេះទម្រាំតែបណ្ដឹងត្រូវចប់ជាស្ថាពរភាគីត្រូវចំណាយប្រាក់ផ្ទាល់ខ្លួនយ៉ាងច្រើន សម្រាប់ដំណើរការនីតិវិធីបណ្ដឹងទៅបាន ព្រោះថា បណ្ដឹងរដ្ឋប្បវេណីជារឿងឯកជន ដែលការពារសិទ្ធិស្របច្បាប់របស់បុគ្គលឯកជនតាមរយៈការដោះស្រាយវិវាទដោយបង្ខំដោយតុលាការជាអ្នកដើរតួ ដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិ

របស់បុគ្គលឯកជន។[72] ប៉ុន្តែយ៉ាងណាមិញ ការចំណាយចំពោះការដាក់ពាក្យបណ្តឹង លើរឿងនីមួយៗត្រូវការប្រាក់ច្រើនទៅហើយ បើឱ្យភាគីមកធ្វើបណ្តឹងសាទុក្ខទៀត ការចំណាយក៏កាន់តែទ្វេដងស្មើតែលើសពីប្រាក់នៃការទាមទារក្នុងបណ្តឹងទៅហើយ ដូចនេះភាគីអាចមិនទទួលបានភាពយុត្តិធម៌នោះទេ បើយើងសិក្សានឹងមើលពីក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៤ បានចែងថា" តុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណីឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តធម៌ និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិត និងស្មោះត្រង់។[73] មួយវិញទៀត ចំពោះបញ្ហាការមិនបង់ប្រាក់ប្រដាប់ក្តីរបស់ដើមបណ្តឹងសាទុក្ខ នៅតុលាការកំពូលនឹងធ្វើការលើកចោលបណ្តឹងសាទុក្ខ ផ្ទុយអំពីបណ្តឹងឧទ្ធរណ៍។

## ១.៥. ការមិនដាក់សារណានៃបណ្តឹងសាទុក្ខរបស់ភាគី

ផ្អែកតាមមាត្រា ២៨៩ ការសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ កថាខណ្ឌទី១ បានចែងថាប្រសិនបើមិនបានសរសេរមូលហេតុនៃបណ្តឹងសាទុក្ខ ក្នុងពាក្យបណ្តឹងសាទុក្ខនោះទេ ដើមបណ្តឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនេះ ជូនទៅតុលាការនៃបណ្តឹងសាទុក្ខក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃបន្ទាប់ពីបានទទួលការបញ្ជូននូវលិខិតពាក្យបណ្តឹងសាទុក្ខ។[74] ប៉ុន្តែបើត្រឡប់មកមើលពីបញ្ហាប្រឈមវិញឃើញថា ការសរសេរលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ គឺមានភាពពិបាកណាស់សម្រាប់ដើមបណ្តឹងសាទុក្ខ ព្រោះបណ្តឹងសាទុក្ខធ្វើការវិនិច្ឆ័យតែលើអង្គច្បាប់ប៉ុណ្ណោះ ភាគីមិនមែនអ្នកសិក្សាច្បាប់គាត់ពុំយល់ ឬពុំច្បាស់លាស់ដូចអ្នកបានសិក្សាច្បាប់នោះទេ (មេធាវី) នេះជាហេតុដែលពិបាករបស់ភាគីដើមបណ្តឹងសាទុក្ខក្នុងការដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ការដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនេះទៀតសោត ដើមបណ្តឹងសាទុក្ខសរសេរលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខពុំមានសំអាងច្បាប់ច្បាស់លាស់ទេ តុលាការងាយនឹងច្រាលចោលពាក្យបណ្តឹងនេះណាស់ ដូចនេះភាគីដើមបណ្តឹងសាទុក្ខត្រូវចំណាយសោហ៊ុយដើម្បីពឹងពាក់មេធាវីក្នុងការការពារក្តីនៅតុលាការកំពូល។

លើសពីនេះទៅទៀតមាត្រា ២៩៣ ការបង្គាប់ឱ្យដាក់ឯកសារត្រៀមបានចែងថា តុលាការនៃបណ្តឹងសាទុក្ខអាចកំណត់អំឡុងពេលសមរម្យ ហើយបង្គាប់ឱ្យចុងបណ្តឹងសាទុក្ខដាក់ឯកសារត្រៀមលើកដំបូង។[75] កាលណាតុលាការទទួលបានពាក្យបណ្តឹងសាទុក្ខពីដើមបណ្តឹងសាទុក្ខហើយតុលាការ គឺមានកាតព្វកិច្ចត្រូវបញ្ជូនលិខិតបណ្តឹងសាទុក្ខនេះទៅចុងបណ្តឹងសាទុក្ខ ដើម្បីឱ្យចុងបណ្តឹងសាទុក្ខធ្វើការដាក់ឯកសារត្រៀមតប (សារណាតប)

[72] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២។

[73] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ៤។

[74] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៨៩ កថាខណ្ឌទី១។

[75] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ២៩៣។

មកដើមបណ្តឹងសាទុក្ខ ដើម្បីជាការដោះបន្ទុករបស់ខ្លួនតបទៅ និងដើមបណ្តឹងសាទុក្ខ ប៉ុន្តែប្រសិនបើចុងបណ្តឹងសាទុក្ខ ពុំធ្វើការដាក់ឯកសារត្រៀមទេ ឬសារណាតបទេ ប្រៀបដូចខ្លួនទទួលស្គាល់ទៅលើបណ្តឹងទៅហើយ កន្លែងនេះវាជាបញ្ហាបើក្នុងករណីភាគីនៃចុងបណ្តឹងសាទុក្ខពុំមានការយល់អំពីការដាក់សារណាតបទេ។ បើមានបណ្តឹងសាទុក្ខកើតឡើងដោយដើមបណ្តឹងសាទុក្ខតុលាការ និងឱ្យដើមបណ្តឹងសាទុក្ខដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ដោយតុលាការនៃបណ្តឹងសាទុក្ខ និងធ្វើការបញ្ជូនពាក្យបណ្តឹងសាទុក្ខទៅចុងបណ្តឹងសាទុក្ខ ដើម្បីឱ្យចុងបណ្តឹងសាទុក្ខដាក់នៅឯកសារត្រៀម (សារណាតប) ដើម្បីធ្វើការដោះបន្ទុក ភាគីមួយចំនួនពុំយល់អំពីខ្លឹមសារនៃបណ្តឹង ឬពុំទទួលបានលិខិតបណ្តឹងដោយការបញ្ជូនរបស់តុលាការក្នុងប្រភេទការបញ្ជូនដោយទុកចោល តុលាការគួរតែព្យាយាមធ្វើការបញ្ជូនដោយប្រគល់ផ្ទាល់ដល់ភាគី ដើម្បីឱ្យភាគីដឹងអំពីបណ្តឹងសាទុក្ខ ឬឱ្យមន្ត្រីអនុវត្តចំពោះការបញ្ជូនធ្វើរបាយការណ៍ឱ្យបានច្បាស់លាស់ និងតុលាការគួរតែពិនិត្យអំពីខ្លឹមសារទាំងនេះ វាជាការទប់ស្កាក់អំពីភាពអកម្មរបស់មន្ត្រីអនុវត្តមួយចំនួនតូច។ ម្យ៉ាងទៀតភាគីនៃចុងបណ្តឹងសាទុក្ខគួរតែស្វែងរកមេធាវីការពារក្តីឱ្យខ្លួន ដើម្បីឱ្យមេធាវីធ្វើការដាក់ឯកសារត្រៀមដែលមានអានុភាព និងស្របច្បាប់ និងមិនប្រាលចាកភាពផ្ទុយច្បាប់ដែលនាំឱ្យភាគីចុងបណ្តឹងសាទុក្ខអាចចាញ់ក្តី។

## ១.៦. ភាពខ្វះចន្លោះនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២

យ៉ាងណាមិញសង្កេតឃើញថា នីតិវិធីនៃបណ្តឹងសាទុក្ខលើកទី១ គឺមានការកំណត់យ៉ាងច្បាស់លាស់ចំពោះនីតិវិធីនៃការជនុំជម្រះបណ្តឹងសាទុក្ខដូចជា រៀបរាប់ការអំពីការដាក់ពាក្យបណ្តឹង ការបញ្ជូនដីកា ការបង់ប្រាក់ប្រដាប់ក្តី ជាពិសេសនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់បានកំណត់ជាក់លាក់ ប៉ុន្តែចំពោះនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ ក៏អនុវត្តដូចគ្នាទៅនឹងនីតិវិធីជំនុំជម្រះបណ្តឹងសាទុក្ខលើកទី១ដែរ ខុសគ្នាត្រង់ថាបណ្តឹងសាទុក្ខលើកទី២ គឺតុលាការដែលមានបន្ទុកទៅលើបណ្តឹងសាទុក្ខធ្វើការជនុំជម្រះទាំងអង្គហេតុ និងអង្គច្បាប់ ដែលផ្ទុយទៅនឹងបណ្តឹងសាទុក្ខលើកទី១ ជំនុំជម្រះតែអង្គហេតុតែប៉ុណ្ណោះ ហើយមានភាពខុសគ្នាចំពោះសមាសភាពចៅក្រមជំនុំជម្រះលើកទី១ មានចៅក្រមត្រឹម ៥ រូប តែការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ គឺប្រព្រឹត្តឡើងដោយសភាពេញអង្គ ហើយមានកំណត់ចែងក្នុង "ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ" សមាសភាពនៃការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ គឺមានសមាសភាពចៅក្រម ៩ រូប។ ប៉ុន្តែឃើញថាពុំមានការបែងចែកច្បាប់ ឬបទបញ្ញត្តិលម្អិតដូចនីតិវិធីនៃការជំនុំជម្រះលើកទី១នោះទេ នៅត្រង់ចំណុចនេះនីតិនិពន្ធអាចគិតថាការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ មានលក្ខណៈដូចគ្នានឹងការជំនុំជម្រះលើកទី១ដែរ បានជាមិនបានចែងការមិនបានចែងនៅត្រង់ចំណុចនេះ ចំពោះការអនុវត្តអាចមិនបានលម្អិតដូចការជំនុំជម្រះលើកទី១ ហើយអាចមានការអនុវត្តខុសគ្នាពីចៅក្រមមួយទៅចៅក្រមមួយទៀត ចំពោះការអនុវត្តនីតិវិធីអ្នកច្បាប់ គឺចង់បានអនុវត្តជា

រួមមួយដូចគ្នា។ អំពី លំហូរនីតិវិធីនៃការជនុំជម្រះបណ្តឹងសាទុក្ខលើកទី១នោះទេ បែរជាមានចែងតែសមាសភាពចៅក្រមនៃការជំនុំជម្រះបណ្តឹងសាទុក្ខលើក២តែប៉ុណ្ណោះ។

# ផ្នែកទី២ ៖ ដំណោះស្រាយ

## ២.១. ការបង្កើតច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិ

ពិតណាស់ទោះបីជានៅប្រទេសកម្ពុជាមានច្បាប់ ឬបទដ្ឋានគតិយុត្តច្រើនក៏ពិតមែនតែក៏ឃើញថាវាមិនទាន់គ្រប់គ្រាន់នៅឡើយជាពិសេសក្រមនីតិវិធីរដ្ឋប្បវេណីត្រង់គន្ថីទី៣ ជំពូកទី៣ បណ្តឹងសាទុក្ខគឺ គួរតែមានបង្កើតច្បាប់ ឬបទបញ្ញាត្តិឱ្យច្រើនបន្ថែមទៀតដែលទាក់ទងទៅនឹងនីតិវិធីនៃបណ្តឹងសាទុក្ខ បន្ថែមទៅចំណុចនៃការដាក់ពាក្យបណ្តឹងសាទុក្ខ របៀបសរសេរបណ្តឹងសាទុក្ខ ការដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ការធ្វើសេចក្តីថ្លែងការណ៍ ឬការដាក់សារណាភាគីជាដើម គួរមានការពន្យល់បន្ថែមចំពោះភាគីនៃបណ្តឹងសាទុក្ខឱ្យកាន់តែលម្អិត ឬក៏ពន្យល់ណែនាំភាគីឱ្យពឹងពាក់មេធាវីដើម្បីជាការសម្រួលដល់ការដាក់បណ្តឹងសាទុក្ខ និងការពារក្តីជូនខ្លួនចំពោះបណ្តឹងសាទុក្ខនេះ។

បង្កើតបទបញ្ញាត្តិបន្ថែម ដែលទាក់ទងនឹងការជំនុំជម្រះបណ្តឹងសាទុក្ខ កំណត់ជាយុត្តិសាស្ត្រជាស្តង់ដាសម្រាប់តុលាការសាលាដំបូង ឬសាលាឧទ្ធរណ៍អាចយកធ្វើជាគំរូ កំណត់អំពីការសរសេរពាក្យបណ្តឹង កំណត់អំពីតម្លៃនៃការបង់ពន្ធ អាចមានលក្ខណៈដូចគ្នាទៅនឹងច្បាប់ប្រទេសជប៉ុន។ លើសពីនេះទៅទៀត គួរតែបង្កើតបទដ្ឋាន សេចក្តីណែនាំនៃតុលាការកំពូលទម្រង់នៃការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២។ ដូចគ្នាផងដែរ ច្បាប់មិនមែនមនុស្សគ្រប់រូបសុទ្ធតែអាចយល់ដឹងពីខ្លឹមសារបទបញ្ញាត្តិនីមួយៗ ក្នុងមាត្រាបានទេទាល់តែឆ្លងកាត់ការរៀន និងសិក្សាស្វែងយល់ឱ្យបានទូលំទូលាយបំផុត ដោយហេតុពាក្យដែលប្រើប្រាស់ក្នុងបទបញ្ញាត្តិនីមួយៗមានពាក្យបច្ចេកទេសច្រើន ដូចនេះដើម្បីជាកត្តាឱ្យមនុស្សគ្រប់រូបស្វែងយល់ពីច្បាប់បាន គួរតែប្រើការសម្រាយ ឬប្រើពាក្យពេចន៍ណាមួយ ដែលងាយយល់ផងដែរ។

## ២.២. ការផ្សព្វផ្សាយ និងបណ្តុះបណ្តាលនីតិវិធីច្បាប់នៅតុលាការកំពូលឱ្យច្រើន

ជាក់ស្តែងសង្គមនាពេលបច្ចុប្បន្នបានកំពុងនឹងជួបប្រទះលើភាពខ្វះចន្លោះនៃច្បាប់ ដោយហេតុកម្រិតចំណេះដឹងរបស់ប្រជាពលរដ្ឋ លើការសិក្សាស្វែងយល់អំពីច្បាប់មានភាពតូចចង្អៀតនៅឡើយ។ ដោយសង្កេតឃើញថាមានបញ្ហាប្រឈម ដូច្នេះគួរតែមានដំណោះស្រាយណាមួយដើម្បីជួយសម្រួលឱ្យប្រព័ន្ធច្បាប់នៅប្រទេសកម្ពុជាកាន់តែមានភាពទូលំទូលាយ និងជាកត្តាជំរុញឱ្យប្រជាជនគ្រប់រូបទទួលដឹងបានគ្រប់ជ្រុងជ្រោយ។ ក្នុងការស្វែងរកដំណោះស្រាយដែលសមស្រប ដើម្បីឆ្លើយតបទៅនឹងផលវិបាកខាងលើនេះ។ គួរតែមានការផ្សព្វផ្សាយតាមរយៈសកម្មភាពជាច្រើនដូចជា៖

**តាមរយៈសិក្ខាសាលា** គួរមានការចែករំលែកចំណេះដឹងឱ្យបានច្រើនទៅកាន់សិស្សានុសិស្ស ឬនិស្សិតបញ្ញវន្ត ដែលគួរបង្កើតប្រធានបទលំហូរនីតិវិធីនៃបណ្តឹងសាទុក្ខឱ្យបានច្រើន ដើម្បីជាជំនួយដល់ការបង្កើន

ចំណេះដឹង ឬការយល់ដឹងបន្ថែមពាក់ព័ន្ធទៅលើវិស័យច្បាប់ ព្រោះថាសិស្សានុសិស្ស គឺជាកត្តាចម្បងក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ជាទំពាំងស្នងឬស្សីប្រទេសជាតិ។ ដូច្នេះពួកគេគួរតែមានការបណ្តុះបណ្តាល សិក្សាស្វែងយល់ឱ្យបានច្រើនទៅលើច្បាប់របស់ប្រទេសរបស់ខ្លួន ក្នុងការរួមចំណែកលើកស្ទួយប្រទេសជាតិខាងធនធានមនុស្ស។ សិស្សានុសិស្ស អាចទទួលបានការសិក្សាស្រាវជ្រាវបានពេញលេញ លុះត្រាតែមានការចូលរួមចំណែកពីសាលារៀន សាស្ត្រាចារ្យ និងជាពិសេសក្រសួងពាក់ព័ន្ធពាក់ព័ន្ធដែលបើកទូលាយលើអត្ថបទច្បាប់ជាដើម។ ជាការសំណូមពរដល់ក្រសួងអប់រំ គួរតែមានរៀបចំប្រព័ន្ធសិក្សាដែលពាក់ព័ន្ធនឹងច្បាប់ក្នុងការសិក្សារបស់សិស្សឱ្យបានច្រើន មិនថាជាប្រភេទមុខជំនាញអ្វី ដើម្បីឱ្យសិស្សបានដឹង និងបានសិក្សាស្វែងយល់បានគ្រប់ៗគ្នាផងដែរ។ ម៉្យាងទៀតសង្កេតឃើញថាចំពោះប្រជាពលរដ្ឋដែលរស់នៅដាច់ស្រយាល ការយល់ដឹងក៏នៅមានកម្រិត ដូច្នេះគួរតែយកចិត្តទុកដាក់បន្ថែម លើប្រព័ន្ធអប់រំ និងការផ្សព្វផ្សាយឱ្យបានកាន់តែទូលាយ ដើម្បីធានាបានថារាល់ការផ្សព្វផ្សាយទាំងនោះបានទទួលជ្រាបដល់ប្រជាជន។

**តាមរយៈការផ្សាយព័ត៌មាន ឬកាសែត** ការផ្សព្វផ្សាយច្បាប់តាមរយៈសារព័ត៌មាននេះ ពិតជាមានសារៈសំខាន់ណាស់ក្នុងការចែករំលែកព័ត៌មានថ្មីៗ ឬហេតុការណ៍ថ្មី ហើយក៏មានប្រជាពលរដ្ឋកម្ពុជាជាច្រើនមានការនិយមចូលចិត្តតាមដានសារព័ត៌មាន ដើម្បីទទួលបានហេតុការណ៍ដែលកើតឡើងក្នុងសង្គម។ ដោយឡែកគួរមានការផ្សព្វផ្សាយច្បាប់ដែលទាក់ទងអំពីនីតិវិធីនៃបណ្តឹងសាទុក្ខឱ្យបានច្រើនតាមរយៈការផ្សាយព័ត៌មាន ឬតាមរយៈកាសែត ព្រោះថាប្រជាពលរដ្ឋខ្មែរងាយស្រួលតាមដានវិស័យច្បាប់ដោយភាពងាយស្រួល ប្រសិនបើករណីប្រជាពលរដ្ឋណាពុំចេះអក្សរក៏អាចយល់ដឹងបានតាមរយៈស្តាប់ការផ្សាព្វផ្សាយព័ត៌មានដែលបាននិយាយជាសំឡេង មិនត្រឹមតែប៉ុណ្ណោះសូម្បីតែអ្នកដែលពិការភាពទៅលើការស្តាប់ពុំបាន ក៏អាចស្វែងរកច្បាប់តាមរយៈកាសែត ឬទស្សនាវដ្តីជាដើម វាជាភាពងាយស្រួលដល់ពួកគាត់ថែមទៀត។

**តាមរយៈទូរទស្សន៍ ឬទូរស័ព្ទ** សង្គមបច្ចុប្បន្ននេះ គឺជាសង្គមដែលជឿនលឿនតាមរយៈប្រព័ន្ធផ្សព្វផ្សាយអេឡិចត្រូនិច ដែលអតិបរមានៃការប្រើប្រាស់របស់ប្រជាពលរដ្ឋមានសន្ទុះខ្ពស់ ដែលផ្តល់ភាពងាយស្រួល និង ទូលំទូលាយក្នុងការផ្សព្វផ្សាយព័ត៌មានផ្សេងៗ មិនថាជាព័ត៌មានសង្គម ឬការផ្សព្វផ្សាយអត្ថបទច្បាប់ណាមួយមានភាពងាយស្រួល និងឆាប់រហ័ស។ ការយល់ដឹងរបស់ប្រជាពលរដ្ឋលើច្បាប់ គឺជាកត្តាចម្បងដែលអាចបញ្ចៀសបាននូវវិវាទផ្សេងៗដែលកើតមាននៅក្នុងសង្គមបានច្រើន និងជំរុញស្មារតីឱ្យប្រជាពលរដ្ឋគោរព និងអនុវត្តច្បាប់បានត្រឹមត្រូវ។ ប្រព័ន្ធច្បាប់គួរតែមានការផ្សព្វផ្សាយឱ្យបានទូលំទូលាយបំផុត តាមរយៈភូមិ ស្រុក ខណ្ឌ ខេត្ត សាលារៀន តាមទីសាធារណៈជាដើម ដើម្បីកំណត់បានថាប្រជាពលរដ្ឋគ្រប់រូបទទួលបានព័ត៌មានទាំងអស់នោះ និងប្រកាន់ភ្ជាប់ការអនុវត្តឱ្យបានខ្ជាប់ខ្ជួន ជាពិសេសយល់ដឹងបន្ថែមចំពោះបណ្តឹងក្នុងរដ្ឋប្បវេណីគ្រប់ដំណាក់កាល ជា

ពិសេសបណ្ដឹងដែលបានឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដូចជាបណ្ដឹងឧទ្ធរណ៍ បណ្ដឹងជំទាស់ និង បណ្ដឹងសាទុក្ខ ផ្សព្វផ្សាយអំពីលំហូរនីតិវិធីឱ្យកាន់តែច្រើនដែលអាចធ្វើទៅបាន។

កត្តានៃការផ្សព្វផ្សាយតាមរយៈខាងលើ និងជួយសម្រួលដល់បុគ្គលណាដែលមានវិវាទក្នុងរឿងរដ្ឋប្បវេណី ជាពិសេសភាគីនៃបណ្ដឹងសាទុក្ខ អាចជួយឱ្យពួកគាត់យល់ដឹងអំពីលំហូរនីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខ លើកទី១ និងនីតិវិធីនៃការជំនុំជម្រះបណ្ដឹងសាទុក្ខលើទី២ ផងដែរ។ ដូចជា របៀបដាក់ពាក្យបណ្ដឹងសាទុក្ខ របៀប សសេរលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្ដឹងសាទុក្ខ និងបង់ពន្ធប្រាក់ប្រដាប់ក្ដី ធ្វើឱ្យពួកគាត់អាចធ្វើបណ្ដឹងបាន ដោយមិនចាំបាច់ពឹងពាក់មេធាវីជាជួយសម្រួលបន្ទុកចំណាយរបស់ពួកគាត់។

## ២.៣. ការពន្លឿននីតិវិធីរឿងបណ្ដឹងសាទុក្ខ នៅតុលាការកំពូល

ដើម្បីគាំពាភាពយឺតយ៉ាវចំពោះនីតិវិធីបណ្ដឹងសាទុក្ខនៅតុលាការកំពូល គួរមានការជម្រុញ ឱ្យតុលាការ កំពូលធ្វើការជំនុំជម្រះ ចំពោះបណ្ដឹងសាទុក្ខបង្អាការបង្វែលសំណុំរឿងពីតុលាការកំពូល ទៅតុលាការដើមវិនិច្ឆ័យ ឡើងវិញ។ តួយ៉ាងតុលាការកំពូលនៅប្រទេសកម្ពុជា គឺមានតែមួយនៅរាជធានីភ្នំពេញតែបើនិយាយពីសំណុំ រឿងតុលាការមានបន្ទុកច្រើន បែបនេះហើយគួរតែបង្កើតស្ថាប័នតុលាការកំពូលឱ្យមានចំនួនសមរម្យដូចជា តុលាការនៃសាលាឧទ្ធរណ៍ ដើម្បីជាការជួយសម្រួលដល់ការទទួលខុសត្រូវសំណុំរឿងច្រើន ហើយចូលរួមក្នុង ការដោះស្រាយវិវាទនៃបណ្ដឹង។ លើសពីនេះទៅទៀត ជម្រុញឱ្យតុលាការគ្រប់ជាន់ថ្នាក់គួរតែមានការពិនិត្យឱ្យ បានល្អិតល្អន់អំពីអង្គហេតុ និងអង្គច្បាប់នៃវិវាទដែលកើតឡើង ដោយភ្ជាប់ជាមួយសំអាងហេតុឱ្យបានត្រឹមត្រូវ ធ្វើដូច្នេះទើបសាលក្រម ឬសាលដីកាដែលចេញមកមានភាពយុត្តិធម៌ និងសុក្រិតបំផុតសម្រាប់ប្រជាពលរដ្ឋ។ យោងតាមបច្ចុប្បន្នភាពនៃសង្គម សង្កេតថាមានវិវាទកើតឡើងប្រចាំថ្ងៃ ដែលសំណុំរឿងអាចមានការរាំងស្ទះ ឬ ការយឺតយ៉ាវនៃដំណើរការនីតិវិធី។ តួយ៉ាងរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ និងប្រកាសជាសេចក្ដីជូន ដំណឹងឱ្យមានការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីជួយពន្លឿនដល់ដំណើរការនីតិវិធី កុំឱ្យមានភាព យឺតយ៉ាវ។

យោងមាត្រា ៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចែងថាតុលាការត្រូវប្រឹងប្រែង ដើម្បីធានារ៉ាប់រងបណ្ដឹងរដ្ឋប្បវេណី ឱ្យទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្ដឹងរដ្ឋប្បវេណីដោយសុចរិត និងស្មោះត្រង់។ មាត្រានេះសំដៅទៅលើតុលាការ ត្រូវតែយកចិត្តទុកដាក់ទៅលើដំណើរការនីតិវិធីលើវិវាទទាំងអស់ឱ្យមានភាព ឆាប់រហ័ស មិនអូសបន្លាយពេល ហើយត្រូវស្របជាមួយភាពយុត្តិធម៌ដែលប្រជាជនគ្រប់រូបទទួលស្គាល់។ តុលាការមានតួនាទីសំខាន់ក្នុងការអនុវត្តច្បាប់ឱ្យមានតម្លាភាព ដូចដែលមានចែងក្នុងនីតិវិធីក្រមរដ្ឋប្បវេណី មាត្រា ៤ "ការទទួខុសត្រូវរបស់តុលាការ និង ភាគី" តុលាការត្រូវប្រឹងប្រែង ដើម្បីរ៉ាប់រងបណ្ដឹងរដ្ឋប្បវេណីឱ្យ

ប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណីដោយសុចរិត និងស្មោះត្រង់។[76] តុលាការមិនមែនតែមិនត្រូវអនុវត្តនីតិវិធីបណ្តឹងដោយមានភាពយុត្តិធម៌ប៉ុណ្ណោះទេ គឺគប្បីជៀសវាងសម្តី ឬអំពើណាដែលអាចត្រូវសង្ស័យថាមានភាពអយុត្តិធម៌ផងដែរ។ បើយុត្តិធម៌យឺតយ៉ាវប្រៀបដូចជាបដិសេធយុត្តិធម៌។ ដូច្នេះរាល់រឿងក្តីពាក់ព័ន្ធនឹងបណ្តឹងរដ្ឋប្បវេណីមិនថារឿងក្តីអ្វីនោះទេ ភាគីក្នុងរឿងក្តីចង់ឱ្យតុលាការដំណើរការ អនុវត្តនីតិវិធីដោយមានភាពយុត្តិធម៌ រួមទាំងមានភាពឆាប់រហ័សទើបអាចផ្តល់យុត្តិធម៌ដល់ភាគី។ ដូចជាក្នុងរឿងបណ្តឹងសាទុក្ខ ចំពោះនីតិវិធីបញ្ជូនពីសាលាឧទ្ធរណ៍ទៅកំពូល តុលាការដើមត្រូវតែអនុវត្តឱ្យបានឆាប់រហ័សក្នុងការបញ្ជូនសំណុំរឿងពាក្យបណ្តឹងសាទុក្ខទៅកាន់តុលាការនៃបណ្តឹងសាទុក្ខឱ្យឆាប់បំផុត ជៀសវាងការផុតរយៈពេលនៃបណ្តឹងសាទុក្ខ និងទប់ស្កាត់ដល់ភាពអកម្មរបស់តុលាការ។ ដូច្នេះរាល់រឿងក្តីពាក់ព័ន្ធនឹងបណ្តឹងរដ្ឋប្បវេណីមិនថារឿងក្តីអ្វីនោះទេ ភាគីក្នុងរឿងក្តីចង់ឱ្យតុលាការដំណើរការ អនុវត្តនីតិវិធីដោយមានភាពយុត្តិធម៌ រួមទាំងមានភាពឆាប់រហ័សទើបអាចផ្តល់យុត្តិធម៌ដល់ភាគី។ ដូចជាក្នុងរឿងបណ្តឹងសាទុក្ខ ចំពោះនីតិវិធីបញ្ជូនពីសាលាឧទ្ធរណ៍ទៅកំពូល តុលាការដើមត្រូវតែអនុវត្តឱ្យបានឆាប់រហ័សក្នុងការបញ្ជូនសំណុំរឿងពាក្យបណ្តឹងសាទុក្ខទៅកាន់តុលាការនៃបណ្តឹងសាទុក្ខឱ្យឆាប់បំផុត ជៀសវាងការផុតរយៈពេលនៃបណ្តឹងសាទុក្ខ និងទប់ស្កាត់ដល់ភាពអកម្មរបស់តុលាការ។

### ២.៤. ជម្រុញឱ្យដើមបណ្តឹងសាទុក្ខបង់ប្រាក់ប្រដាប់ក្តី និងកាត់បន្ថយចំណាយបន្ទុកសោហ៊ុយច្រើន

បង្កើតនីតិវិធីជម្រុញឱ្យដើមបណ្តឹងសាទុក្ខ បង់ប្រាក់ប្រដាប់ក្តី ឬមានការពន្យាពេលគួរសមណាមួយដើម្បីឱ្យដើមបណ្តឹងសាទុក្ខអាចធ្វើការបង់ប្រាក់ប្រដាប់ក្តីបាន ជៀសវាងការលើកចោលពាក្យបណ្តឹងសាទុក្ខ ហើយបង្កើតច្បាប់ ឬបទដ្ឋានគតិយុត្តណាមួយដែលមានកំណត់ឱ្យបានច្បាស់លាស់នូវប្រាក់ប្រដាប់ក្តីជាពិសេសប្រាក់ប្រដាប់ក្តីក្រៅពីពន្ធគួរអនុវត្តដូចគ្នា និងក្រមនីតិវិធីរដ្ឋប្បវេណីជប៉ុនគឺ មានការកំណត់បានច្បាស់លាស់អំពីប្រាក់ប្រដាប់ក្តី កំណត់អំពីបន្ទុកចំណាយរបស់ភាគី ដើម្បីជាភាពងាយស្រួយដល់ការបង់ពន្ធរបស់ភាគីនៃបណ្តឹងសាទុក្ខ គួរកាត់បន្ថែយបន្ទុកនៃប្រាក់ប្រដាប់ក្តីភាគី។ លើសពីនេះក្នុងករណីដើមបណ្តឹងសាទុក្ខពុំមានផលិតភាពក្នុងការបង់ប្រាក់ប្រដាប់ក្តីទេ ច្បាប់ក៏មានវិធានការសង្គ្រោះបណ្តឹងដែរ ទោះបីការសង្គ្រោះបណ្តឹងច្បាប់មានចែងក៏ពិតមែន តែលុះត្រាតែត្រូវនឹងល័ក្ខខ័ណ្ឌដូចច្បាប់កំណត់ល័ក្ខខ័ណ្ឌសង្គ្រោះលើបណ្តឹងល័ក្ខខ័ណ្ឌដើម្បីទទួលស្គាល់នូវការសង្គ្រោះលើបណ្តឹងគឺ ទី១ គ្មានលទ្ធភាពទ្រព្យធននឹងបង់ប្រាក់ដែលចាំបាច់ដើម្បីរៀបចំ និងប្រព្រឹត្តនៃនីតិវិធីបណ្តឹង ឬអាចមានការលំបាកយ៉ាងខ្លាំងក្នុងការទ្រទ្រង់ជីវភាពដោយសារ ការ

[76] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១,០៦ កក្កដា ២០០៦, មាត្រា ៤ ។

បង់ប្រាក់នេះ ទី២ គឺមិនច្បាស់ជាគ្មានលទ្ធភាពនឹងឈ្នះក្ដី។ ប៉ុន្តែមិនបានកំណត់ឱ្យច្បាស់ទំហំណាទើបអាចចាត់ទុកថាអាចធ្វើការសង្គ្រោះលើបណ្ដឹងត្រង់នេះគួរមានបទបញ្ញត្តិបន្ថែម ឬច្បាប់កំណត់បន្ថែមអំពីការសង្គ្រោះបណ្ដឹងឱ្យបានច្បាស់ជាងនេះទៅទៀត ដើម្បីជាភាពងាយស្រួលចំពោះដើមបណ្ដឹងសាទុក្ខណាដែលគ្មានលទ្ធភាពបង់ប្រាក់ប្រដាប់ក្ដី ជាពិសេសគឺ ប្រាក់ប្រាប់ក្ដីក្រៅពីពន្ធត្រូវធ្វើការកំណត់ឱ្យច្បាស់លាស់ ឬមានកំណត់ក្នុងច្បាប់ដើម្បីកុំឱ្យភាគីមានភាពពិបាកគិតគូររឿងប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធ ហើយក៏បង្កើនដល់ការជឿទុកចិត្តរបស់ប្រជាជនមកកាន់តុលាការផងដែរ ការគិតគូរចំពោះប្រាក់ប្រដាប់ក្ដីក្រៅពីពន្ធក៏ជាការទប់ស្កាត់ដល់ភាពពុករលួយផងដែរ វាជាផ្នែកមួយបង្ការនឹងទប់ស្កាត់។ ក្នុងករណីដែលដើមបណ្ដឹងគ្មានលទ្ធភាពបង់ប្រាក់ប្រដាប់ក្ដី តើចំពោះចំណាយសោហ៊ុយទាំងអស់នោះត្រូវបានកំណត់យ៉ាងដូចម្ដេច? ជាការទទួលខុសត្រូវរបស់ភាគីដែលចាញ់ក្ដី ឬមានល័ក្ខខ័ណ្ឌកំណត់ណាមួយដែលមានច្បាប់ចែង។ ម៉្យាងទៀតក៏មានការចូលរួមពីមេធាវីស្ម័គ្រចិត្តក្នុងការចូលរួមដោះស្រាយក្ដីចំពោះប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតក្នុងការពឹងពាក់មេធាវីសម្រាប់ការដោះស្រាយក្ដីវិវាទ។ ប្រជាពលរដ្ឋអាចពឹងមេធាវីស្ម័គ្រចិត្តក្នុងការដោះស្រាយលើរឿងក្ដីរបស់ខ្លួនដោយមិនមានការចំណាយណាមួយឡើយ។

## ២.៥. ជម្រុញឱ្យភាគីនៃបណ្ដឹងសាទុក្ខដាក់សារណា និងសារណាតប

ការសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខ ពិតជាសំខាន់ដែលនាំឱ្យកើតមានដំណើរការនៃការជំនុំជម្រះក្ដី។ ប្រសិនបើមិនបានសរសេរ នូវមូលហេតុនៃបណ្ដឹងសាទុក្ខ ក្នុងពាក្យបណ្ដឹងសាទុក្ខទេ ដើមបណ្ដឹងសាទុក្ខត្រូវដាក់លិខិតបញ្ជាក់មូលហេតុ នៃបណ្ដឹងសាទុក្ខនេះ ជូនទៅតុលាការនៃបណ្ដឹងសាទុក្ខ ក្នុងអំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីបានការបញ្ជូននូវលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ។ ក្នុងករណីដែលបណ្ដឹងសាទុក្ខធ្វើឡើងដោយបណ្ដឹងសាទុក្ខ ត្រូវសរសេរមូលហេតុនៃបណ្ដឹងសាទុក្ខនេះ ដោយបញ្ជាក់អំពីបញ្ញត្តិ នៃរដ្ឋធម្មនុញ្ញ ឬរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្ត និងហេតុដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬច្បាប់ ឬបទដ្ឋានគតិយុត្តនោះ។ តួយ៉ាងប្រសិនបើដើមបណ្ដឹងសាទុក្ខមិនបានសរសេរមូលហេតុបណ្ដឹងសាទុក្ខទេ តុលាការនៃបណ្ដឹងសាទុក្ខត្រូវលើកចោលបណ្ដឹងសាទុក្ខ ដោយដីកាសម្រេច។ ដូច្នេះប្រសិនបើដើមបណ្ដឹងសាទុក្ខមានភាពពិបាកក្នុងការសរសេរមូលហេតុអំពីបណ្ដឹងសាទុក្ខ គួរតែមានការណែនាំពីមេធាវីដើមបណ្ដឹង ដើម្បីជាជំនួយក្នុងការសរសេរ ឱ្យមានទម្រង់ស្របតាមច្បាប់ផងដែរ។ តុលាការក៏មានការបន្ធូរបន្ថយផងដែរ ចំពោះពាក្យបណ្ដឹងសាទុក្ខណាដែលមានចំណុចខ្វះខាត តុលាការនៃបណ្ដឹងសាទុក្ខត្រូវបង្គាប់ឱ្យធ្វើការកែតម្រូវ ដោយកំណត់អំឡុងពេលសមរម្យ គឺរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីទទួលបានការបញ្ជូនលិខិតទទួលពាក្យបណ្ដឹងសាទុក្ខ។ ប្រសិនបើមិនបានសរសេរនូវ

មូលហេតុនៃបណ្តឹងសាទុក្ខក្នុងពាក្យបណ្តឹងសាទុក្ខទេ ដើមបណ្តឹងអាចសរសេរក្នុងលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខនេះពេលក្រោយបាន។

ដើមបណ្តឹងសាទុក្ខ អាចពឹងពាក់មេធាវី ក្នុងការការពារលើសំណុំរឿងក្តីរបស់ខ្លួនបាន។ ច្បាប់មិនបានហាមថាមិនឱ្យដើមបណ្តឹងសាទុក្ខមិនអាចមិនពឹងពាក់មេធាវីក្នុងសំណុំរឿងក្តីរបស់ខ្លួនបានទេ ព្រោះជាការផ្តល់សិទ្ធិ និងយល់ឃើញថាតែមេធាវី ឬអ្នកចេះច្បាប់ទេ ទើបអាចយល់បានទូលំទូលាយ និងមានចំណេះដឹងខ្ពស់។ តុលាការបើកសិទ្ធិទូលាយចំពោះដើមបណ្តឹងក្នុងការពឹងពាក់មេធាវី ឬការពារក្តីដោយខ្លួនឯងផ្ទាល់បានដែរ។ ម៉្យាងទៀតយើងសង្កេតថា ចំពោះជនក្រីក្រ ក៏អាចពឹងពាក់មេធាវីដោយឥតមានកម្រៃផងដែរ។

នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញបុគ្គលគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ បុគ្គលដែលត្រូវគេប្តឹងក៏មានសិទ្ធិការពារខ្លួនតាមផ្លូវច្បាប់ស្វែងរកយុត្តិធម៌ដូចគ្នា ដូចជារឿងបណ្តឹងសាទុក្ខពេលដែលដើមបណ្តឹងសាទុក្ខបានដាក់ពាក្យបណ្តឹងសាទុក្ខតុលាការនៃបណ្តឹងសាទុក្ខនឹងធ្វើការពិនិត្យ ហើយបញ្ជូនទៅកាន់ចុងបណ្តឹងសាទុក្ខដើម្បីឱ្យចុងបណ្តឹងសាទុក្ខមានពេលវេលាគ្រប់គ្រាន់ក្នុងការដាក់ឯកសារត្រៀមការពារខ្លួន ក្នុងចំណុចករណីចុងបណ្តឹងសាទុក្ខមិនចេះអំពីវិធីដាក់ឯកសារផ្សេងៗ ដើម្បីដោះបន្ទុកខ្លួនទេ គួរមានការណែនាំទៅកាន់ចុងបណ្តឹងសាទុក្ខដើម្បីស្វែងរកមេធាវីការពារក្តី ដែលជាមេធាវីតំណាងដោយអាណត្តិដែលភាគីនៃចុងបណ្តឹងសាទុក្ខត្រូវប្រគល់សិទ្ធិទៅកាន់មេធាវីរបស់ខ្លួន ជៀសវាងការខកខានមិនដាក់សារណាតប បើសិនភាគីនៃចុងបណ្តឹងមិនដាក់សារណាតបទេ វានឹងធ្វើឱ្យការវិនិច្ឆ័យរបស់ចៅក្រមមានភាពលម្អៀងទៅម្ខាង បែបនេះហើយបានច្បាប់តម្រូវឱ្យភាគីទាំងសងខាងត្រូវដាក់ឯកសារត្រៀមរៀងៗខ្លួនដើម្បីជាការដោះបន្ទុក និងថ្លឹងថ្លែងពីភាពត្រឹមត្រូវឱ្យមានតម្លាភាពស្របគ្នាដោយមិនលម្អៀង។

## ២.៦. ការបង្កើតលិខិតបទដ្ឋានគតិយុត្តឱ្យច្បាស់លាស់ និងការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២

ជាក់ស្តែងចំពោះនីតិវិធីនៃបណ្តឹងសាទុក្ខសង្កេតឃើញថា នៅពេលដែលភាគីនៃបណ្តឹងសាទុក្ខដាក់ពាក្យបណ្តឹងទៅតុលាការកំពូលហើយតុលាការកំពូលពិនិត្យយល់ឃើញថាការសម្រេចសេចក្តីរបស់តុលាការសាលាដំបូង ឬសាលាឧទ្ធរណ៍មានភាពផ្ទុយច្បាប់ ឬមាត្រាណាមួយដែលពុំត្រឹមត្រូវ តុលាការកំពូល និងចង្អុលបង្ហាញអំពីចំណុចត្រូវកែតម្រូវ ហើយបង្វែលសំណុំរឿងទៅកាន់តុលាការដើមឱ្យសម្រេចឡើងវិញ ប្រសិនបើសេចក្តីសម្រេចរបស់តុលាការដើមមិនខុសពីការសម្រេចសេចក្តីដំបូងទេ ភាគីមិនសុខចិត្ត និងធ្វើការប្តឹងសាទុក្ខលើកទី២ ទៅតុលាការកំពូល តុលាការកំពូល និងធ្វើការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២។ ប៉ុន្តែចំពោះនីតិវិធីច្បាប់បានកំណត់នីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី១ អំពីលំហូរនីតិវិធីបានយ៉ាងច្បាស់លាស់ តែ

ចំពោះនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ ក៏អនុវត្តដូចគ្នានឹងលើកទី១ដែរ តែការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ តុលាការធ្វើការវិនិច្ឆ័យទាំងអង្គហេតុ និងអង្គច្បាប់តែប៉ុណ្ណោះ។ ហើយចំពោះសមាសភាពចៅក្រមជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ មានដល់ទៅ ០៩ រូប (ប្រាំបួន) វាខុសពីបណ្តឹងសាទុក្ខលើកទី១ ដូច្នេះនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខគឺ មានភាពពិបាកត្រង់ចំណុចនេះគួរមានការកំណត់បទបញ្ញត្តិច្បាប់ ក្រមនីតិវិធីរដ្ឋប្បវេណីនៃបណ្តឹងសាទុក្ខ ឬបទដ្ឋានគតិយុត្តបន្ថែម ដើម្បីធ្វើកំណត់អំពីលំហូរនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ ឱ្យបានច្បាស់លាស់បន្ថែមទៀត។ លើសពីនេះទៅទៀតដើម្បីជាក្បួនច្បាប់ក្រមនីតិវិធីរដ្ឋប្បវេណីត្រង់លំហូរនីតិវិធីនៃកាជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ គួរមានការកែតម្រូវនូវមាត្រាច្បាប់មួយចំនួនដែលមានភាពខ្វះចន្លោះដោយការធ្វើវិសោធនកម្មដែលបន្ថែមខ្លឹមសារមាត្រាច្បាប់ចែងអំពីលំហូរនីតិវិធីបណ្តឹងសាទុក្ខលើកទី២ ដើម្បីងាយស្រួលដល់ការអនុវត្តនីតិវិធីនៃការជំនុំជម្រះក្តីរបស់ចៅក្រម ពីការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី២ ឱ្យមានភាពច្បាស់លាស់ ឬតុលាការកំពូលគួរមានបង្កើតជាយុត្តិសាស្ត្រដើម្បីឱ្យតុលាការជាន់ក្រោមដូចជា តុលាការសាលាដំបូង និងសាលាឧទ្ធរណ៍អាចយកជាគំរូសម្រាប់អនុវត្តផងដែរ ក្នុងការសម្រេចលើរឿងក្តីបណ្តឹងសាទុក្ខលើកក្រោយទៀត។ មួយវិញទៀតប្រសិនបើភាគីនៃបណ្តឹងសាទុក្ខពុំទាន់យល់អំពីនីតិវិធីនៃការជំនុំជម្រះលើកទី២ទេ តុលាការគួរមានការពន្យល់ណែនាំភាគីដើម្បីជាភាពងាយស្រួល និងជាការជួយសម្រួលដល់ភាគីនៃបណ្តឹងសាទុក្ខពុំសូវមានភាពតាមតឹងចំពោះនីតិវិធីនៃការធ្វើបណ្តឹង។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ឆ្លងតាមបកស្រាយបណ្ដឹងសាទុក្ខ គឺជាប្រភេទមួយនៃបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ដែលធ្វើឡើងប្រឆាំង និងសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ ឬសាលាដំបូងរាជធានី/ខេត្ត (ចំពោះករណីដែលភាគីព្រមព្រៀងគ្នាជាលាយលក្ខណ៍អក្សរថាមិនប្ដឹងឧទ្ធរណ៍)។ ជាងនេះទៅទៀត ដើម្បីធ្វើបណ្ដឹងនេះបានត្រឹមត្រូវតាមច្បាប់ និងទទួលបានការវិនិច្ឆ័យពីសំណាក់តុលាការតាមការធ្វើឧបាស្រ័យភាគី លុះត្រាតែបណ្ដឹងនោះបានធ្វើឡើងដោយផ្អែកលើមូលហេតុនៃភាពផ្ទុយនឹងរដ្ឋធម្មនុញ្ញ ច្បាប់ ឬបទដ្ឋានគតិយុត្តិដែលមានឥទ្ធិពលលើសាលក្រមនីតិវិធីរដ្ឋប្បវេណីមានដូចជាតុលាការដែលចេញសាលក្រម ឬសាលដីកាបានចូលរួមក្នុងការចេញសាលក្រម ឬសាលដីកាមានភាពផ្ទុយនឹងបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដាច់មុខ ការខ្វះសិទ្ធិតំណាងដើម្បីធ្វើសកម្មភាពបណ្ដឹង ភាពផ្ទុយនឹងបញ្ញាត្តិស្ដីពីការទាញហេតុផលដោយផ្ទាល់មាត់ និងករណីដែលសាលក្រម ឬសាលដីកានោះគ្មានសំអាងហេតុ ឬសំអាងហេតុនោះផ្ទុយគ្នា។ ម្យ៉ាងទៀតបណ្ដឹងសាទុក្ខច្បាប់ក៏បានបង្កើតឱ្យមានការប្ដឹងសាទុក្ខបានដល់ទៅ៣ ប្រភេទដើម្បីឱ្យភាគីដែលប្ដឹងសាទុក្ខអាចមានសិទ្ធិសម្រេចក្នុងការធ្វើបណ្ដឹងសាទុក្ខក្នុងប្រភេទណាមួយ ដោយភាគីអាចប្ដឹងសាទុក្ខទូទៅ ប្ដឹងសាទុក្ខផ្លោះ និងការធ្វើបណ្ដឹងសាទុក្ខបន្ទាប់បន្សំបានទៀតផង។ ជាងនេះទៀតសោតតុលាការដែលទទួលបានពាក្យបណ្ដឹងសាទុក្ខដោយស្របច្បាប់ត្រូវបង់នូវប្រាក់ប្រដាប់ក្ដីដោយដើមបណ្ដឹងសាទុក្ខ បានបញ្ជូនពាក្យបណ្ដឹងសាទុក្ខទៅតុលាការនៃបណ្ដឹងសាទុក្ខ ហើយតុលាការនៃបណ្ដឹងសាទុក្ខ និងធ្វើការបញ្ជូនលិខិតបណ្ដឹងសាទុក្ខទៅកាន់ចុងបណ្ដឹងសាទុក្ខដើម្បីឱ្យ ចុងបណ្ដឹងសាទុក្ខដាក់នូវឯកសារត្រៀមដោះបន្ទុក។

នៅពេលដែលពាក្យបណ្ដឹងសាទុក្ខ និងសំណុំរឿងត្រូវបានបញ្ជូនមកដល់តុលាការនៃបណ្ដឹងសាទុក្ខ ប្រធានតុលាការត្រូវចេញដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រមចំនួន ០៥ រូប ដែលមានចៅក្រម ០១ រូបធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម។ ក្រោយពីទទួលការចាត់តាំងប្រធានក្រុមប្រឹក្សាចេញដីកាចាត់តាំងចៅក្រមណាម្នាក់ក្នុងក្រុមប្រឹក្សានោះឱ្យធ្វើជាចៅក្រមទទួលបញ្ជា ដើម្បីទទួលបន្ទុកចាត់ការសំណុំរឿងនោះហើយធ្វើរបាយការណ៍វាយតម្លៃលើអង្គច្បាប់ អំពីសេចក្ដីសម្រេច ក្នុងសាលក្រម ឬសាលដីកាដែលតុលាការដើមបានចេញ ហើយត្រូវដាក់ជូនក្រុមប្រឹក្សាជំនុំជម្រះនៃចៅក្រម។ តែទោះជាយ៉ាងនេះក៏ដោយការវាយតម្លៃនេះ មិនចាប់បង្ខំឱ្យក្រុមប្រឹក្សានៃចៅក្រមត្រូវតែសម្រេចតាមការវាយតម្លៃនោះទេ វាគ្រាន់តែជាព័ត៌មាន ឬយោបល់មួយជូនក្រុមប្រឹក្សានៃចៅក្រមប៉ុណ្ណោះ។ នៅក្រោយពេលដែលបាទទួលសំណុំរឿងចៅក្រមទទួលបញ្ជារត្រូវធ្វើការពិនិត្យពាក្យបណ្ដឹងនោះ ហើយចេញដីកាបង្គាប់ឱ្យដើមបណ្ដឹងសាទុក្ខដាក់លិខិតបញ្ជាក់មូលហេតុនៃបណ្ដឹងសាទុក្ខនោះ។

លើសពីនេះទៅទៀតចំពោះសមាសភាពនៃចៅក្រមដែលធ្វើការវិនិច្ឆ័យបណ្ដឹងនេះ មានការប្រែប្រួលទៅតាមនីតិវិធីនៃការជំនុំជម្រះលើបណ្ដឹងនោះ ពោលគឺជំនុំជម្រះបណ្ដឹងសាទុក្ខលើរឿងក្ដីដដែលជាលើកទី២ ត្រូវ

មានចៅក្រមចំនួន ៥ រូប ប៉ុន្តែនៅពេលដែលធ្វើការជំនុំជម្រះបណ្តឹងសាទុក្ខលើរឿងក្តីដដែលជាលើកទី២ ត្រូវមានចៅក្រមចំនួន ០៩ រូប។ ដោយហេតុថាការសម្រេចសេចក្តីរបស់តុលាការកំពូលជាសេចក្តីសម្រេចចុងក្រោយ នោះភាគីមិនអាចធ្វើឧបាស្រ័យទៅតុលាការណាទៀតបានឡើយ ហេតុនេះសាលដីការរបស់តុលាការកំពូលនឹងចូលជាស្ថាពរភ្លាមនៅក្រោយពេលដែលតុលាការកំពូលប្រកាសសាលដីកានោះ។

ជាងនេះទៀតបណ្តឹងសាទុក្ខ ត្រូវធ្វើទៅតុលាការកំពូលដោយផ្អែកលើមូលហេតុមួយ ដែលច្បាប់បានកំណត់ជាក់លាក់។ ផ្ទុយមកវិញបណ្តឹងសាទុក្ខ ក៏អាចត្រូវលើកចោលដោយហេតុថា ជាបណ្តឹងខុសច្បាប់ ឬច្រានចោលដោយសារគ្មានមូលហេតុច្បាស់លាស់តាមផ្លូវច្បាប់ ហើយចំពោះនីតិជំនុំជម្រះក្តីនៃបណ្តឹងសាទុក្ខមិនមាននីតិវិធីត្រៀមសម្រាប់ការទាញផលដោយផ្ទាល់មាត់ទេ។ នៅពេលក្រោយពេលបញ្ចាប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តុលាការត្រូវប្រកាសសម្រាកដើម្បីថយទៅពិចារណា មុនពេលប្រកាសសាលដីកា ឬតុលាការអាចលើកពេលប្រកាសសាលដីកានៅពេលក្រោយក៏បាន សាលដីការបស់តុលាការកំពូលត្រូវចូលជាស្ថាពរភ្លាមក្រោយពេលប្រកាស។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវសិក្សាកន្លងមក ការមើលឃើញសកម្មភាពនៃបណ្តឹងរដ្ឋប្បវេណីនៅកម្ពុជានេះទៀតសោតបច្ចុប្បន្ននេះមានការកើនឡើងជាច្រើន យើងខ្ញុំសង្កេតឃើញថាវិវាទដែលកើតឡើងជារៀងរាល់ថ្ងៃនេះហើយមានស្ថានភាពច្រើនតែពាក់ព័ន្ធទៅរឿងទ្រព្យសម្បត្តិ ញាតិ បងប្អូនបង្កើតទាមទាររឿងទ្រព្យសម្បត្តិគ្នា ប្តីប្រពន្ធដែលអស់មនោសញ្ចេតនានឹងគ្នាប្តឹងគ្នាដើម្បីទាមទារកូនទាមទារទ្រព្យ ឬក៏កូនបំណុលមិនសងប្រាក់ទៅម្ចាស់បំណុល ឬម្ចាស់បំណុលមិនបំពេញកាតព្វកិច្ចចំពោះកូនបំណុល ដែលជាបញ្ហារបស់បុគ្គលឯកជនដែលមានការចង់ឈ្នះគ្នា ដោយហ៊ានចំណាយប្រាក់ជាច្រើនដើម្បីប្តឹងទៅតុលាការស្ទើតែអស់ពីខ្លួនដើម្បីតែចង់ឈ្នះក្តីខ្លះបង្កើតឱ្យក្លាយជារឿងព្រហ្មទណ្ឌទៅទៀតព្រោះតែការមិនស្របគ្នាមិនបំពេញកាតព្វកិច្ចឱ្យគ្នា បង្កទៅជាហិង្សាឬឈានដល់ការសម្លាប់គ្នាក៏មាន គឺនាំឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅដល់ការអភិវឌ្ឍន៍សង្គមជាតិ ទាំងផ្នែកសេដ្ឋកិច្ច ការអប់រំ សណ្តាប់ធ្នាក់សាធារណៈ និងស្ថានភាពផ្លូវចិត្តរបស់ប្រជាពលរដ្ឋ។

បើយើងនិយាយពីរឿងបណ្តឹងរដ្ឋប្បវេណី គឺមានច្រើនដែលចែងនៅក្នុងក្រមរដ្ឋប្បវេណី និងច្បាប់ពិសេសមួយចំនួនទៀត។ ប៉ុន្តែយើងលើកយកតែរឿងក្តីណាដែលនាំឱ្យមានវិវាទរដ្ឋប្បវេណីដែលកើតមានច្រើននៅក្នុងសង្គមមកពិភាក្សាតែប៉ុណ្ណោះ។ ដូចជារឿងបណ្តឹងទាមទារឱ្យផ្តល់តាវកាលិក បណ្តឹងទាមទារឱ្យបញ្ជាក់ និងបណ្តឹងទាមទារឱ្យបង្កើត កែប្រែ ឬរំលត់ទំនាក់ទំនងគតិយុត្ត ដោយស្ថិតនៅក្នុងប្រភេទបណ្តឹងទាំង៣ នេះវាមានច្រើនបបណ្តឹងជាដើម។ បើយើងមើលទៅលើអត្ថបទច្បាប់ដែលបានចែងមក គឺមានលក្ខណៈល្អប្រសើរស្ទើតែគ្រប់ជ្រុងជ្រោយ។ ប៉ុន្តែអ្វីដែលជាបញ្ហា គឺអ្នកអនុវត្តច្បាប់មួយចំនួន គឺការអនុវត្តនៅមានចំណុចខ្វះខាតមិនទាន់បានពេញលេញនៅឡើយ។ ដើម្បីធ្វើឱ្យបណ្តឹងរដ្ឋប្បវេណីប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌ យើងខ្ញុំមាននូវសំណូមពរចំនួន៣៖

**សំណូមពរទី១៖** នៅពេលទទួលបានពាក្យបណ្តឹងសាទុក្ខ ពីភាគីនៃបណ្តឹងសាទុក្ខ សូមឱ្យតុលាការដើមធ្វើការបញ្ជូនពាក្យបណ្តឹងទៅឱ្យមានភាពឆាប់រហ័ស ទៅកាន់តុលាការនៃបណ្តឹងសាទុក្ខ ហើយតុលាការនៃបណ្តឹងសាទុក្ខសូមធ្វើការពិនិត្យបើមានភាពខ្វះខាតទុកពេលវេលាដល់ដើមបណ្តឹងកែតម្រូវ ជៀសវាងការលើកចោលពាក្យបណ្តឹង និងជួយធ្វើការបញ្ជូនឱ្យបានឆាប់ទៅចុងបណ្តឹងសាទុក្ខមានពេលវេលាគ្រប់គ្រាន់ដើម្បីដាក់ឯកសារត្រៀមដើម្បីដោះបន្ទុកខ្លួនឱ្យមានភាពសមស្របគ្នា។

**សំណូមពរទី២៖** ចំពោះប្រព័ន្ធតុលាការក៏គួរតែ ខិតខំធ្វើយ៉ាងណាបង្កើតឱ្យមានចៅក្រមដែលទទួលបន្ទុកជំនុំជម្រះលើរឿងក្តីតែមួយជំនាញបានហើយ ដូចជាចៅក្រមផ្នែករដ្ឋប្បវេណី ផ្នែកព្រហ្មទណ្ឌ ផ្នែកពាណិជ្ជកម្ម ផ្នែកការងារផ្សេងៗគ្នា មិនគួរឱ្យចៅក្រមតែម្នាក់ធ្វើការវិនិច្ឆ័យគ្រប់ជំនាញ ដែលនាំឱ្យមានការសម្រេចសេចក្តីពុំសូវទទួលបាននូវលទ្ធផលល្អ ការបែងចែកបែបនេះក្នុងគោលបំណងដើម្បីធានាថា ការវិនិច្ឆ័យរឿងក្តីនឹងកាន់តែមាន

សុក្រឹតភាពដែលភាគីទាំងសងខាងទទួលយកបាន និងមានការស្ងប់ចិត្តនឹងសេចក្តីសម្រេចនោះ។ ឱ្យចៅក្រម មានភាពងាយស្រួលក្នុងការកាត់ក្តីដែលត្រូវតាមជំនាញខ្លួន ហើយភាគីក៏មានភាពងាយស្រួលក្នុងការធ្វើបណ្តឹង នាំឱ្យរាល់រឿងក្តីមានភាពឆាប់រហ័សមិនកកស្ទះសំណុំរឿងនៅតុលាការ ការអនុវត្តនីតិវិធីច្បាប់ក៏កាន់តែរឹងមាំ ប្រជាជនមានភាពជឿទុកចិត្តមកលើប្រព័ន្ធតុលាការផងដែរ។

**សំណូមពរទី៣៖** សំណូមពរចំពោះប្រាក់ប្រដាប់ក្តី មានការកំណត់ឱ្យច្បាស់លាស់នៃទំហំមួយសមល្មម ដែលភាគីមកពឹងពាក់តុលាការអាចទទួលយកបាន និងកំណត់ប្រាក់ប្រដាប់ក្តីក្រៅពីពន្ធគួរតែដាក់តម្លៃជាក់លាក់ មួយនៅក្នុងច្បាប់ឱ្យហើយ ព្រោះថាស្ថានភាពជាក់ស្តែងចៅក្រមខ្លះកំណត់តម្លៃ ១០០.០០០ (មួយរយពាន់) រៀល រីឯចៅក្រមខ្លះទៀតកំណត់តម្លៃ ២០០.០០០ (ពីររយពាន់) រៀល។ ការកំណត់តម្លៃខុសៗគ្នានេះ ដោយសារ តែគ្មានការកំណត់តម្លៃឱ្យមានលក្ខណៈជាស្តង់ដារនៅឡើយនៅកម្ពុជា ប៉ុន្តែករណីនៅប្រទេសជប៉ុនគេបាន កំណត់ជាស្តង់ដារតែម្តង។ ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ តម្រូវឱ្យភាគីធ្វើការបង់ជាមុនដើម្បីឱ្យតុលាការធ្វើ សកម្មភាពណាមួយ ប៉ុន្តែករណីដែលភាគីមិនបានបង់ទេ នោះតុលាការនឹងមិនធ្វើនូវសកម្មភាពដែលតម្រូវឱ្យបង់ ប្រាក់ប្រដាប់ក្តីនោះឡើយ។

**សំណូមពរទី៤៖** សំណូមពរឱ្យមានការបង្កើតច្បាប់បន្ថែមពាក់ព័ន្ធទៅនឹងការជំនុំជម្រះបណ្តឹងសាទុក្ខ លើកទី២ ឬការបង្កើតបទបញ្ញត្តិច្បាប់ណាមួយដែលមានចែងអំពីលំហូរនីតិវិធីនៃការជំនុំជម្រះបណ្តឹងសាទុក្ខ លើកទី២ ក្នុងរឿងរដ្ឋប្បវេណីឱ្យបានច្បាស់លាស់បន្ថែម ដើម្បីជាភាពងាយស្រួលដល់ការអនុវត្តនីតិវិធីនៃការជំនុំ ជម្រះបណ្តឹងសាទុក្ខក្នុងរឿងរដ្ឋប្បវេណី ដូចជាចៅក្រម ក្រឡាបញ្ជីមន្ត្រីរដ្ឋបាលជាដើមអាចយកមកអនុវត្តអំពីលំហូរ នីតិវិធីបានច្បាស់លាស់ដូចគ្នា និងការជំនុំជម្រះបណ្តឹងសាទុក្ខលើកទី១ ផងដែរ។

# ឯកសារយោង

# ឯកសារយោង

## I. ច្បាប់ និងបទដ្ឋានគតិយុត្ត

១. រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣។

២. ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

៣. ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ២០០៦។

៤. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

៥.សេចក្តីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

៦.រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, សៀវភៅ ស្តីពី ការពន្យល់អំពីនីតិវិធីជម្រះក្តីលើកទី១ បោះពុម្ពលើកទី២ ឆ្នាំ២០០៩។

៧. ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, លេខ នស/រកម/០៧១៤/០១៥, ១៦ កក្កដា ២០១៤។

៨. ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តីនៃរដ្ឋកម្ពុជា, លេខ ០៦ក្រ,០៨កុម្ភៈ ១៩៩៣។

## II. វចនានុក្រម និងសទ្ទានុក្រម

១. កម្មវិធីវចនានុក្រមអេឡិចត្រូនិចរបស់តម្រាច្បាប់ ឆ្នាំ២០២២។

២. សទ្ទានុក្រមច្បាប់ភូមិបាល ឆ្នាំ២០០១។

៣. សទ្ទានុក្រមពាក្យច្បាប់ ខ្មែរ អង់គ្លេស បារាំងផ្នែករដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណីដែលត្រូវរៀបចំដោយគណៈកម្មការបណ្ឌិត្យសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងបោះផ្សាយដោយទីស្តីការគណៈរដ្ឋមន្ត្រីនៅឆ្នាំ២០០៧។

## III. សៀវភៅ និងស្នាដៃនិពន្ធ

នីតិវិធីរដ្ឋប្បវេណី របស់សាស្ត្រាចារ្យ ហេង បូរ៉ា (ឆ្នាំ ២០២៣-២០២៤)។

## IV. ប្រភពផ្សេង

1. បណ្តឹងសាទុក្ខក្នុងរឿងរដ្ឋប្បវេណី ឧទ្ទេសនាមដោយ៖ MR. UCHIYAMA ព្រះរាជអាជ្ញានៃប្រទេសជប៉ុន និងអ្នកជំនាញការនៃក្រមរដ្ឋប្បវេណី និងនិតិវិធីរដ្ឋប្បវេណី បណ្តឹងសាទុក្ខ.pdf ចូលមើលថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៤។
2. https://www.google.com/url?sa=t&rct=j&q=&esrc=s&source=web&cd=&cad=rja&uact=8&ved=2ahUKEwjrzI6k4qiHAxU4UGcHHU4XDx0QFnoECBEQAQ&url=https%3A%2F%2Fwww.jica.go.jp%2Fproject%2Fenglish%2Fcambodia%2F025%2Fmaterials%2

Fc8h0vm0000c54sbn-att%2Fcode_11_02.pdf&usg=AOvVaw0oNmLM6oYfzb_5wR3a42AL&opi=89978449 ចូលមើលថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៤។

3. https://www.google.com/url?sa=t&rct=j&q=&esrc=s&source=web&cd=&ved=2ahUKEwjrzI6k4qiHAxU4UGcHHU4XDx0QFnoECCcQAQ&url=https%3A%2F%2Fwww.khsearch.com%2Fqna%2F10912&usg=AOvVaw1SjijITfBo7wiDp3RsXjbY&opi=89978449 ចូលមើលថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៤។

4. https://www.google.com/url?sa=t&rct=j&q=&esrc=s&source=web&cd=&ved=2ahUKEwjrzI6k4qiHAxU4UGcHHU4XDx0QFnoECCoQAQ&url=https%3A%2F%2Flaw2021.wordpress.com%2F2022%2F07%2F14%2F%25E1%259E%2580%25E1%259F%2592%25E1%259E%259A%25E1%259E%2598%25E1%259E%2593%25E1%259E%25B8%25E1%259E%258F%25E1%259E%25B7%25E1%259E%259C%25E1%259E%25B7%25E1%259E%2592%25E1%259E%25B8%25E1%259E%259A%25E1%259E%258A%25E1%259F%2592%25E1%259E%258B%25E1%259E%2594%25E1%259F%2592%25E1%259E%2594%25E1%259E%259C%25E1%259F%2581-17%2F&usg=AOvVaw3zyIwREUP1GE3Faeqrd5d5&opi=89978449 ចូលមើលថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២៤។

5. https://www.google.com/url?sa=t&rct=j&q=&esrc=s&source=web&cd=&ved=2ahUKEwj0847s4qiHAxUNTGwGHQeFBxEQFnoECBIQAQ&url=https%3A%2F%2Fwww.jica.go.jp%2Fproject%2Fcambodia%2F0701047%2F04%2Fku57pq00001spnva-att%2Fclause02_k.pdf&usg=AOvVaw2ZuuxmCODSxyNSsqs154qf&opi=89978449 ចូលមើលថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៤។

6. https://www.google.com/url?sa=t&rct=j&q=&esrc=s&source=web&cd=&ved=2ahUKEwi9t7aa46iHAxWEZ2wGHWuAC_wQFnoECBMQAQ&url=https%3A%2F%2Ffreshnewsasia.com%2Findex.php%2Fen%2Ffreshnewsplus%2F198762-2021-05-23-06-50-24.html&usg=AOvVaw2RKPyJn-Iz1vNBz9WDOyBp&opi=89978449 ចូលមើលថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២៤។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធ១៖** | ពាក្យបណ្ដឹងសាទុក្ខ |
| **ឧបសម្ព័ន្ធ២៖** | ពាក្យបណ្ដឹងសាទុក្ខបន្ទាប់បន្សំ |
| **ឧបសម្ព័ន្ធ៣៖** | បង្កាន់ដៃប្រាក់ប្រដាប់ក្ដីតុលាការសម្រាប់តុលាការកំពូល |
| **ឧបសម្ព័ន្ធ៤៖** | ដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្ដី |
| **ឧបសម្ព័ន្ធ៥៖** | បង្កាន់ដៃទទួលប្រាក់ |
| **ឧបសម្ព័ន្ធ៦៖** | បង្កាន់ដៃទទួលប្រាក់(សារណាតប) |
| **ឧបសម្ព័ន្ធ៧៖** | ដីកាចាត់តាំងសមាសភាពចៅក្រមក្រុមជំនុំជម្រះ |
| **ឧបសម្ព័ន្ធ៨៖** | ដីកាចាត់តាំង |
| **ឧបសម្ព័ន្ធ៩៖** | ដីកាបង្គាប់ឱ្យដាក់លិខិតបញ្ជាក់អំពីមូលហេតុ នៃបណ្ដឹងសាទុក្ខ |
| **ឧបសម្ព័ន្ធ១០៖** | លិខិតតំណាងដោយអាណត្តិ |
| **ឧបសម្ព័ន្ធ១១៖** | លិខិតប្រគល់សិទ្ធិតំណាងសិទ្ធិតំណាងដោយអាណត្តិ |
| **ឧបសម្ព័ន្ធ១២៖** | ពាក្យស្នើសុំត្រួតពិនិត្យ និងថតចម្លងសំណុំរឿង |
| **ឧបសម្ព័ន្ធ១៣៖** | លិខិតផ្ទេរសិទ្ធិ |
| **ឧបសម្ព័ន្ធ១៤៖** | ដីកាបង្គាប់ឱ្យដាក់ឯកសារត្រៀម(សារណាទប) |
| **ឧបសម្ព័ន្ធ១៥៖** | សារណាតប |
| **ឧបសម្ព័ន្ធ១៦៖** | របាយការណ៍ |
| **ឧបសម្ព័ន្ធ១៧៖** | ដីកាកោះ |
| **ឧបសម្ព័ន្ធ១៨៖** | លិខិតអញ្ជើញ |
| **ឧបសម្ព័ន្ធ១៩៖** | សាលដីកា(កំពូល) |
| **ឧបសម្ព័ន្ធ២០៖** | រូបមន្តអនុវត្តសាលដីកា |
| **ឧបសម្ព័ន្ធ២១៖** | ការណ៍បញ្ជូន។ |

ឧបសម្ព័ន្ធទី១

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹងសាទុក្ខ

**ដើមបណ្តឹងសាទុក្ខ ៖** លោក ............ ជាតិ.... កើតឆ្នាំ ........... និងប្រពន្ធឈ្មោះ .............. មានទីលំនៅបច្ចុប្បន្ន ...........................................................។

**ចុងបណ្តឹងសាទុក្ខ ៖** - លោក.....................ហៅ ............. ជាតិ....... មានទីលំនៅបច្ចុប្បន្ន ..........................................................................................។

- លោក .....................ហៅ ........... ជាតិខ្មែរ អាយុ ៥៨ ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ........................................................... ។

- លោក ...................... ហៅ .................... ជាតិ...... អាយុ ..... ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ...........................................................។

## សូមគោរពជូន

## ឯកឧត្តមប្រធានសាលាឧទ្ធរណ៍

**កម្មវត្ថុ ៖** ប្តឹងសាទុក្ខនឹងសាលដីកាលេខ .................. ចុះថ្ងៃទី...... ខែ........ ឆ្នាំ............ របស់ ......................... ។

**យោង ៖** - ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

- សំណុំរឿងរដ្ឋប្បវេណីលេខ..........ចុះថ្ងៃទី.....ខែ......ឆ្នាំ..........របស់សាលាឧទ្ធរណ៍
- សាលដីកាលេខ.......... ចុះថ្ងៃទី..... ខែ...... ឆ្នាំ.......... របស់សាលាឧទ្ធរណ៍។

តបតាមកម្មវត្ថុ និងយោងខាងលើ យើងខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា កាលពីថ្ងៃទី......ខែ..... ឆ្នាំ.......... សាលាឧទ្ធរណ៍បានចេញសាលដីកាលេខ................ ដែលមានខ្លឹមសារដូចខាងក្រោម ៖

- ទទួលពាក្យបណ្ដឹងឧទ្ធរណ៍លេខ ....... ចុះថ្ងៃទី...... ខែ........ ឆ្នាំ............ របស់មេធាវីឈ្មោះ ........................ អ្នកតំណាងដោយអាណត្តិឲ្យសហចុងចម្លើយឈ្មោះ ........................ ឈ្មោះ ................ និងឈ្មោះ .................... ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។
- លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី.... ខែ....... ឆ្នាំ........... របស់សាលាដំបូង.................ចោលជាអសារបង់ ។
- ច្រានពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ ........................ ចុះថ្ងៃទី..... ខែ....... ឆ្នាំ.......... ចោលជាអសារបង់ ។
- ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។

ការសម្រេចសេចក្ដីខាងលើនេះ គឺពិតជាបានផ្ដល់នូវភាពអយុត្តិធម៌ជាទីបំផុតដល់យើងខ្ញុំ ដែលជាជនរងគ្រោះដោយសារការរំលោភបំពានរបស់ភាគីចុងចម្លើយ ដែលយើងខ្ញុំពុំអាចទទួលយកបានទេ ។

អាស្រ័យហេតុដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្ដមប្រធាន** មេត្តាទទួលយកបណ្ដឹងសាទុក្ខ និងចាត់ការតាមនីតិវិធីច្បាប់ដោយក្ដីអនុគ្រោះ ។

សូម **ឯកឧត្ដមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី.....ខែ...... ឆ្នាំ.........

ស្នាមមេដៃស្ដាំ

........................

ឧបសម្ព័ន្ធទី២

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹងសារទុក្ខ បន្ទាប់បន្សំ

ខ្ញុំបាទឈ្មោះ ហៅ អាយុ ៧៣ឆ្នាំ ជាតិខ្មែរ សញ្ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ភូមិឫស្សីចារ ឃុំថ្មគ្រែ ស្រុកចិត្របុរី ខេត្តក្រចេះ ។

**សូមគោរពចូលមក**

**ឯកឧត្តម ប្រធានសាលាឧទ្ធរណ៍**

**កម្មវត្ថុ:** សំណើសុំប្តឹងសារទុក្ខបន្ទាប់បន្សំលើ សាលដីការដ្ឋប្បវេណីលេខ ១០ក្រIV(ច) ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី ៣ នៃសេចក្តីសម្រេចបញ្ចប់ ។

**យោង:** -មាត្រា ២៧០ , ២៨៦ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

-សំណុំរឿងរដ្ឋប្បវេណីលេខ ៤៣៣ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា ៖ សាលដីការដ្ឋប្បវេណីលេខ ១០ក្រIV(ច) ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ បានយល់ឃើញថា បណ្តឹងតប ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១១ របស់ខ្ញុំបាទ មានលក្ខណៈត្រឹមត្រូវ អាចឱ្យក្រុមប្រឹក្សាពិចារណាបាន ព្រោះភាគីដើមចោទ មិនបានតវ៉ាអំពីបណ្តឹងតបនេះនៅចំពោះមុខសាលាឧទ្ធរណ៍ទេ ដូចមានកំណត់ហេតុទាញហេតុផលផ្ទាល់មាត់ ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១១ របស់សាលាឧទ្ធរណ៍ និងកំណត់ហេតុទាញ ហេតុផលផ្ទាល់មាត់ ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៣ របស់តុលាការកំពូល ស្រាប់ ។

ប៉ុន្តែ សាលាឧទ្ធរណ៍បែរជា មិនសម្រេចអំពីបំណងចិត្តរបស់ខ្ញុំបាទទៅវិញ ដោយយល់ឃើញថា ឈ្មោះ និងឈ្មោះ ជាឪពុក និងកូនបង្កើត មិនបានបង្កការខូចខាតធ្ងន់ធ្ងរទៅវិញ។ ការយល់ឃើញដូច្នេះ មិនត្រឹមត្រូវទេ ព្រោះទោះជាឪពុកនឹងកូនក៏មានការខូចខាតដែរ ពិសេសចំពោះកូនដែលមកប្តឹងយកកេរ្តិ៍តករបស់ឪពុកដែលកំពុងនៅមានជីវិតនេះ បញ្ជាក់អំពីភាពអកត្តញ្ញូ និងភាពឃោរឃៅរបស់កូន ដែលធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់ខ្ញុំបាទយ៉ាងធ្ងន់ធ្ងរណាស់ គឺធ្ងន់ធ្ងរជាងអ្នកដទៃទៅទៀតផង ។

ហេតុដូច្នេះ ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្ញុំបាទ និងក្នុងគោលបំណងអនុវត្តឱ្យបានត្រឹមត្រូវតាមច្បាប់ផង សូមឯកឧត្តម មេត្តាចាត់បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ៤៣៣ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៣ ទៅតុលាការកំពូល ដើម្បីចាត់ការជាសមត្ថកិច្ចតាមច្បាប់ ។

សូមឯកឧត្តម ទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅភ្នំពេញ,ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៤

**ស្នាមមេដៃ**

**បានឃើញ**

លោក ផ្តិតមេដៃចំពោះមុខមេធាវី ។

ភ្នំពេញ,ថ្ងៃទី ០៦ ខែមិថុនា ឆ្នាំ២០១៤

**ហត្ថលេខា និង ត្រា**

មេធាវី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ឧបសម្ព័ន្ធទី៣

**សាលាឧទ្ធរណ៍**

**លេខ:**.............

## បង្កាន់ដៃបង់ប្រាក់ប្រដាប់ក្ដីតុលាការ សម្រាប់តុលាការកំពូល

(យោងលិខិតលេខ........ចុះថ្ងៃទី.......ខែ..........ឆ្នាំ.........របស់តុលាការកំពូល)

- សំណុំរឿងរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី........ខែ..........ឆ្នាំ........របស់សាលាឧទ្ធរណ៍
- សាលាដីការរដ្ឋប្បវេណីលេខ...........ចុះថ្ងៃទី........ខែ........ឆ្នាំ.........របស់សាលាឧទ្ធរណ៍
- ឈ្មោះអ្នកបង់ប្រាក់................................................................................................
- ទីលំនៅ.........ភូមិ........ស្រុក........សង្កាត់/ខណ្ឌ...........រាជធានី/ខេត្ត.......................

ចំនួនទឹកប្រាក់.....................(............)

.- ក្នុងរឿងប្ដឹង...........................................................................................។

រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ......

**នាយកក្រឡាបញ្ជី**

ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

## ដីកាបង្គាប់ឱ្យបង់ប្រាក់ប្រដាប់ក្តី

សំណុំរឿងរដ្ឋប្បវេណី
លេខ ...07...........
ចុះថ្ងៃទី 23.01.2012

យើង ...[illegible]........... ចៅក្រមទទួលបញ្ជារបស់ក្រុមប្រឹក្សាជំនុំជំរះ នៃតុលាការកំពូល
បង្គាប់មកឈ្មោះ ...[illegible]............... ភេទ ...[illegible]... អាយុ ...[illegible]... ឆ្នាំ
អាសយដ្ឋាន៖ ផ្ទះលេខ...[illegible]... ក្រុម/ផ្លូវ..................... ភូមិ...[illegible]... សង្កាត់/ឃុំ...[illegible]...
ខណ្ឌ/ ស្រុក...[illegible]... រាជធានី/ខេត្ត ...[illegible]... មុខរបរ...[illegible]...
ឱ្យមកបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធចំនួន ១០០.០០០ (ដប់ម៉ឺន)រៀល ក្នុងអំឡុងពេល...30...ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូនដីកានេះពាក់ព័ន្ធនឹងបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ...[illegible]...ចុះថ្ងៃទី ...30... ខែ...7... ឆ្នាំ...2011... របស់សាលាឧទ្ធរណ៍ ទៅសភារដ្ឋប្បវេណីនៃតុលាការកំពូល ។

**សំគាល់៖** "បើម្ចាស់បណ្តឹងសាទុក្ខមិនយកប្រាក់មកបង់តាមដីកានេះទេ តុលាការកំពូលនឹងលើកបណ្តឹងសាទុក្ខចោល តាមចំណុច ក មាត្រា ២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី" ។

ភ្នំពេញ, ថ្ងៃទី ...01... ខែ ...[illegible]... ឆ្នាំ 2012
ចៅក្រម

ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខ: 499

## បង្កាន់ដៃទទួលប្រាក់

បានទទួលពីឈ្មោះ [illegible]

នៅឃុំ [illegible] ស្រុក [illegible] ខេត្ត [illegible]

ចំនួនទឹកប្រាក់ 5.000៛

ពីដំណើរ [illegible]

ថ្ងៃទី 07 ខែ 04 ឆ្នាំ 2015

ក្រឡាបញ្ជី

[illegible]

ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខៈ 1563

# បង្កាន់ដៃទទួលប្រាក់

បានទទួលពីឈ្មោះ.................................................

នៅឃុំ [illegible] ស្រុក [illegible] ខេត្ត [illegible]

ចំនួនទឹកប្រាក់ 5000,00-

ពីដំណើរ [illegible]

ថ្ងៃទី 05 ខែ 09 ឆ្នាំ 2015

ក្រឡាបញ្ជី

**ឧបសម្ព័ន្ធទី៧**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
លេខ: 374 ច.ក

## ដីកាចាត់តាំងសមាសភាពជំនុំជំរះ

************

### ប្រធានតុលាការកំពូល

-បានឃើញច្បាប់ ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ដែលប្រកាសអោយប្រើ ដោយក្រឹត្យលេខ ០៦ក្រ. ចុះថ្ងៃទី ០៨-០២-៩៣។

-បានឃើញច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ២១ក្រ ចុះថ្ងៃទី ០៨-៣-៩៣។

### សំរេចចាត់តាំង

១-ឯកឧត្ដម[redacted] ប្រធាន

២-លោក[redacted] ចៅក្រម     ៦-លោក ចៅក្រម

៣-លោក[redacted] ចៅក្រម     ៧-លោក ចៅក្រម

៤-លោក[redacted] ចៅក្រម     ៨-លោក ចៅក្រម

៥-លោក[redacted] ចៅក្រម     ៩-លោក ចៅក្រម

ក្រឡាបញ្ជី......................................

អោយចូលរួមជំនុំជំរះរឿង រដ្ឋប្បវេណី :

១-លេ[redacted]...ចុះថ្ងៃទី 20 ខែ 08 ឆ្នាំ ២០13

២-លេ[redacted]...ចុះថ្ងៃទី 28 ខែ 10 ឆ្នាំ ២០13

៣-លេ[redacted]...ចុះថ្ងៃទី 28 ខែ 11 ឆ្នាំ ២០14

៤- លេ[redacted]...ចុះថ្ងៃទី 15 ខែ 12 ឆ្នាំ ២០14

៥- លេខ[redacted]...ចុះថ្ងៃទី............ខែ....................ឆ្នាំ ២០០.....

នាសវនាការជាសាធារណៈ នៅថ្ងៃទី 18 ខែ ធ្នូ ឆ្នាំ ២០១៥

រាជធានីភ្នំពេញ, ថ្ងៃទី 11 ខែ វិច្ឆិកា ឆ្នាំ ២០១៥

[redacted]

ឧបសម្ព័ន្ធទី៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខ :.............. ធ.ក

# ដីកាចាត់តាំង

*****

## ប្រធានតុលាការកំពូល

សំរេចចាត់តាំងលោក...................................................... ជាចៅក្រមទទួលបញ្ជា

ឱ្យពិនិត្យអំពីទំរង់ និង គតិច្បាប់ នៃ សំណុំរឿងរដ្ឋប្បវេណីលេខ.......................
ចុះថ្ងៃទី ......ខែ...វិច្ឆិកា.......ឆ្នាំ...២០១៤..... របស់តុលាការកំពូល និងសាលដីកាលេខ..២៦៤/៣..ចុះថ្ងៃទី ...២៩..........ខែ...កក្កដា............ឆ្នាំ...២០១៤... របស់សាលាឧទ្ធរណ៍ ហើយធ្វើរបាយការណ៍សន្និដ្ឋានវាយតំលៃលើអង្គច្បាប់ និង ចង្អុលប្រាប់នូវវិធានការដោះស្រាយផ្សេងៗ ដើម្បីដាក់ជូនតុលាការកំពូល ជំនុំជំរះ ។

ភ្នំពេញ, ថ្ងៃទី ...០៥.........ខែ...ធ្នូ.............ឆ្នាំ២០១៤

**ឧបសម្ព័ន្ធទី៩**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី

លេខ .................................

ចុះថ្ងៃទី..........ខែ........ឆ្នាំ២០...

<u>**ដីកាបង្គាប់ឱ្យដាក់លិខិតបញ្ជាក់**</u>
<u>**អំពីមូលហេតុ នៃបណ្តឹងសាទុក្ខ**</u>

យើង ...............................ចៅក្រមទទួលបញ្ជារបស់ក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល បង្គាប់មកលោក-លោកស្រី...............................អាយុ..........ឆ្នាំ មានមុខរបរ............................ អាសយដ្ឋាន: ផ្ទះលេខ..........ក្រុម/ផ្លូវ.............ភូមិ.......................សង្កាត់/ឃុំ ........................ ខណ្ឌ/ស្រុក.........................រាជធានី/ខេត្ត.................................................................... ជាដើមបណ្តឹងសាទុក្ខ ឱ្យធ្វើលិខិតបញ្ជាក់អំពីមូលហេតុនៃ បណ្តឹងសាទុក្ខ ដែលបានប្តឹងពិសាលដីការដ្ឋប្បវេណី លេខ....................ចុះថ្ងៃទី..............ខែ..............ឆ្នាំ..............របស់សាលាឧទ្ធរណ៍ ដាក់ជូនតុលាការកំពូល ក្នុងរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីបានទទួលការបញ្ជូនដីកានេះ ។

<u>**សំគាល់:**</u> "បើដើមបណ្តឹងសាទុក្ខមិនដាក់លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ តាមដីកានេះទេ តុលាការកំពូលនឹងលើកបណ្តឹងសាទុក្ខចោល តាមចំណុចខ មាត្រា ២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី" ។

ភ្នំពេញ ថ្ងៃទី..........ខែ..........ឆ្នាំ..........

ចៅ...

ឧបសម្ព័ន្ធទី១០

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រុមមេធាវី អេច ប៊ី អ និង សហការី
HBR And Associates Law Group
លេខ.................. HBR /.........

**<u>លិខិតតំណាងដោយអាណត្តិ</u>**

ខ្ញុំបាទមេធាវី **ហោង បូរ៉ា** អត្តលេខ៖ ២០២១ ជា**ប្រធានក្រុមមេធាវី អេច ប៊ី អ និង សហការី (HBR AND ASSOCIATES LAW GROUP)** ដែលមានទីស្នាក់ការស្ថិតនៅផ្ទះE59 បុរីរុងរឿង ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

ទូរស័ព្ទទំនាក់ទំនងលេខ: .................................។

**<u>សូមគោរពចូលមក</u>**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*<u>សូមទានជ្រាប!</u>*

**<u>កម្មវត្ថុ:</u>** ស្តីការពីតំណាងដោយអាណត្តិឱ្យឈ្មោះ ......................... ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៖............ ចុះថ្ងៃទី..... ខែ........ឆ្នាំ......... របស់សាលាដំបូងរាជធានីភ្នំពេញ។

**<u>យោង:</u>** - មាត្រា២ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា។
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ .............. ចុះថ្ងៃទី......ខែ....... ឆ្នាំ..........។

តាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា:................ បានប្រគល់សិទ្ធិឱ្យខ្ញុំបាទ ធ្វើជាមេធាវីតំណាងដោយអាណត្តិ នៅក្នុងសំណុំរឿងរដ្ឋប្បវេណី ដូចមានចែងក្នុង កម្មវត្ថុខាងលើ។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រធាន** មេត្តាជ្រាបដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលយកនូវការគោរពរាប់អាន អំពីខ្ញុំបាទ។

ថ្ងៃ...................... ខែ......... ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ,ថ្ងៃទី....... ខែ......... ឆ្នាំ២០២៣

**ហត្ថលេខា និង ត្រា**

ឧបសម្ព័ន្ធទី១១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.........................ភេទ.......អាយុ.........ជនជាតិខ្មែរ សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ:...........................ចុះថ្ងៃទី..........ខែ...........ឆ្នាំ.........មានអាសយដ្ឋានស្ថិតនៅផ្ទះលេខ:.........ផ្លូវ........ភូមិ.......................ឃុំ/សង្កាត់......................ស្រុក/ខណ្ឌ......................រាជធានី/ខេត្ត........................។

## សូមធ្វើការប្រគល់សិទ្ធិជូន

លោកមេធាវី **ហេង បូរ៉ា** អត្តលេខ៖ ២០២១ ជា**ប្រធានក្រុមមេធាវី អេច ប៊ី អ និង សហការី** (HBR AND ASSOCIATES LAW GROUP) ដែលមានទីស្នាក់ការស្ថិតនៅផ្ទះ:E59 បុរីរុងរឿង ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីធ្វើជាអ្នកតំណាងដោយអាណត្តិឲ្យ នាងខ្ញុំ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៖........... ចុះថ្ងៃទី.......... ខែ........... ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ។

ចាប់ពីថ្ងៃផ្តិតមេដៃនេះតទៅ លោក **ហេង បូរ៉ា** នឹងមានសិទ្ធិតំណាងដោយអាណត្តិឲ្យអាណត្តិទាយក និងមានសិទ្ធិអំណាចពេញលេញក្នុងការធ្វើរាល់សកម្មភាពដូចតទៅ:

១.ការដាក់ពាក្យបណ្តឹង ការដកពាក្យបណ្តឹង ការផ្សះផ្សា ការចចារ សម្របសម្រួល ការលះបង់ការទាមទារ ឬការទទួលស្គាល់ការទាមទារ ការឆ្លើយដោះសារចំពោះបណ្តឹង ការចូលរួមអត្តាគមន៍បណ្តឹង។

២.ការដាក់ពាក្យបណ្តឹងតប ការប្តឹងតវ៉ា បណ្តឹងទាស់ បណ្តឹងឧទ្ធរណ៍ បណ្តឹងជំទាស់ បណ្តឹងសាទុក្ខ។

៣.ការចាត់ចែងរក្សាការពារ ការអនុវត្តដោយបង្ខំ ការជ្រើសតាំងអនុតំណាង។

៤.មានសិទ្ធិបញ្ជាក់សាលក្រម ឬសាលដីកាស្ថាពរ ចំតចម្លងសាលក្រម ឬសាលដីកានិងរូបមន្តអនុវត្ត។

៥.ដាក់ពាក្យសុំប្រកាសផ្សាយជាសាធារណៈ និងធ្វើសេចក្តីបញ្ជាក់ដំបូង។

៦.ដាក់សេចក្តីថ្លែងការណ៍ និងលិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ។

៧.ធ្វើគ្រប់សកម្មភាពចាំបាច់សម្រាប់ការការពារក្តី ដោយគោរពផលប្រយោជន៍ស្របច្បាប់និងមានសិទ្ធិដោះស្រាយបញ្ហាជាមួយអាជ្ញាធរ និងតុលាការគ្រប់ជាន់ថ្នាក់។

<u>បញ្ជាក់៖</u> សោហ៊ុយចំណាយលើការបង់ពន្ធផ្សេងៗ នៅក្នុងសំណុំរឿងនេះ គឺជាបន្ទុករបស់នាងខ្ញុំជាអាណត្តិទាយក។ ក្នុងករណីមិនគោរពតាមកាតព្វកិច្ចនេះ នាងខ្ញុំសុខចិត្តទទួលខុសត្រូវនូវរាល់ការបាត់បង់ផលប្រយោជន៍នានាដោយផ្ទាល់។

ថ្ងៃ.........................ខែ..........ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

**បានឃើញ និងយល់ព្រម**

ធ្វើជាមេធាវីតំណាងដោយអាណត្តិឲ្យឈ្មោះ ..................... តាមនីតិវិធីច្បាប់។

ថ្ងៃ...................... ខែ......... ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី........ខែ........... ឆ្នាំ

**ហត្ថលេខា និងត្រា**

រាជធានីភ្នំពេញ, ថ្ងៃទី.......... ខែ.......... ឆ្នាំ២០២៣

**ស្នាមមេដៃស្តាំអាណត្តិទាយក**

........................

ឧបសម្ព័ន្ធទី១២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមមេធាវី អេច ប៊ី អ និង សហការី**
**HBR And Associates Law Group**
**លេខ.................. HBR /.........**

**ពាក្យស្នើសុំពិនិត្យ និងថតចម្លងសំណុំរឿង**

ខ្ញុំបាទមេធាវី **ហេង ប៊ូរ៉ា** អត្តលេខ៖ ២០២១ ជា**ប្រធានក្រុមមេធាវី អេច ប៊ី អ និង សហការី** (**HBR AND ASSOCIATES LAW GROUP**) ដែលមានទីស្នាក់ការស្ថិតនៅផ្ទះE59 បុរីរុងរឿង ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ជាមេធាវីតំណាងដោយអាណត្តិនៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៖ ........ចុះថ្ងៃទី..... ខែ.......ឆ្នាំ.......... របស់សាលាដំបូងរាជធានីភ្នំពេញ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

*សូមមានជ្រាប !*

**កម្មវត្ថុ:** ស្នើសុំពិនិត្យ និងថតចម្លងសំណុំរឿងរដ្ឋប្បវេណីលេខ៖............ចុះថ្ងៃទី......ខែ........ឆ្នាំ ២០២២ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង:** - ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។
- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី.......ខែ........ឆ្នាំ......... របស់ឈ្មោះ............។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមការអនុញ្ញាតអំពី **ឯកឧត្តមប្រធាន** ធ្វើការពិនិត្យ និងថតចម្លងសំណុំរឿងដូចបានជម្រាបជូនខាងលើ ដើម្បីឱ្យខ្ញុំបាទមានលទ្ធភាពបានសិក្សាស្រាវជ្រាវ ការពារផលប្រយោជន៍ស្របច្បាប់ឱ្យកូនក្ដីខ្ញុំបាទ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាតតាមការស្នើសុំដោយសេចក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ស្មោះស្ម័គ្រ អំពីខ្ញុំបាទ។

ថ្ងៃ.......................ខែ................**ឆ្នាំ**ថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី........ខែ .........ឆ្នាំ២០២៣

**ហត្ថលេខា និង ត្រា**

ឧបសម្ព័ន្ធទី១៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមមេធាវី ជាតិ និង អន្តរជាតិ**
NATIONAL AND INTERNATIONAL LAW FIRM
**មេធាវី ខៀវ សុផល**
KHIEV SOPHAL Avocat, Attorney-At-Law

## លិខិតផ្ទេរសិទ្ធិ

ខ្ញុំបាទឈ្មោះ ជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា របត្តលេខ ជាមេធាវីតំណាងដោយអាណត្តិឱ្យលោក ហៅ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ២៣-០១-២០១២ របស់តុលាការកំពូល ។

**សូមគោរពជូន**

**ឯកឧត្តម ប្រធានតុលាការកំពូល ជាទីគោរព !**

**កម្មវត្ថុ** : សំណើផ្ទេរសិទ្ធិជូនលោកមេធាវី ដើម្បីធ្វើសកម្មភាពជំនួសខ្ញុំបាទ ក្នុងនាមជាអ្នកតំណាងឱ្យ លោក ហៅ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ២៣-០១-២០១២ របស់តុលាការកំពូល ។

**យោង** : ពាក្យសុំធ្វើជាមេធាវីតំណាងដោយអាណត្តិ របស់ខ្ញុំបាទ នៅក្នុងសំណុំរឿង ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា: ដោយហេតុថា នៅថ្ងៃទី ២១ និង ២២ ខែឧសភា ឆ្នាំ២០១៣ ខ្ញុំបាទជាប់រវល់ចាំបាច់មិនអាចខកខានបាន ក្នុងការចូលរួមកម្មវិធីសិក្សានៅសាលាភូមិន្ទសារការីនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។ មិនអាចមកចូលរួមសវនាការនៅតុលាការកំពូលបាន ។

ហេតុដូច្នេះ ដើម្បីកុំឱ្យមានការពន្យាពេលនាំឱ្យមានការកកស្ទះសំណុំរឿង ខ្ញុំសូមផ្ទេរសិទ្ធិទៅឱ្យលោកមេធាវី ដើម្បីធ្វើសកម្មភាពជំនួសខ្ញុំបាទ ក្នុងនាមជាអ្នកតំណាងឱ្យលោក តី ឈុនឆាយ ហៅ ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ០៧ ចុះថ្ងៃទី ២៣-០១-២០១២ របស់តុលាការកំពូល ពីថ្ងៃនេះ តទៅ ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើនេះ សូមឯកឧត្តមមេត្តាអនុញ្ញាត និងទទួលស្គាល់លោកមេធាវី ដោយក្តីអនុគ្រោះ ។

សូមឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**បានឃើញ និងយល់ព្រម**

ទទួលសិទ្ធិធ្វើជាមេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ តី ឈុនឆាយ ពិតប្រាកដមែន។

ថ្ងៃទី 20 ខែ... ឆ្នាំ 2013

**មេធាវីទទួលសិទ្ធិ**

មេធាវី.

ធ្វើនៅ... ថ្ងៃទី 20 ខែ... ឆ្នាំ 2013

**មេធាវីផ្ទេរសិទ្ធិ**

ឧបសម្ព័ន្ធទី១៤

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

~~~~~~~~~~

**<u>លិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ</u>**

នាងខ្ញុំឈ្មោះ ជាមេធាវីតំណាងដោយអាណត្តិអោយឈ្មោះ អាយុ ២៨ ឆ្នាំ ជនជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅបច្ចុប្បន្នភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ក្នុងករណី: សុំទាមទារដី-ផ្ទាកទិន និងម៉ូតូ មានសំណុំរឿង ៣៣ ចុះថ្ងៃទី ២៦-មករា-២០១៥ របស់តុលាការកំពូល ។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានតុលាការកំពូល**

**<u>កម្មវត្ថុ:</u>** សុំធ្វើលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹ ឬាជន៏របស់កូនក្តីនាងខ្ញុំក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣ ចុះថ្ងៃទី ២៦-មករា-២០១៥ របស់តុលាការកំពូល ។

**<u>យោង:</u>** -ដីកាបង្គាប់រេ ហេតុនៃបណ្តឹងសារទុក្ខចុះថ្ងៃទី ០៣-កុម្ភៈ-២០១៥ របស់តុលាការកំពូល ។

-សំណុំរឿងរដ្ឋប្បវេណីលេខ ៣៣ ចុះថ្ងៃទី ២៦-មករា-២០១៥ របស់តុលាការកំពូល ។

-ពាក្យតំណាងដោយអាណត្តិចុះថ្ងៃទី ២៦-មិនា-២០១៥ ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមជំរាបជូនឯកឧត្តមប្រធានមេត្តាជ្រាបពីដំណើររឿងដូចខាងក្រោម:

**១-<u>អំពីអង្គហេតុ:</u>**

កូនក្តីនាងខ្ញុំឈ្មោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ នៅក្នុងឆ្នាំ ២០១០ ហើយបានរស់នៅជាមួយគ្នាបានកូនប្រុសម្នាក់ឈ្មោះ អាយុ ០៣ ឆ្នាំ ។ នៅក្នុងរយៈពេលរស់នៅជាមួយគ្នាជាប្តីប្រពន្ធកូនក្តីនាងខ្ញុំបានប្រឹងប្រែងរកស៊ីជាមួយគ្នាបានលុយចំនួន ១១000ដុល្លា ( មួយម៉ឺនមួយពាន់ដុល្លាអាមេរិក ) មកទិញផ្ទះ និងដី ពីបងថ្លៃឈ្មោះ គឺ ដីមានទំហំ ១៦ម គុណ ១១ម រីឯផ្ទះទំហំ ៨ម គុណ ៨.៤ម ស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ។ បន្ទាប់ពីកូនក្តីនាងខ្ញុំបានប្រគល់ប្រាក់ថ្លៃទិញដី និងផ្ទះចំនួន ១១000ដុល្លា (មួយម៉ឺនមួយពាន់ដុល្លាអាមេរិក) មកអោយបងថ្លៃឈ្មោះ គ្រប់ចំនួនហើយ ទើបនាំប្តីប្រពន្ធចូលមករស់នៅលើដី និងផ្ទះនេះរួចកូនក្តីនាងខ្ញុំក៏បានរៀបបន្ទប់ថ្មខាងក្រោមផ្ទះជុំវិញ និងបានតយ៉ាកពីមុខផ្ទះថែមទៀត ។ ការរស់នៅរបស់កូនក្តីនាងខ្ញុំជាមួយប្រពន្ធកូនសុខសាន្តណាស់មិនមានបញ្ហាអ្វីកើតឡើង មិនតែប៉ុណ្ណោះកូនក្តីនាងខ្ញុំនិងប្រពន្ធបានដកប្រាក់រកស៊ីរួមគ្នាយកមកទិញខ្សែកផ្ទាកទីន-ចិញ្ចៀន-កងដៃអោយប្រពន្ធ និងទិញម៉ូតូមួយគ្រឿងម៉ាក C125 សេរី 2008 ពាក់ស្លាកលេខ សំរាប់ប្រើប្រាស់ក្នុងគ្រួសារទៀតផង ( ដូចមានឯកសារក្នុងសំណុំរឿងស្រាប់ ) ។
~~~~~~~~~~

រស់នៅ និងបានសាងសង់សំណង់ជាហូរហែរក៏ពុំដែលមានទំនាស់ ឬការជំទាស់ពីចុងចម្លើយម្តងណាដែរ ដូច្នេះកិរិយានៃការកាន់កាប់របស់ដើមចោទនេះ បានបង្ហាញអោយឃើញថា ដើមចោទបានបំពេញកាតព្វកិច្ចចប់សព្វគ្រប់ជាមួយចុងចម្លើយរួចហើយទើបមិនមានការរារាំងពីចុងចម្លើយ ។

•ចំពោះលិខិតផ្ទេរដីមួយកន្លែងចុះថ្ងៃទី ០៩-កញ្ញា-២០០៥ *( ឯកសារលេខ ៣/១ នៅក្នុងសំណុំរឿងស្រាប់ )* គឺដាក់ថា: ឈ្មោះ បានផ្ទេរដីមួយកន្លែងទៅអោយឈ្មោះ ។ ប៉ុន្តែនៅត្រង់កន្លែងស្នាមមេដៃអ្នកលក់បែរជាដាក់ឈ្មោះ ( ប្តី ) និង ( ប្រពន្ធ ) ហើយនៅត្រង់កន្លែងស្នាមមេដៃអ្នកទិញបែរជាដាក់ឈ្មោះ ។ ដូច្នេះឃើញថា ឈ្មោះអ្នកទិញនៅក្នុងលិខិតនេះ គឺឈ្មោះ មិនមែនជាឈ្មោះរបស់ចុងចម្លើយ ( ) និងប្តីរបស់ចុងចម្លើយ( )នោះឡើយ ។ ដូច្នេះឃើញថា ដី និងផ្ទះដែលកំពុងតែមានវិវាទនេះមិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ និងឈ្មោះ ទេ ។

•ចំណែកឯលិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ ត្រង់កន្លែងស្នាមមេដៃម្ចាស់កម្មសិទ្ធិមានឈ្មោះដល់ទៅចំនួន០៤នាក់ គឺ ឈ្មោះ -ឈ្មោះ -ឈ្មោះ និងឈ្មោះ ។ ប៉ុន្តែនៅផ្នែកអក្សរខាងលើបែរជាដាក់ថា: ម្ចាស់កម្មសិទ្ធិឈ្មោះ និងឈ្មោះ ទៅវិញ ហើយថែមទាំងបញ្ជាក់ទៀតថា: ឈ្មោះ និងឈ្មោះ បានកាន់កាប់ប្រើប្រាស់តាំងពីឆ្នាំ ២០០៩ នៅលើដី និងផ្ទះកំពុងតែមានវិវាទនេះ ។ ចំនុចទាំងអស់នេះបានបង្ហាញអោយឃើញពីភាពមិនប្រក្រតីទៅលើ លិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ *( ឯកសារលេខ ៣/១ នៅក្នុងសំណុំរឿងស្រាប់ )* នូវចំនុចមួយចំនួនដូចខាងក្រោម:

- **ចំនុចទី១:** បើឈ្មោះ និងឈ្មោះ បានកាន់កាប់ប្រើប្រាស់តាំងពីឆ្នាំ ២០០៩ ចុះហេតុអ្វីបានជាមានលិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ ធ្វើតាំងពីឆ្នាំ ២០០៨ គឺមុនមានដីទៅទៀត ?
- **ចំនុចទី២:** នៅក្នុងឆ្នាំ ២០០៨ លោក គឺជាមេភូមិ មេលប់ ចុះហេតុអ្វីបានជាលោក ដែលខ្លួនមិនមែនជាមេភូមិមកចុះហត្ថលេខា ជំនួសលោក ទៅវិញ ?

•តាមលិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ គឺមានដាក់ឈ្មោះ ជាម្ចាស់កម្មសិទ្ធិដែរ ។ ដូច្នេះចំនុចនេះជាភស្តុតាងស៊ីសង្វាក់ ទៅនិងអង្គហេតុដែលកូនក្តីនាងខ្ញុំបានអះអាងថា ខ្លួនទិញដី និង ផ្ទះ ដែលកំពុងតែមានវិវាទនេះពីឈ្មោះ ហើយក៏បានប្រគល់ប្រាក់គ្រប់ចំនួនអោយទៅឈ្មោះ រួចហើយ ។

•ម្យ៉ាងទៀតតាមរបាយការណ៍បំភ្លឺរបស់លោក មេឃុំរកា ចុះថ្ងៃទី ១២-១២-២០១៣ និង របាយការណ៍បំភ្លឺរបស់លោក មេភូមិមេលប់ចុះថ្ងៃទី ១២-១២-២០១៣ សុទ្ធតែបានបញ្ជាក់ដូចគ្នាថា: ឈ្មោះ និងឈ្មោះ បានទិញដីកំពុងមានវិវាទនេះពីឈ្មោះ និងឈ្មោះ កាលពីថ្ងៃទី ០៩ ខែ ០៩ ឆ្នាំ ២០០៥ ។ ប៉ុន្តែការបំភ្លឺនេះផ្ទុយពីលិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ *( ឯកសារលេខ ៣/១នៅក្នុងសំណុំរឿងស្រាប់)* ព្រោះថា តាមឯកសារនេះបានបញ្ជាក់ថា: ឈ្មោះ និងឈ្មោះ បានកាន់កាប់ប្រើប្រាស់តាំងពីឆ្នាំ ២០០៩ មិនបានកាន់កាប់ពីឆ្នាំ ២០០៥ នោះឡើយ ។ ដូច្នេះមានន័យថា: រាល់ឯកសារដែលឈ្មោះ និងឈ្មោះ ធ្វើឡើងនេះ គឺ ដើម្បីបំភ្លៃការពិតទាំងស្រុងធ្វើអោយតុលាការមានការភន្តច្រឡំថាខ្លួនជាម្ចាស់កម្មសិទ្ធិលើដី និងផ្ទះដែលកំពុងតែមានវិវាទនេះ ។ ប៉ុន្តែតាមរយៈឯកសារមិនប្រក្រតីនេះបានបង្ហាញអោយ

ស្រាប់តែនៅថ្ងៃទី ២៦-០៩-២០១៣ ប្រពន្ធរបស់កូនក្តីនាងខ្ញុំឈ្មោះ ក៏បានទទួលមរណៈភាព ។ កូនក្តីនាងខ្ញុំបានធ្វើបុណ្យសព០៧ថ្ងៃប្រពន្ធរួច ស្រាប់តែឪពុកម្តាយក្មេកបានមកដេញកូនក្តីនាងខ្ញុំចេញពីផ្ទះដែលកំពុងតែរស់នៅ ហើយបានយកម៉ូតូ ព្រមទាំងគ្រឿងអលង្ការដែលមានទំងន់ ៩ជី ១ហ៊ុនកន្លះ ជារបស់កូនក្តីនាងខ្ញុំទៅបាត់ ។

ដោយឃើញកូនក្តីនាងខ្ញុំឃើញសកម្មភាពរបស់ឪពុកម្តាយក្មេកចង់បានទ្រព្យសម្បត្តិរបស់ខ្លួនដូច្នេះ ទើបកូនក្តីនាងខ្ញុំបានដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីធ្វើការដោះស្រាយទៅតាមផ្លូវច្បាប់ ។

**២-អំពីអង្គច្បាប់:**

ក/-ចំពោះការទាមទាររបស់កូនក្តីនាងខ្ញុំ: សុំសិទ្ធិគ្រប់ដីមានទំហំ ១៦ម X ១១ម និងផ្ទះទំហំ ៨ម X ៨.៤ម ស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ដោយហេតុថា: ដី និងផ្ទះនេះគឺកូនក្តីនាងខ្ញុំ និងប្រពន្ធ ពិតជាបានទិញពីឈ្មោះ ត្រូវជាបង និងជាបងថ្លៃ ហើយក៏បានប្រគល់ប្រាក់ថ្លៃទិញដីនិងផ្ទះនេះចំនួន ១១០០០ដុល្លា (មួយម៉ឺនមួយពាន់ដុល្លាអាមេរិក) អោយទៅឈ្មោះ គ្រប់ចំនួនរួចហើយ ទើបកូនក្តីនាងខ្ញុំនិងប្រពន្ធមានសិទ្ធិចូលទៅរស់នៅ និង ធ្វើការសាងសង់បន្ទប់ជុំវិញក្រោមផ្ទះទាំងអស់ និងតយ៉ាកខាងមុខផ្ទះ និងសងខាងផ្ទះ ។

+មួយវិញទៀតបន្ទាប់ពីឈ្មោះ បានទទួលប្រាក់ថ្លៃលក់ដី និងផ្ទះពីកូនក្តីនាងខ្ញុំរួចហើយ ក៏បានយកទៅទិញដីនៅឯផ្សារវិញ (ដូចមានចំលើយសាក្សីឈ្មោះ បញ្ជាក់ជូនស្រាប់នៅក្នុងសំណុំរឿង) ហើយចំនុចនេះឈ្មោះ ក៏បានទទួលស្គាល់ដែរថា ខ្លួនពិតជាទិញដីនៅផ្សារពិតមែន (ដូចមានចំលើយបញ្ជាក់ជូនស្រាប់នៅក្នុងសំណុំរឿង) ។

+តាមរបាយការណ៍របស់លោក ជាសមាជិកក្រុមប្រឹក្សាឃុំរកា បានបញ្ជាក់ថា: នៅឆ្នាំ ២០១១ ឈ្មោះ និងប្រពន្ធឈ្មោះ ពិតជាបានទិញផ្ទះ និងដី ព្រមទាំងបានរស់នៅលើផ្ទះនោះរហូតពុំដែលមានបញ្ហាអ្វីឡើយ ថែមទាំងបានធ្វើបន្ទប់គេង បន្ទប់ទឹកខាងក្រោមផ្ទះ នឹងតយ៉ាបចាប់ដែកនៅខាងមុខនិងសងខាងផ្ទះដោយពុំមានអ្នកណាមករាំងស្ទះឡើយ *(ដូចមានឯកសារលេខ ៧/១ នៅក្នុងសំណុំរឿងស្រាប់)* ។

+តាមរបាយការណ៍របស់លោក ជាអនុភូមិមេលប់ បានបញ្ជាក់ថា: នៅថ្ងៃទី ២០-០៧-២០១១ ឈ្មោះ បានលក់ដី និងផ្ទះអោយទៅឈ្មោះ និងប្រពន្ធឈ្មោះ ពិតមែន។ ហើយក្នុងចន្លោះឆ្នាំ ២០១១ រហូតដល់ឆ្នាំ ២០១៣ ឈ្មោះ និងប្រពន្ធឈ្មោះ បានកសាងបន្ទប់ក្រោមផ្ទះយ៉ាងធំ តម្លើងដោយដែកប្រក់សង្ក័សី នៅក្នុងភូមិប្រជាពលរដ្ឋជាទូទៅគេដឹងលឺថា ពិតជាបានលក់ទិញមែន *(ដូចមានឯកសារលេខ ៧/១ និងឯកសារលេខ ៦/១ ដល់ ៦/៨ នៅក្នុងសំណុំរឿងស្រាប់)* ។

+ចំពោះភស្តុតាងដើម្បីបញ្ជាក់អំពីការប្រគល់.ទទួលប្រាក់ ក្នុងការទិញ.លក់ដី និងផ្ទះ ដែលជាចំនុចវិវាទនេះ គឺមិនមានជាលាយលក្ខ័អក្សរមែន។ ប៉ុន្តែតាមអង្គហេតុចុងចម្លើយបានទទួលស្គាល់ថាពិតជាមានការទិញ.លក់មែន ហើយចុងចម្លើយក៏ទទួលស្គាល់ទៀតថា បានទទួលប្រាក់ចំនួន ១០០០ដុល្លា (មួយពាន់ដុល្លាអាមេរិក) ពីដើមចោទ ដោយគ្រាន់យកលេះថា ដើមចោទមិនទាន់អោយប្រាក់គ្រប់ចំនួន ។ ដូច្នេះបើភាគីចុងចម្លើយបានទទួលស្គាល់ថា មានការទិញ.លក់ មានការប្រគល់ប្រាក់ នេះជាអង្គហេតុពិត ហើយចំពោះចុងចម្លើយអះអាងថា មិនទាន់បានទទួលប្រាក់គ្រប់ចំនួន គឺមិនអាចអោយជឿបាន ព្រោះថា ដើមចោទមិនបានទទួលស្គាល់នូវអង្គហេតុនេះទេ ម្យ៉ាងផ្ទះ និងដីគឺដើមចោទបានចូលទៅ

ឃើញថា មានការឃុបឃិតគ្នារវាងឈ្មោះ និងឈ្មោះ ជាមួយអាជ្ញាធរ ដើម្បីកសាងឯកសារទាំងនេះឡើងទាញយកប្រយោជន៍ពីកូនក្តីនាងខ្ញុំតែប៉ុណ្ណោះ ។

**ខ/-** ចំពោះការទាមទាររបស់កូនក្តីនាងខ្ញុំៈ សុំយកម៉ូតូមួយគ្រឿងម៉ាកសេ ១២៥ សេរីឆ្នាំ ២០០៨ ពីភាគី ចុងចម្លើយវិញ នោះ គឺ ជាការត្រឹមត្រូវ ព្រោះថាៈ តាមលិខិតរបស់មន្ទីរសាធារណៈការ និង ដឹកជញ្ជូនខេត្តព្រៃវែងលេខ ១៣០/២០១៤ ស.ក.ពវ ចុះថ្ងៃទី ២០-មិនា-២០១៤ បានបញ្ជាក់យ៉ាងច្បាស់ថាៈ ម៉ូតូមួយគ្រឿងម៉ាក C125 សេរី 2008 ពាក់ស្លាកលេខ B1-6540 គឺ ជាកម្មសិទ្ធិរបស់ឈ្មោះ ។

**គ/-** ចំពោះការទាមទាររបស់កូនក្តីនាងខ្ញុំៈ សុំយកមាសផ្លាកទីនរួមមាន ខ្សែក ចិញ្ចៀន និងកងដៃទម្ងន់សរុប ៩ ជី ២ហ៊ុន ពីភាគីចុងចម្លើយវិញ នោះ គឺជាការត្រឹមត្រូវ ព្រោះថាៈ មានវិក័យប័ត្រដែលដើមចោទ និងប្រពន្ធឈ្មោះ ជាអ្នកទិញក្នុងអំឡុងពេលរស់នៅជាមួយគ្នា *( មានឯកសារក្នុងសំណុំរឿងស្រាប់ )* ។

**៣-<u>អំពីការសំរេចសេចក្តីរបស់តុលាការៈ</u>**

**ក/-ចំពោះការសំរេចសេចក្តីរបស់សាលាដំបូងខេត្តព្រៃវែងៈ** តាមអំណាចសាលក្រមលេខ ០២ ( ខ ) ចុះថ្ងៃទី ២៦-០៣-២០១៤ ដោយប្រគល់ៈ ដីមានទំហំ ១៦ម X ១១ម និងផ្ទះទំហំ ៨ម X ៨.៤ម ស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង - ម៉ូតូមួយគ្រឿងម៉ាក C125 សេរី 2008 ពាក់ស្លាកលេខ និង ខ្សែក ចិញ្ចៀន និងកងដៃទម្ងន់សរុប ៩ ជី ២ហ៊ុន អោយមកឈ្មោះ ជាដើមចោទវិញ គឺជាការសំរេចសេចក្តីប្រកបដោយភាពយុត្តិធម៌បំផុតហើយ ព្រោះថាៈ តាមការបង្ហាញក្នុងចំនុចទី២អំពីអង្គច្បាប់ខាងលើ បានបញ្ជាក់ថាៈ ឈ្មោះ ពិតជាជាកម្មសិទ្ធិលើទ្រព្យសម្បត្តិទាំងអស់នេះពិតប្រាកដមែន ហើយចុងចម្លើយគ្មានឯកសារជាក់លាក់ណាមួយដើម្បីបង្ហាញជូនតុលាការឡើយ ។ មួយវិញទៀតរាល់ឯកសារដីដែលចុងចម្លើយយកមកធ្វើជាភស្តុតាង គឺមានភាពមិនប្រក្រតីយ៉ាងច្រើន និងមិនអាចអោយជឿបានទេ ។

**ក/-ចំពោះការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍ៈ** តាមអំណាចសាលដីកាលេខ ០៤ ( ក្រ IV សស ) ចុះថ្ងៃទី ១៥-០៥-២០១៤ ដោយទទួលស្គាល់ពាក្យបណ្តឹងតបចុះថ្ងៃទី ២២-ធ្នូ-២០១៣ របស់ចុងចម្លើយ ដោយអោយឈ្មោះ ចុះចេញពីផ្ទះនិងដីទំនាស់នោះគឺជាការមិនត្រឹមត្រូវឡើយ ដោយហេតុថាៈសាលាឧទ្ធរណ៍មិនបានពិនិត្យនិងពិចារណាលើអង្គហេតុដែលភាគីចុងចម្លើយទទួលស្គាល់ថា ពិតជាមានការទិញលក់ដី និងផ្ទះ ព្រមទាំងមានការប្រគល់. ទទួលប្រាក់ថ្លៃទិញផ្ទះ ហើយក៏មិនបានពិនិត្យ និងពិចារណាទៅលើភាពមិនប្រក្រតីពាក់ពន្ធ័និងឯកសាររបស់ចុងចម្លើយយកមកបង្ហាញជូនតុលាការដូចជាៈ លិខិតផ្ទេរដីមួយកន្លែងចុះថ្ងៃទី ០៩-កញ្ញា-២០០៥ *( ឯកសារលេខ ៣/១ នៅក្នុងសំណុំរឿងស្រាប់)* - លិខិតបញ្ជាក់កម្មសិទ្ធិចុះថ្ងៃទី ២៤-១២-២០០៨ *( ឯកសារលេខ ៣/១ នៅក្នុងសំណុំរឿងស្រាប់)* របាយការណ៍បំភ្លឺរបស់លោក មេឃុំរកា ចុះថ្ងៃទី ១២-១២-២០១៣ និងរបាយការណ៍បំភ្លឺរបស់លោក មេភូមិមេលប់ចុះថ្ងៃទី ១២-១២-២០១៣ ដូចបានបង្ហាញជូន "**ត្រង់ចំនុចអង្គច្បាប់**" ខាងលើនេះឡើយ ។

ម៉្យាងទៀតចំពោះការសំរេចរបស់សាលាឧទ្ធរណ៍ ច្រានចោលនូវការទាមទាររបស់ដើមចោទ ដែលអោយចុងចម្លើយធ្វើការប្រគល់គ្រឿងអលង្ការរួមមានៈ ខ្សែក ចិញ្ចៀន និង កងដៃ ទម្ងន់សរុប ៩ ជី ២ហ៊ុន ដោយផ្អែកតាមការអះអាងរបស់ចុងចម្លើយថា ខ្លួនលក់ព្យាបាលកូន និងធ្វើបុណ្យសពអស់ហើយ ជាការពុំត្រឹមត្រូវទេ ព្រោះថាៈ ដើមចោទ

ជាអ្នកមើលថែ និងព្យាបាលជំងឺរបស់ប្រពន្ធ ហើយការចំណាយធ្វើបុណ្យសពនិងព្យាបាលជំងឺនោះដើមចោទជាអ្នកចាត់ចងដែរ ព្រោះថាដើមចោទមានមុខរបរ ។ម្យ៉ាងទៀតចុងចម្លើយគ្មានសិទ្ធិអ្វីមកធ្វើការចាត់ចែងលក់ដូរទ្រព្យសម្បត្តិរួមរបស់ដើមចោទឡើយ ប្រសិនបើមានការលក់គ្រឿងអលង្ការទាំងអស់នេះមែនក៏ទុកសិទ្ធិអោយដើមចោទជាអ្នកលក់ដែរមិនមែនចុងចម្លើយជាអ្នកលក់នោះទេ ។ ជាពិសេសទៅទៀតភាគីចុងចម្លើយគ្មានភាពស្មោះត្រង់បង្ហាញការពិតឡើយ គឺចង់បានទ្រព្យសម្បត្តិរបស់ដើមចោទ ព្រោះថា ដើមចោទបានអះអាងថា គ្រឿងអលង្ការខ្លួនជាអ្នកទិញអោយកូនស្រីឈ្មោះ , តាំងពីមិនទាន់រៀបការ ចំណែកឯម៉ូតូក៏ខ្លួនជាអ្នកទិញដែរ ប៉ុន្តែនៅពេលដែលដើមចោទបានបង្ហាញឯកសារពាក់ពន្ធ័និងគ្រឿងអលង្ការ និងឯកសារម៉ូតូ ឃើញថា អះអាងរបស់ចុងចម្លើយគឺភូតកុហកតុលាការ ទាំងស្រុង ។ ដូច្នេះការសំរេចសេចក្តីរបស់សាលាឧទ្ធរណ៍គប្បីពិនិត្យទៅលើចំនុចទាំងអស់នេះ និងលើឯកសារដែលបានលើកក្នុងចំនុចអង្គច្បាប់ខាងលើ ទើបការសំរេចសេចក្តីអាចផ្តល់នូវភាពយុត្តិធម៌សំរាប់កូនក្តីនាងខ្ញុំបាន ។

**៣-<u>សំណូមពរ</u>**

សូមឯកឧត្តមប្រធានមេត្តាសំរេចសេចក្តី ច្រានចោលសាលដីកាលេខ 0៤ ( ក្រ IV សស ) ចុះថ្ងៃទី១៥-0៩-២0១៤ របស់សាលាឧទ្ធរណ៍ រួចធ្វើការសំរេចសេចក្តីមិនបង្វិល ដោយដំកល់ទុកនូវ សាលក្រមលេខ 0២ ( ខ ) ចុះថ្ងៃទី២៦-0៣-២0១៤ របស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការពេញទាំងមូលដដែល ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមឯកឧត្តមប្រធាមមេត្តាទទួលនូវការស្នើសុំរបស់នាងខ្ញុំក្នុងនាមជាមេធាវីតំណាងដោយអាណត្តិដោយក្តីអនុគ្រោះ ។

សូមឯកឧត្តមប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

ធ្វើនៅថ្ងៃទី 0៧ ខែ មេសា ឆ្នាំ ២0១៥

**ហត្ថលេខានិងត្រា**

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

ឧបសម្ព័ន្ធទី១៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

**ដីកាបង្គាប់ឱ្យដាក់ឯកសារត្រៀម (សារណាតប)**

សំណុំរឿងរដ្ឋប្បវេណី

លេខ ......33......................

ចុះថ្ងៃទី....6...ខែ..01..ឆ្នាំ២០.15

យើង ........................................ចៅក្រមទទួលបញ្ហារបស់ក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល បង្គាប់មកលោក-លោកស្រី...................................អាយុ............ឆ្នាំ មានមុខរបរ................. អាសយដ្ឋាន: ផ្ទះលេខ...........ក្រុម/ផ្លូវ..............ភូមិ...................សង្កាត់/ឃុំ ......................... ខណ្ឌ/ស្រុក.........................រាជធានី/ខេត្ត.................................................................... ជាចុងបណ្តឹងសាទុក្ខ ឱ្យដាក់ឯកសារត្រៀមឆ្លើយតបទៅនឹងមូលហេតុនៃបណ្តឹងសាទុក្ខដែលភ្ជាប់មកជាមួយនេះ របស់.............................................ជូនតុលាការកំពូល ក្នុងអំឡុងពេល..30.....ថ្ងៃបន្ទាប់ពីបានទទួលការបញ្ជូនដីកានេះ ។

ភ្នំពេញ ថ្ងៃទី.......ខែ..........ឆ្នាំ.2015.

ជូនភ្ជាប់ជាមួយនូវ ៖

-លិខិតបញ្ជាក់មូលហេតុនៃបណ្តឹងសាទុក្ខ

ឧបសម្ព័ន្ធទី១៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

—

**<u>សារណាតប</u>**

នាងខ្ញុំឈ្មោះ ស្នាក់នៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ... ក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ របស់តុលាការកំពូល ។

**សូមគោរពជូន**

**ឯកឧត្តម ប្រធានតុលាការកំពូល**

**<u>កម្មវត្ថុ</u>:** ស្តីពីសារណាតបទៅនឹងមូលហេតុនៃបណ្តឹងសាទុក្ខក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ៣៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ របស់តុលាការកំពូល ។

**<u>យោង</u>:** ដីកាបង្គាប់ឲ្យដាក់ឯកសារលេខ ១/៥ ចុះថ្ងៃទី 28 ខែមករា ឆ្នាំ 2015 របស់តុលាការកំពូល

តបតាមកម្មវត្ថុ និង យោងខាងលើ នាងខ្ញុំសូមគោរពជំរាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ដីកោះដីទំហំ១៨,៥០ម៉ែត្រ គុណ ១៦,៥០ម៉ែត្រ ឋិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង គឺ នាងខ្ញុំបានទិញពីលោក ឈ្មោះពេញ និង ប្រពន្ធឈ្មោះ ឈ្មោះពេញ តាំងពីថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៥ មកម៉្លេះ ដូចមានលិខិតផ្ទេរដីមួយកន្លែង ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៥ ចុះហត្ថលេខាដោយ មេឃុំរកា ជាភស្តុតាង ។ ឯផ្ទះថ្មក្រោម ឈើលើ នាងខ្ញុំ និង ប្តីនាងខ្ញុំ ជន ដួត ពិតជាបានសាងសង់ តាំងពីឆ្នាំ២០០៨ ពិតប្រាកដមែន ដែលមានលិខិតបញ្ជាក់កម្មសិទ្ធិលេខ១៧៦៧/២០០៨ ចុះថ្ងៃទី២៤ ខែ១២ ឆ្នាំ២០០៨ ចុះហត្ថលេខា ដោយលោកមេឃុំរកា ផងដែរ ឯស្នាមមេដៃដែលមានឈ្មោះ និង ឈ្មោះ គឺ យើងខ្ញុំមានគំរោងផ្ទេរឱ្យអ្នកទាំងពីរនាក់នេះ តែជាក់ស្តែង អ្នកទាំងពីរនាក់មិនយកទេ ហើយក៏មិនស្នាក់នៅដែរ ហើយយើងខ្ញុំក៏នៅតែជាម្ចាស់កម្មសិទ្ធិលើដី និង ផ្ទះនេះ រហូតដល់បច្ចុប្បន្ន។ ចំណែកនៅក្នុង លិខិតបញ្ជាក់កម្មសិទ្ធិខាងលើ ត្រង់ចំនុច " កាន់កាប់ប្រើប្រាស់តាំងពីឆ្នាំ២០០៩ " ជាកំហុសអក្ខរាវិរុទ្ធ ដែលតែងតែកើតមាន នៅក្នុងឯកសាររបស់អាជ្ញាធរ អ្វីដែលសំខាន់គឺ ឯកសារទាំងនោះ មិនមែនក្លែងបន្លំ ឬ ជាឯកសារក្លែងក្លាយ និង ជាអង្គហេតុពិត ។ម្យ៉ាងទៀត កូននាងខ្ញុំឈ្មោះ និង ឈ្មោះ បានរៀបការនៅឆ្នាំ២០១០ នេះទេ ហើយអ្នកទាំងពីរប្តីប្រពន្ធ ទើបតែមកស្នាក់នៅលើដី-ផ្ទះទំនាស់ នៅឆ្នាំ២០១២ ដោយនៅក្នុងផ្ទះមានបន្ទប់ថ្មដែលនាងខ្ញុំធ្វើរួចជាស្រេច ជាការចំណាយរបស់នាងខ្ញុំទាំងអស់ ។ ឯយ៉ាបមុខផ្ទះ ដែលកូននាងខ្ញុំ និង ឈ្មោះ ទើបតែក្នុងឆ្នាំ២០១៣ គឺ អាចដោះបាន ហើយ លោក ដោះយកទៅវិញចុះ ។ លើសពីនេះទៅទៀត ការអះអាងរបស់ឈ្មោះ ដែលថាបានទិញដី-ផ្ទះ ពីឈ្មោះ គឺ មិនមានឯកសារផ្ទេរសិទ្ធិពីឈ្មោះ ទៅ ដែរ ហើយក៏មិនមានឯកសារទិញលក់ដី-ផ្ទះ មិនមានឯកសារប្រគល់ទទួលលុយ ជាពិសេស សាម៉ីខ្លួន ឈ្មោះ ក៏មិនបានបញ្ជាក់ថា លក់ ដី-ផ្ទះ នេះ ឱ្យទៅ ឈ្មោះ ដែរ ។ បើតាមរបាយការណ៍របស់លោក មេភូមិមេលប់ គោរពជូន អនុប្រធានតុលាការខេត្តព្រៃវែង គឺ ការអះអាងរបស់ឈ្មោះ ទេ ដែលមិនគួរឱ្យជឿទុកចិត្តបាន ដោយ នៅពេលសម្រុះសម្រួលនៅថ្នាក់ឃុំ ឈ្មោះ បានឆ្លើយ

...ក៏តុលាការចាត់ៈ បានប្រគល់ប្រាក់8000$ នៅសល់3000$ទៀត ហើយលុយ8000$ ឱ្យថ្លៃផ្ទះនេះ គឺ ខ្លួនបានមកពី រកស៊ីចង ការប្រាក់ និង លក់មាស។ តែពេលមេភូមិចុះស្រាវជ្រាវដល់កូនបំណុល គេថា គេចងការពី នាងខ្ញុំទេ ។ ចំណែកមាស មិនដឹង លក់ឱ្យ ជាងណាទេ ។ ដូចនេះ ទាក់ទង ដី-ផ្ទះ ពិតជាកម្មសិទ្ធិរបស់យើងខ្ញុំពិតប្រាកដ មិនមែនជាកម្មសិទ្ធិរបស់ឈ្មោះ ឡើយ ។

ចំណែកម៉ូតូហុងដា C125 ផលិតឆ្នាំ២០០៨ និង ខ្សែក ផ្លាកទីន ចិញ្ចៀន កងដៃ គឺ នាងខ្ញុំជា អ្នកចំណាយលុយទិញទាំងអស់ ។ ម៉ូតូនេះ ក្នុងឆ្នាំ២០០៨ នាងខ្ញុំទិញត ក្នុងតំលៃ1.300$ ពីឈ្មោះ ដែលទើបតែប្រើប្រាស់ និង ទិញបានតែជាងមួយខែ ។ ក្រោយមក កូននាងខ្ញុំបានភ្ជាប់ពាក្យជាមួយឈ្មោះ នាងខ្ញុំក៏ឱ្យលុយទៅឈ្មោះ ១០ម៉ឺនរៀល និង អត្តសញ្ញាណរបស់នាងខ្ញុំ ឱ្យទៅធ្វើ កាតគ្រីម៉ូតូឱ្យនាងខ្ញុំ ហើយកូនស្រីនាងខ្ញុំ និង ឈ្មោះ ប្រើប្រាស់រហូតមក តែនាងខ្ញុំទើបតែដឹងនៅពេលមានទំនាស់កើតឡើង ថា ម៉ូតូត្រូវបានដាក់ឈ្មោះ ទៅវិញ ។ ឯខ្សែក ផ្លាកទីន ចិញ្ចៀន កងដៃ ទំងន់០៥ជី ០១ហ៊ុន នាងខ្ញុំលក់បាន ***២លាន៨ម៉ឺនរៀល*** សំរាប់ព្យាបាលជំងឺរបស់កូនស្រីនាងខ្ញុំឈ្មោះ ដែលស្ថិតក្នុងស្ថានភាពធ្ងន់ធរ អស់ ***២លាន៥០ម៉ឺនរៀល*** ហើយខាតលើចំណាយបុណ្យសព និង បុណ្យ០៧ថ្ងៃ ***អស់១លាន៥០ម៉ឺន*** រៀល និង ខាតលើបុណ្យ១០០ថ្ងៃ អស់០២លាន៥០ម៉ឺនរៀល ។ ចំណែកឯលោក វិញ ថ្លៃព្យាបាលជំងឺប្រពន្ធក៏មិនជួយចេញអ្វីទាំងអស់ ហើយ ចំណាយធ្វើបុណ្យក៏មិនចំណាយអ្វីដែរ ។

អាស្រ័យហេតុនេះ ការសម្រេចសេចក្តីរបស់សាលាឧទ្ធរណ៍ តាមរយៈសាលដីកាលេខ០៤ (ក្រ IV សស) ចុះថ្ងៃទី១៥ ខែ០៩ ឆ្នាំ២០១៤ គឺ នាងខ្ញុំអាចទទួលយកបានហើយ ដោយនាងខ្ញុំ សំណូមពរ **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និង សំរេចតម្កល់សាលដីកាសាលាឧទ្ធរណ៍នេះដដែល ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ និង ថ្លែងអំណរគុណអំពីនាងខ្ញុំ ។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៥

ស្នាមដៃស្តាំ

ឧបសម្ព័ន្ធទី១៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី

លេខ: ៣៣

ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥

## របាយការណ៍

តាមដីកាចាត់តាំងលេខ ៤៦ច.ត ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកឧត្តមប្រធាន តុលាការកំពូល ឲ្យពិនិត្យអំពីទម្រង់និងគតិច្បាប់នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ របស់តុលាការកំពូល និងសាលដីការដ្ឋប្បវេណីលេខ ០៤ក្រ.IV.សស ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍រាជ៖

**ដើមចោទ:** លោក ( (ជាដើមបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៨ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើស្រែ មានទីលំនៅសព្វថ្ងៃ ភូមិមេលប់ ឃុំរការ ស្រុកពារាំង ខេត្តព្រៃវែង។

មានអ្នកតំណាងដោយអាណត្តិលោកស្រី មេធាវី

**ចុងចម្លើយ:** ឈ្មោះ (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី និងប្តីឈ្មោះ អាយុ៤៩ឆ្នាំ មុខរបរធ្វើស្រែ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃភូមិ មេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ។

មានអ្នកតំណាងដោយអាណត្តិលោកមេធាវី

**កម្មវត្ថុបណ្តឹង:** ប្តឹងទាមទារដីភូមិទំហំ ១៨ម គុណ ១១ម និងផ្ទះសង់អំពីឈើលើថ្មក្រោមទំហំ ៨ម គុណ ៨,៤ម ខ្សែកផ្លាកទីនចំនួន ៩ជី ២ហ៊ុន និងម៉ូតូ C125 ស៊េរី ២០០៨ មួយគ្រឿង។

**I.អំពីអង្គហេតុ:**

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៣ របស់ឈ្មោះ បញ្ជាក់ថា: នៅឆ្នាំ២០១០ ដើមចោទឈ្មោះ រៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ដួត សាវីច ហើយបានរួមរស់ជាមួយគ្នា មានកូន ០១នាក់ ឈ្មោះ ( ) ភេទប្រុស អាយុ០៣ឆ្នាំ បានរកស៊ីជាមួយគ្នា ទិញបានដីភូមិទំហំ១៨ម៉ែត្រ គុណ ១១ម៉ែត្រ និងផ្ទះប្រក់ក្បឿង (ឈើរខាងលើ ខាងក្រោមថ្ម) ទំហំ៨ម៉ែត្រ គុណ ៨,៤ម៉ែត្រ ស្ថិតក្នុងភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ដីភូមិ និងផ្ទះនេះទិញពីបងថ្លៃឈ្មោះ ដួត សាវុធ មានតម្លៃ ១១,០០០ ដុល្លារអាមេរិក ទិញម៉ូតូសេ១២៥ ស៊េរីឆ្នាំ២០០៨ មួយគ្រឿង មានតម្លៃ៥០០ ដុល្លារអាមេរិក និងខ្សែកផ្លាកទីនទម្ងន់ ៩ជី ២ហ៊ុន ឯការរួមរស់នៅជាមួយគ្នា បានសេចក្តីសុខនិងគ្នាមិនដែលឈ្លោះប្រកែកអ្វីទេ នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ប្រពន្ធដើមចោទមានជម្ងឺរលាកខួរក្បាល ក៏បានស្លាប់ទៅ បន្សល់ទុកកូនប្រុសមួយនាក់ កំព្រាម្តាយ ស្រាប់តែម្តាយក្មេកដើមចោទយកខ្សែក ម៉ូតូសេ១២៥ ស៊េរីឆ្នាំ២០០៨ មួយគ្រឿង ព្រមទាំងដេញដើមចោទ និងកូនឱ្យចុះចេញពីលើផ្ទះរបស់ដើមចោទថែមទៀត។

តាមពាក្យបណ្តឹងតប ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣ របស់ឈ្មោះ និងប្រពន្ធឈ្មោះ បានប្តឹងពីឈ្មោះ ឱ្យចុះចេញពីផ្ទះរបស់ខ្លួន ដោយសំអាងហេតុថា៖

១-ដីភូមិ និងផ្ទះនេះ ជាកម្មសិទ្ធិរបស់ខ្លួន ពុំមានការពាក់ព័ន្ធជាមួយឈ្មោះ ទេ ព្រោះខ្លួនមានលិខិតបញ្ជាក់ពីកម្មសិទ្ធិរបស់ ខ្លួនផ្ទាល់។

២-សុំទាមទារប្រាក់ដែលពាក់ព័ន្ធនឹងឈ្មោះ មាន៖ ថ្លៃផ្ទួសជុលបន្ទប់សរុបមានចំនួន ៥០០ដុល្លាររអាមេរិក,ថ្លៃព្យាបាលជម្ងឺមុនពេលកូនស្រីរបស់ខ្លួនស្លាប់សរុបចំនួន២.៥០០.០០០រៀល (ពីរលានប្រាំសែនរៀល), ថ្លៃធ្វើបុណ្យក្រោយពេលស្លាប់សរុបចំនួន ១.៥០០.០០០រៀល (មួយលានប្រាំសែនរៀល), ប្រាក់សុទ្ធចំនួន ៥.០០០.០០០រៀល (ប្រាំលានរៀល), ខ្សែកផ្កាកទឹន ១ខ្សែ ស្មើនឹងទម្ងន់ ២ជី មានក្រោយពីពេលរៀបការរួចហើយ។

៣-ដីស្រែ ២កន្លែង គឺចំណុចត្រាំគ ទំហំ ៦០អា និងចំណុច ប្រគួចទំហំ ៦០អា។

៤-ទូ ១គ្រឿង។

**II-អំពីសេចក្តីសម្រេចរបស់តុលាការ:**

តាមសាលក្រមរដ្ឋប្បវេណីលេខ ០២(ខ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ៖

១/ ទទួលស្គាល់បណ្តឹងទាមទារ របស់ដើមចោទឈ្មោះ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២/បង្គាប់ឱ្យចុងចម្លើយឈ្មោះ ណុច សារឿន ប្រគល់ម៉ូតូ ០១គ្រឿង ម៉ាកសេ១២៥ ស៊េរីឆ្នាំ២០០៨ និងខ្សែរកផ្កាកទឹន, ចិញ្ចៀន, កងដៃ សរុបទម្ងន់ ៩ជី ២ហ៊ុន អោយទៅឈ្មោះ ជាដើមចោទវិញនៅពេលដែលសាលក្រមចូលជាស្ថាពរ។

៣/ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ។

៤/សាលក្រមនេះ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ចំពោះមុខគូភាគី សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

<u>សាលាដំបូង ខេត្តព្រៃវែង សម្រេចដោយសំអាងហេតុថា:</u>

តាមលទ្ធផលនៃសាកសួរ សាម៉ីភាគី ការពិនិត្យភស្តុតាងក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា តាមអង្គហេតុនេះ គូភាគីទទួលស្គាល់ថា: ដើមឡើយដី និងផ្ទះទំនាស់នេះជារបស់ចុងចម្លើយ តែបានលក់អោយទៅដើមចោទជាកូនហើយ។

ក្នុងរឿងនេះ ចំណុចវិវាទនៅត្រង់ថា: បានទទួលប្រាក់តែ ១.០០០$ (មួយពាន់ដុល្លាររអាមេរិក) ប៉ុណ្ណោះ ក្នុងចំនួនថ្លៃលក់សរុប ១២.០០០$ (មួយម៉ឺនពីរពាន់ដុល្លាររអាមេរិក)។ ចំណុចនេះគប្បីតុលាការពិចារណា។

ការលក់ទិញ និងប្រគល់ប្រាក់របស់ភាគីនេះ ពុំមានឯកសារជាលាយលក្ខ័អក្សរទេ ដោយសំអាងថា

ជាម្តាយ និងកូន ។

យល់ឃើញថា: ការអះអាងផ្តល់ចម្លើយរបស់ចុងចម្លើយ នៅពេលទាញហេតុផលដោតផ្ទាល់មាត់ គ្មានមូលហេតុត្រឹមត្រូវដូចជា: ផ្ទះ និងដីដែលចុងចម្លើយទាមទារយកវិញនោះ គឺជាផ្ទះ និងដីដែលចុងចម្លើយបានលក់អោយទៅដើមចោទជាកូនឈ្មោះ និងកូនប្រសារឈ្មោះ ។ ហើយ ហើយដើមចោទក៏បានសាងសង់បន្ថែម គឺរៀបចំបន្ទប់ខាងក្រោមផ្ទះឈើរនោះ មានទាំងបន្ទប់គេង និងបន្ទប់ទឹក ព្រមទាំងបានតយាបចាប់ដែកផ្ទះ ដោយពុំមានភាគីណាមករារាំងឡើយ។

តាំងពីទិញ រហូតមកដល់សាងសង់បន្ថែម ភាគីដើមចោទបានរស់នៅដោយសុខសាន្តដោយពុំមានបញ្ហាអ្វីឡើយ តែនៅពេលប្រពន្ធរបស់ដើមចោទ ( ) ចាប់មានជម្ងឺហើយបានស្លាប់ក៏កើតមានទំនាស់ ដោយចុងចម្លើយត្រូវជាម្តាយក្មេកបានដេញកូនប្រសារ (ដើមចោទ) អោយចុះចេញពីផ្ទះនេះ ដោយអះអាងថា: ពុំទាន់បានទូទាត់ប្រាក់ថ្លៃទិញផ្ទះនេះគ្រប់នៅឡើយ។ ចំណុចនេះ គប្បីតុលាការពិចារណា។

ករណីនេះ បើដើមចោទមិនបានបង់ប្រាក់ថ្លៃទិញផ្ទះនោះ មិនមែនធ្វើជាលាយល័ក្ខអក្សរទេ ដោយហេតុថា: ជាម្តាយ និងកូន ។ ជាក់ស្តែងដូចជា ម៉ូតូ ហុងដា ម៉ាកសេ១២៥ ស៊េរី ២០០៨ ពាក់ស្លាកលេខ ដែលចុងចម្លើយ ដែលបានដកហូតយកពីដើមចោទ (កូនប្រសារ) ដោយអះអាងថា: ជាម៉ូតូរបស់ខ្លួនទិញអោយកូនស្រី (ប្រពន្ធដើមចោទ) ប្រើជាបណ្តោះអាសន្នតាំបីមុនរៀបអាពាហ៍ពិពាហ៍ មកម៉្លេះ ហើយគ្មានកាតគ្រី និងស្លាកលេខទេ។

ចំណុចនេះ ដើមចោទបានអះអាងថា៖ ម៉ូតូនេះ ជារបស់ខ្លួនដែលបានទិញក្រោយពេលរៀបអាពាហ៍ពិពាហ៍។ ចុងចម្លើយ (ម្តាយក្មេក) បានដកហូតយកម៉ូតូនេះទៅ ដោយមានកាតគ្រីខ្លួនដាក់នៅក្រោមកែបម៉ូតូ ហើយម៉ូតូនោះផ្លាកលេខ ១B ៦៥៤០ ដែលជាកម្មសិទ្ធិរបស់ខ្លួន តែចុងចម្លើយយកឯកសារនេះលាក់បំបាត់គាង។

តាមលិខិតលេខ ១៣០ សក.ពវ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ របស់មន្ទីសាធារណៈការ និងដឹកជញ្ជូនខេត្តព្រៃវែង បានបញ្ជាក់ថា ម៉ូតូដែលមានផ្លាកលេខ ១B ៦៥៤០ ជាកម្មសិទ្ធិរបស់ឈ្មោះ ។

មាសផ្លាកទីនមាន: ខ្សែក ចិញ្ចៀន និងកងដៃទម្ងន់សរុប ៩,២ ហ៊ុន (ប្រាំបួនជីពីរហ៊ុន) ដែលចុងចម្លើយ ( ) បានដកហូតពីប្រពន្ធដើមចោទ ដែលកំពង់សម្រាកព្យាបាលនៅមន្ទីពេទ្យសូវៀតនោះ ចុងចម្លើយអះអាងថា: ជារបស់ខ្លួនដែលបានទិញអោយកូនស្រី (ប្រពន្ធដើមចោទ) មុនពេលរៀបការដែរ តែនៅពេលតុលាការសួររកឯកសារទិញលក់គ្មានផ្ទុយពីដើមចោទ គឺមានវិក័យប័ត្រទិញលក់(មាសផ្លាកទីន) ត្រឹមត្រូវ ហើយការលក់ទិញនេះ គឺស្ថិតនៅក្នុងកំឡុងពេលមានចំណងអាពាហ៍ពិពាហ៍។

ការអះអាងរបស់ចុងចម្លើយ ( ) គ្មានមូលហេតុត្រឹមត្រូវដែលអាចអោយតុលាការពិចារណាបានឡើយ ដោយហេតុថា: ប្រសិនបើប្រពន្ធរបស់ ( ) ត្រូវជាកូនបង្កើតរបស់ចុងចម្លើយពុំបានស្លាប់នោះទេ ក៏ពុំមានមូលហេតុក្នុងការទាមទារដី និងផ្ទះនេះវិញដែរ។ ការទាមទារនេះគឺ ចុងចម្លើយមានចេតនាទុច្ចរិតចង់បានដី និងផ្ទះ ដែលបានលក់ទៅអោយកូនរួចហើយមកគ្រប់គ្រងវិញ

ដោយសំអាងថា: ការលក់ទិញពុំមានធ្វើជាលាយល័ក្ខអក្សរ។

-តាមរបាយការណ៍របស់លោក សមាជិកក្រុមប្រឹក្សាឃុំរកា បានបញ្ជាក់ថា: នៅឆ្នាំ២០១១ ឈ្មោះ និងប្រពន្ធឈ្មោះ ពិតជាបានទិញផ្ទះ និងដីពីឈ្មោះ (ជាម្តាយ)។ ទាំងពីរនាក់ប្តីប្រពន្ធ បានរស់នៅលើផ្ទះនោះរហូតមក ដែលពុំមានបញ្ហាឡើយ ថែមទាំងបានធ្វើបន្ទប់គេង បន្ទប់ទឹកក្រោមផ្ទះ នឹងតយាបចាប់ដែក នៅខាងមុខនឹងសងខាងផ្ទះ ដោយពុំមានអ្នកណាមករារាំងឡើយ។ លុះដល់ឆ្នាំ២០១៣ ក្រោយពីឈ្មោះ ជាប្រពន្ធរបស់ដើមចោទស្លាប់ទៅបាន ០៧ថ្ងៃ ឪពុកម្តាយរបស់ឈ្មោះ បានបណ្តេញឈ្មោះ ជាកូនប្រសារ អោយចុះចេញពីផ្ទះ ដោយអោយយកទាំងកូនប្រុសអាយុ០៣ឆ្នាំ ទៅជាមួយផង មិនតែប៉ុណ្ណោះ ឈ្មោះ និង (ចុងចម្លើយ) បានចាក់សោរផ្ទះ និងយកគោទៅចងរំខាននៅកន្លែងរកស៊ីរបស់ ទៀតផង។ ខ្លួនជាក្រុមប្រឹក្សាឃុំដែលបានរស់នៅទីនោះ ផ្ទាល់បានដឹងឮយ៉ាងច្បាស់ពីបញ្ហានេះ ហើយក៏មានប្រជាពលរដ្ឋនៅក្នុងភូមិមេលប់ជាច្រើននាក់ទៀត ក៏បានដឹងលឺពីបញ្ហានេះដែរ។

តាមចម្លើយរបស់សាក្សីឈ្មោះ យ៉ឹង ម៉ឺន ក៏ដូចជាចម្លើយរបស់សាក្សីឯទៀតដូចមានឈ្មោះ ខាងលើបានឆ្លើយបំភ្លឺប្រហាក់ប្រហែលគ្នាថា: ខ្លួនបានដឹងថាឈ្មោះ និងប្រពន្ធឈ្មោះ បានទិញដី និងផ្ទះពីបងថ្លៃរបស់គេ ឈ្មោះ ប្រាកដមែន ព្រោះផ្ទះនោះ ចុងចម្លើយបានចែកមរតកក៏អោយទៅកូនបងឈ្មោះ ។ ក្រោយពីទិញហើយ ឃើញប្តីប្រពន្ធគេរស់នៅលើផ្ទះនេះរហូតមកមិនដែលមានបញ្ហាអ្វីទេ។ ឯបងថ្លៃរបស់ឈ្មោះ ) ក្រោយពីលក់ផ្ទះនោះអោយទៅប្អូនហើយ ក៏ទៅទិញផ្ទះនៅឯផ្សារវិញ ។ ចម្លើយនេះ ស៊ីសង្វាក់ទៅនឹងចម្លើយរបស់ឈ្មោះ ដួត សារុធ ដែលបានទទួលស្គាល់ថា: នៅក្នុងឆ្នាំ២០១០ ក្រោយពីប្អូនស្រីខ្លួន ( ប្រពន្ធ ) រៀបការរួច ខ្លួនពិតជាបានទិញដីនៅផ្សារប្រាកដមែន។ អង្គហេតុនេះ គប្បីតុលាការពិចារណាតាមច្បាប់។

យល់ឃើញថា: ការលើកឡើងរបស់លោកមេធាវី ចំពោះឯកសារបញ្ជាក់កម្មសិទ្ធិដីធ្លី និងផ្ទះ ដែលបញ្ជាក់ដោយលោកមេភូមិ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៨ ថាមានភាពមិនប្រក្រតី នៃលិខិតដោយហេតុថា: ការកាន់កាប់ប្រើប្រាស់នៅឆ្នាំ២០០៩ ឯលិខិតបញ្ជាក់កម្មសិទ្ធិធ្វើនៅឆ្នាំ២០០៨ ដែលនៅឆ្នាំ២០០៨នេះ មេភូមិមេលប់ គឺលោក មិនមែនជាលោក ឡើយ។ ចំណុចនេះ គប្បីតុលាការពិចារណាតាមច្បាប់។

យល់ឃើញថា: ខ្សែក ចិញ្ចៀន និងកងដៃទម្ងន់ ៩ជី ២ហ៊ុន ដើមចោទមានឯកសារទិញលក់ពីជាងត្រឹមត្រូវ នៅក្នុងកំឡុងដែលពួកគេរកស៊ីជាមួយគ្នា ដូចមានបញ្ជាក់ក្នុងលិខិតទិញលក់ ។

យល់ឃើញថា: តាមលិខិតបញ្ជាក់របស់មន្ទីសាធារណៈការ និងដឹកជញ្ជូនខេត្តព្រៃវែង បានបញ្ជាក់ថា: ឈ្មោះ ជាកម្មសិទ្ធិនៃម៉ូតូម៉ាកសេ១២៥ ស៊េរី២០០៨ ពាក់ផ្លាកលេខ ១B-៦៥៤០ ប្រាកដមែន។

យល់ឃើញថា: យោងតាមហេតុផលទាំងនេះ តុលាការទទួលស្គាល់ថា: អង្គហេតុ និងមូលហេតុនៃការទាមទាររបស់ដើមចោទមានអត្ថិភាព។

យល់ឃើញថា: បណ្តឹងទាមទាររបស់ឈ្មោះ និងឈ្មោះ ចុះថ្ងៃទី២២ ខែធ្នូ

ឆ្នាំ២០១៣ ពុំមានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ គប្បីតុលាការច្រានចោលការទាមទារនេះ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ១២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ ប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០២(ខ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

តាមសាលដីការរដ្ឋប្បវេណីលេខ ០៤ក្រ.IV.សស ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ របស់សាលាឧទ្ធរណ៍ មានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍ របស់ចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ខ្លះ។

២-ទទួលស្គាល់បណ្ដឹងតបចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៣ របស់ចុងចម្លើយ និងប្ដីឈ្មោះ ត្រង់ចំណុចទី១ ការទាមទារឱ្យ ចុះចេញពីផ្ទះ និងដីទំនាស់ទុកជាត្រឹមត្រូវតាមច្បាប់។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ: ០២(ខ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់សេចក្ដីសម្រេចចំណុចទី២ បង្គាប់ឱ្យចុងចម្លើយ ប្រគល់ម៉ូតូ ០១ គ្រឿង ម៉ាកសេ១២៥ សេរីឆ្នាំ២០០៨ ឱ្យឈ្មោះ រឿន សុជាតិ ជាដើមចោទវិញ។ ចំណុចក្រៅពីនេះ ត្រូវលុបចោល។

៤-បង្គាប់អោយដើមចោទឈ្មោះ ចាកចេញពីផ្ទះ និងដីទំនាស់ទំហំ ១៨ម គុណ ១១ម ផ្ទះទំហំ ៨ម គុណ ៨,៤ម ឈើលើ ថ្មក្រោម ស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង និងឱ្យចុងចម្លើយឈ្មោះ ប្រគល់ប្រាក់ចំនួន ១,០០០$ ឱ្យទៅ ដើមចោទឈ្មោះ វិញ។

៥-សាលដីកានេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈនាថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៤ បើកផ្លូវប្ដឹងសាទុក្ខក្នុងរយៈពេល០១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនពីសាលដីកានេះ។

<u>សាលាឧទ្ធរណ៍សម្រេចដោយសំអាងហេតុថា:</u>

-តាមលទ្ធផលនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការពិនិត្យភស្តុតាងឃើញថា ចុងចម្លើយ សុំបដិសេធសាលក្រមរបស់សាលាដំបូងខេត្តព្រៃវែង ដោយសុំទាមទារឱ្យសាលាឧទ្ធរណ៍លើកយកបណ្ដឹងតបរបស់ខ្លួន និងប្ដី ចុះថ្ងៃទី២២ ខែ១២ ឆ្នាំ២០១៣ ដែលបានប្ដឹងឱ្យឈ្មោះ ចុះចេញពីផ្ទះរបស់ខ្លួន សុំទាមទារម៉ូតូម៉ាកសេ ១២៥ សេរីឆ្នាំ ២០០៨ និងគ្រឿងអលង្ការដោយអះអាងថា ផ្ទះនិងដី ទំនាស់ជាកម្មសិទ្ធិរបស់ខ្លួន និងប្ដីពុំបានប្រគល់ឱ្យឈ្មោះ ទេ ហើយផ្ទះ និងដីនោះ ខ្លួនបានអោយកូនឈ្មោះ ស្នាក់នៅបណ្ដោះអាសន្នបន្ទាប់ពីរៀបការជាមួយ ហើយខ្លួនបានប្រាប់កូនថាលក់ឱ្យតម្លៃ ១២,០០០$ ហើយកូនបានអោយប្រាក់ខ្លួន ១,០០០$ នៅខ្វះ ១១,០០០$ ពេលកូនស្រីខ្លួនស្លាប់ទៅឈ្មោះ មានគំនិតលោភលន់ចង់បានផ្ទះ និងដីរបស់ខ្លួន និងថាបានអោយប្រាក់ឈ្មោះ គ្រប់ចំនួនរួចហើយ តែតាមពិតពុំបានឱ្យទេ ។ បន្ទាប់ធ្វើបន្ថែមគឺខ្លួនជាអ្នកចេញប្រាក់អោយកូនធ្វើ។ ខ្លួនសុំទាមទារផ្ទះ និងដីនោះសុំប្រគល់លុយ ១.០០០$ វិញ ឈប់លក់ហើយ ព្រោះកូនស្រីរបស់ខ្លួនស្លាប់ហើយ ហើយ ក៏ពុំទាន់ឱ្យប្រាក់ខ្លួនគ្រប់ដែរ ។ ខ្សែក ចិញ្ចៀន កងដៃ ខ្លួន

ដោះយកពីកូនមែន ពេលឈឺដេកពេទ្យ លក់ព្យាបាល និងធ្វើបុណ្យសពអស់ហើយ ម៉ូតូខ្លួនគ្រប់គ្រង។

-តាមស្តាប់អំណានចម្លើយរបស់ដើមចោទ បានអះអាងថា ខ្លួនប្តឹងទាមទារផ្ទះម៉ូតូ១គ្រឿង និងខ្សែក ផ្កាកទីន ចិញ្ចៀន កងដៃ សរុប ៩ជី ២ ហ៊ុន ពីចុងចម្លើយ ណុច សារឿន ដោយសំអាងថា កាលពីឆ្នាំ២០១០ ខ្លួនបានរៀបការជាមួយឈ្មោះ ត្រូវជាកូនរបស់ចុងចម្លើយ ពេលរកស៊ីជាមួយប្រពន្ធមានលុយក៏បានទិញផ្ទះពីបងថ្លៃឈ្មោះ តម្លៃ ១១.០០០$ ផ្ទះទំហំ ៨ម គុណ ៨,៥ម សង់លើដីទំហំ១៦ម គុណ ១១ម បានប្រគល់ប្រាក់ឱ្យបងថ្លៃចំនួន និងចូលទៅរស់នៅបានសាងសង់បន្ទប់ថ្មខាងក្រោម តយ៉ាបខាងមុខ ទិញ ខ្សែកផ្កាកទីន កងដៃ ចិញ្ចៀន និងកងដៃ ឱ្យប្រពន្ធពាក់ និងទិញម៉ូតូ ០១ គ្រឿង នៅថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ ប្រពន្ធខ្លួនស្លាប់ទៅធ្វើបុណ្យ៧ថ្ងៃរួច ម្តាយក្មេកដេញខ្លួនឱ្យចុះចេញពីផ្ទះ និងដកយកម៉ូតូ ១គ្រឿង ចំពោះខ្សែក គ្រឿងអលង្កា ម្តាយក្មេកដកយកនៅពេលប្រពន្ធខ្លួនឈឺ ដឹកយកមកមន្ទីរពេទ្យរុស្សី។

-តាមស្តាប់អំណានចម្លើយសាក្សី ! បានអះអាងថា ខ្លួនពុំបានលក់ដី និងផ្ទះឱ្យទៅឈ្មោះ 1 ទេ ហើយក៏ពុំដែលទទួលលុយពី ដែរ និងផ្ទះនោះជាកម្មសិទ្ធិរបស់ម្តាយខ្លួន ។ ខ្លួនពុំមានសិទ្ធិក្នុងការលក់ដូរទេ ។ នៅឆ្នាំ ២០១០ ក្រោយពីប្អូនស្រីខ្លួនការរួច ខ្លួនពិតជាបានទិញដីនៅផ្សារប្រាកដមែនដែលជាលុយផ្ទាល់ខ្លួន ចំណែកម៉ូតូម៉ាកសេ ១២៥ សេរីឆ្នាំ២០០៨ ម្តាយខ្លួនទិញអោយខ្លួន និងប្អូនស្រី ជិះទៅរៀនដែរ គ្រឿងអលង្ការម្តាយទិញឱ្យពាក់តាំងពីនៅក្មេង។

-តាមស្តាប់អំណាន ចម្លើយឱ្យការណ៍របស់សាក្សី និង ដែលជាអជ្ញាធរមូលដ្ឋានបានដាក់បញ្ជាក់ថា ពួកខ្លួនជាអ្នកដោះស្រាយវិវាទរវាងដើមចោទ និងចុងចម្លើយ ហើយបានសួររកប្រាក់ចំណូលដើម្បីទិញផ្ទះ របស់ដើមចោទ ដែលថា ដើមចោទពុំមានខ្ចីប្រាក់ពីអ្នកភូមិ និងពុំប្រាប់ពីកន្លែងលក់មាស ហើយសាក្សីឈ្មោះ ពេលសួរ ថាបានអោយលុយទិញផ្ទះទៅម្តាយក្មេក ៨,០០០$ ខ្វះ ៣,០០០$ រីឯចម្លើយសាក្សីឈ្មោះ ពេលខ្លួនសួរឈ្មោះ ថាអោយលុយទៅម្តាយក្មេក ៦,០០០$ គឺចម្លើយពុំស៊ីសង្វាក់ ពុំអាចអោយតុលាការជឿបានទេ ព្រោះពុំមានធ្វើកំណត់ហេតុ និងពុំមានការទទួលស្គាល់ពី ។

-ចម្លើយសាក្សីឈ្មោះ បានឆ្លើយប្រហាក់ប្រហែលគ្នាថា ឈ្មោះ ពិតជាបានទិញដី និងផ្ទះទំនាស់នោះ ពីឈ្មោះ ដួត សារុធ និងបានរៀបបន្ទប់ថ្មរ និងតយ៉ាប ខាងមុខ ។ សាក្សីឈ្មោះ ថា នៅឆ្នាំ២០១១ ឈ្មោះ និងប្រពន្ធឈ្មោះ បានទិញដី និងផ្ទះពីឈ្មោះ (ជាម្តាយ) ចម្លើយសាក្សីទាំងអស់នោះពុំអាចយកជាការបានព្រោះ ការឆ្លើយនោះត្រូវបានឈ្មោះ បដិសេធហើយក៏ពុំមានឯកសារឬលិខិតទិញលក់ និងប្រគល់ទទួលប្រាក់ជាមួយឈ្មោះ នោះទេ។

-មេធាវី ធ្វើសេចក្តីថ្លែងការណ៍ថា សុំឱ្យសាលាឧទ្ធរណ៍សម្រេចតាមបណ្តឹងតបរបស់កូនក្តីខ្លួន ដោយលើកហេតុផលថា: ដី និងផ្ទះទំនាស់នោះគឺជាកម្មសិទ្ធិរបស់កូនក្តីខ្លួន មានឯកសារត្រឹមត្រូវ បញ្ជាក់ពីមេឃុំ ម៉ូតូ និងគ្រឿងអលង្ការ កូនក្តីខ្លួនទិញអោយកូនមុនរៀបការ។

-មេធាវី សុំអោយតុលាការតម្កល់សាលក្រមរបស់សាលាដំបូងខេត្តព្រៃវែង ទុកជាបានការ ដោយបញ្ជាក់ថា: កូនក្តីខ្លួនបានទិញដី និងផ្ទះទំនាស់ពីចុងចម្លើយបានអោយប្រាក់គ្រប់ចំនួនហើយ ទើបចុងចម្លើយអោយកូនខ្លួនទៅរស់នៅ ហើយអោយធ្វើបន្ទប់ និងតយ៉ាបខាងមុខ ចំណែកម៉ូតូ និងគ្រឿងអលង្ការ ជារបស់កូនក្តីខ្លួន ដែលមានកាតគ្រីម៉ូតូ និងលិខិតទិញលក់មាស។

-ពាក្យបណ្តឹងចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៣ ចុងចម្លើយបានប្តឹងអោយដើមចោទ ចុះចេញពីផ្ទះរបស់ខ្លួន និងទាមទារប្រាក់ថ្លៃជួសជុលបន្ទប់ចំនួន ៥00$ ថ្លៃព្យាបាលជម្ងឺ និងចំណាយបុណ្យសពរបស់កូន ៤លានរៀល ខ្សែករ១ខ្សែ ២ជី ទាមទារដីស្រែ ៦០អា ពីរកន្លែង ប៉ុន្តែសាលាដំបូងខេត្តព្រៃវែងពុំបានសម្រេចពីការទាមទាររបស់ចុងចម្លើយ បើពិនិត្យលើខ្លឹមសារបណ្តឹងនោះ គឺជាបណ្តឹងតបត្រង់ការទាមទារដើមចោទអោយចុះចេញពីផ្ទះ ខ្លួនសុំប្រគល់ប្រាក់ ១000$ អោយដើមចោទវិញ ។ គប្បីសាលាឧទ្ធរណ៍ យកមកពិចារណា ហើយនៅពេលទាញហេតុផលនោះ ចុងចម្លើយពុំបានទារប្រាក់ថ្លៃជម្ងឺ និងបុណ្យសពកូន និងទាមទារដី ៦០អា ពីរកន្លែង ពីឈ្មោះ ទេ។

-តាមការអះអាងរបស់ភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីតំណាងដោយអាណត្តិ ឱ្យភាគី និងចម្លើយបំភ្លឺរបស់សាក្សី ឃើញថា ពុំមានកិច្ចសន្យាលក់ ទិញ រវាងដើមចោទ និង និងពុំមានលិខិតប្រគល់ទទួលប្រាក់ ។ តាមការអះអាងរបស់ដើមចោទ ថា ទិញពីបងថ្លៃឈ្មោះ បានអោយប្រាក់គ្រប់ចំនួនហើយ តែឈ្មោះ បដិសេធថាពុំបានលក់ ហើយក៏ពុំបានទទួលប្រាក់ដើមចោទដែរ ហើយក៏គ្មានសាក្សីណាបានដឹងអំពីតម្លៃ និងឃើញដើមចោទប្រគល់ប្រាក់អោយឈ្មោះ ដែរ។ ប៉ុន្តែតាមការអះអាងដើមចោទ ថាខ្លួនទទួលប្រាក់តែ ១.000$ ពីកូន ដួត សាវិច និងកូនសារ នៅខ្វះ ១១,000$ ទៀត កូនពុំទាន់បានអោយគ្រប់ទេ។ បើតាមឯកសារលិខិតបញ្ជាក់របស់មេឃុំ និងការអះអាងរបស់ភាគីផ្ទះ និងដីទំនាស់ជាកម្មសិទ្ធិរបស់ចុងចម្លើយ ដូចនេះ ចុងចម្លើយមានសិទ្ធិឈប់លក់វិញនៅពេលដើមចោទ ពុំបានចេញប្រាក់មកអោយខ្លួន ។ ម៉ូតូម៉ាកសេ ១២៥ សេរីឆ្នាំ២00៨ មានលិខិតបញ្ជាក់ថា ជាកម្មសិទ្ធិរបស់ដើមចោទ ដូចនេះគប្បីច្រានចោលការទាមទាររបស់ចុងចម្លើយ។ គ្រឿងអលង្កាប្លាទីនទម្ងន់ ៩ជី ២ហ៊ុន ដើមចោទមានវិក័យប័ត្រទិញលក់មែន ប៉ុន្តែតាមការអះអាងរបស់ចុងចម្លើយថា ខ្លួនលក់ព្យាបាលកូន និងធ្វើបុណ្យសពអស់ហើយ ចំណុចនេះដើមចោទក៏ទទួលស្គាល់ថាពេលប្រពន្ធខ្លួនឈឺដឹកយកទៅមន្ទីរពេទ្យ ម្តាយក្មេកដោះយកពីប្រពន្ធខ្លួន ហេតុនេះ សាលាឧទ្ធរណ៍ យល់ឃើញថាចុងចម្លើយជាអ្នកចំណាយប្រាក់ថ្លៃព្យាបាលជំងឺ និងបុណ្យសពរបស់កូន គប្បីលុបចោលការសម្រេចឱ្យចុងចម្លើយសងគ្រឿងអលង្ការទៅដើមចោទ។

-ពាក្យបណ្តឹងតបចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៣ របស់ចុងចម្លើយ សាលាដំបូងខេត្តព្រៃវែង ពុំបានសម្រេចអំពីការទាមទារឡើយ គប្បីសាលាឧទ្ធរណ៍លើកយកមកពិចារណា និងសម្រេចតាមច្បាប់។

-សាលក្រមរដ្ឋប្បវេណីលេខ ០២(ខ) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង បានសម្រេចសេចក្តីដោយលើកយកសំអាងហេតុ ពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយគប្បីបំពេញបន្ថែមផ្នែកសំអាងហេតុតាមការយល់ឃើញខាងលើ។ ចំណែកការសម្រេចសេចក្តីក្នុងសាលក្រមនេះ ឃើញថា

- តាមលិខិតបញ្ជាក់អំពីមូលហេតុនៃបណ្តឹងសាទុក្ខ ដើមបណ្តឹងសាទុក្ខបានអះអាងថាដី និងផ្ទះ ដែលស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្ត ព្រៃវែង គឺខ្លួន និង ប្រពន្ធបានទិញពី ឈ្មោះ និងបានប្រគល់ប្រាក់ថ្លៃទិញចំនួន ១១០០០ដុល្លារអាមេរិច គ្រប់ចំនួនរួចហើយ ទើបខ្លួន និង ប្រពន្ធមានសិទ្ធិចូលទៅរស់នៅក្នុងផ្ទះនោះ និងសាងសង់បន្ទប់ តយ៉ាក ក៏ប៉ុន្តែពុំមានឯកសារណាមួយបញ្ជាក់អំពីការលក់ទិញ និង ការប្រគល់ប្រាក់គ្រប់ចំនួន ទេ ការដែលដើមចោទ និង ប្រពន្ធបានចូលទៅនៅក្នុងផ្ទះនោះ ដោយសារ ប្រពន្ធរបស់ដើមចោទជាកូនស្រីបង្កើតរបស់ចុងចម្លើយ ហើយចុងចម្លើយប្រគល់ផ្ទះនោះអោយដើមចោទ និង កូនស្នាក់នៅបណ្តោះអាសន្ន ម្យ៉ាងទៀត ពុំមានឯកសារណាមួយដែលបញ្ជាក់ថា ដីនិងផ្ទះ ទំនាស់ជាកម្មសិទ្ធិរបស់ ឈ្មោះ ទេ។

ម្យ៉ាងវិញទៀត ចុងចម្លើយបានទទួលស្គាល់ថា ខ្លួនព្រមលក់ផ្ទះអោយកូនស្រីខ្លួនក្នុងតម្លៃ ១២០០០ដុល្លារអាមេរិក ហើយកូន បានអោយប្រាក់ចំនួន ១០០០ដុល្លារអាមេរិច នៅខ្វះចំនួន ១១០០០ដុល្លាអាមេរិចទៀត ពេលនេះកូនខ្លួនស្លាប់ហើយ ដូចនេះ ខ្លួនឈប់លក់វិញហើយ ក្នុងករណីនេះ ចុងចម្លើយដែលជាអ្នកលក់ក៏មានសិទ្ធិក្នុងការរំលាយកិច្ចសន្យាចោលវិញដែរ ដោយសង២ដងនៃប្រាក់កក់ទៅអោយអ្នកទិញវិញ យោងតាមមាត្រា ៥១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-សាលាឧទ្ធរណ៍បានសម្រេចសេចក្តីអោយ ឈ្មោះ ចាកចេញពីផ្ទះទំនាស់ ដោយពុំទាន់បានពិចារណាល្អិតល្អន់ ទៅលើលិខិតផ្ទេរដីចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥ ដែលមានឈ្មោះខុស និង លិខិតបញ្ជាក់កម្មសិទ្ធិ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៨ ដែលខ្លឹមសារនៃលិខិតបញ្ជាក់ថា ចុងចម្លើយបានកាន់កាប់ដីទំនាស់តាំងពីឆ្នាំ ២០០៩ មក នៅឡើយ គឺមានន័យថា ការធ្វើលិខិតបញ្ជាក់នេះមុនការកាន់កាប់របស់ ចុងចម្លើយទៀត។

-ការដែលសាលាឧទ្ធរណ៍សម្រេចលប់ចោលការប្រគល់ គ្រឿងអលង្ការទៅ អោយដើមចោទ នោះជាការត្រឹមត្រូវហើយ ពីព្រោះ ដើមចោទទទួលស្គាល់ថានៅពេលប្រពន្ធខ្លួនឈឺ ចុងចម្លើយជាអ្នកដឹកយកទៅមន្ទីរពេទ្យ ដូចនេះអាចជឿបានថា ចុងចម្លើយជាអ្នកមើលថែជំងឺ រហូតដល់បុណ្យសពកូនទៀត ផ្ទុយទៅវិញការដែលដើមចោទអះអាងថាខ្លួនជាអ្នកមើលថែ ប្រពន្ធ និង ចំណាយក្នុងការបុណ្យសពនោះ ពុំមានអ្វីមកបញ្ជាក់ទេ។

- ការសម្រេចសេចក្តី របស់សាលាឧទ្ធរណ៍ តាមសាលដីកា លេខ០៤ក្រIV"សស" ចុះថ្ងៃទី១៥ ខែ ០៩ ឆ្នាំ២០១៤ ត្រឹមត្រូវខ្លះ ខុសខ្លះ។

អាស្រ័យហេតុនេះ សូម ឯកឧត្តមប្រធាន និង ក្រុមប្រឹក្សាជំនុំជម្រះពិនិត្យ និងសម្រេចតាមច្បាប់។

ចៅក្រមទទួលបញ្ជា

ឧបសម្ព័ន្ធទី១៨

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី
លេខ ........................
ចុះថ្ងៃទី២៣...ខែ០៧..ឆ្នាំ២០១២

# ដីកាកោះ

យើង .............................ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះនៃតុលាការកំពូល

បង្គាប់មកលោក-លោកស្រី...............................អាយុ..៥០...ឆ្នាំ មានមុខរបរ...........

អាសយដ្ឋាន: ផ្ទះលេខ.........ក្រុម/ផ្លូវ.............ភូមិ.............សង្កាត់/ឃុំ.............

ខណ្ឌ/ស្រុក.............រាជធានី/ខេត្ត.............................

ឱ្យចូលខ្លួនមកកាន់តុលាការកំពូលនៅថ្ងៃទី២៤...ខែ.......ឆ្នាំ២០១៣ វេលាម៉ោង.............

ដើម្បីចូលរួមពីដំណើរការទាញហេតុផលដោយផ្ទាល់មាត់ទាក់ទងនឹងរឿង

...........................................................................................

"សាម៉ីខ្លួនត្រូវអញ្ជើញមកអោយទាន់ពេលវេលា និងយកលិខិតផ្សេងៗដែលមានទំនាក់ទំនងនឹងរឿងក្តីខាងលើមកជាមួយផង ប្រសិនបើមាន"។

ភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ២០១៣

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

មហាវិថីសម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, រាជធានីភ្នំពេញ, កម្ពុជា
Samdech Sothearos Blvd, Sangkat Chatomouk, Khan Daun Penh, Phnom Penh, Cambodia
ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣) ២១២ ៨២៦
Phone/fax: (855-23) 212 826

ឧបសម្ព័ន្ធទី១៩

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សំណុំរឿង [illegible]...
លេខ ......... 07 .........
ចុះថ្ងៃទី [illegible]

# លិខិតអញ្ជើញ

ប្រធាន ..........................................
ជំរាបមក...[illegible].. ..........................................
ការបើកសវនាការរបស់តុលាការកំពូលដើម្បីជំនុំជំរះរឿង [illegible]........
......................ពីបណ្តឹងសាទុក្ខរបស់លោក ..............នឹងប្រព្រឹត្តទៅ
នៅថ្ងៃទី...[illegible]...ខែ [illegible]. ឆ្នាំ ២០13 .. វេលាម៉ោង ...[illegible]....... ។
ហេតុនេះសូមអញ្ជើញលោកទៅចូលរួមសវនាការក្នុងឋានៈជា [illegible]..
[illegible]......................
ក្នុងករណីមានធុរៈ សូមលោកអោយដំណឹងមកតុលាការកំពូលជាបន្ទាន់ ។

ភ្នំពេញ ថ្ងៃទី [illegible]... ខែ [illegible].. ឆ្នាំ ២០13
តុលាការកំពូល

ឧបសម្ព័ន្ធទី២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

**សភាវិវាទប្បវេណី**
សំណុំរឿងរដ្ឋប្បវេណី
លេខៈ ៣៣
ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥
សាលដីកា
លេខៈ ៥២៧ "ក"
ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានទាញហេតុផលដោយផ្ទាល់មាត់នាសវនាការជាសាធារណៈនៅថ្ងៃទី១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥។

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

១-ឯកឧត្តម ជីវ កេង ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
២-លោក ជាចៅក្រម
៣-លោក ជាចៅក្រម
៤-លោក ជាចៅក្រម
៥-លោកស្រី ជាចៅក្រម

[illegible]
លោកស្រី [illegible]

[illegible]
លោក [illegible]

[illegible]ការ
លោក [illegible] ជាព្រះរាជអាជ្ញា

**ដើមចោទៈ**លោក រឿន សុជាតិ( ដើមបណ្តឹងសាទុក្ខ) អាយុ ៥៨ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិមេលប់ ឃុំរការ ស្រុកពារាំង ខេត្តព្រៃវែង។

**អ្នកតំណាងដោយអាណត្តិ៖** លោកស្រីមេធាវី ពិង ធីតា

**ចុងចម្លើយៈ**អ្នកស្រី ណុច សារឿន (ចុងបណ្តឹងសាទុក្ខ) ប្តីឈ្មោះ ដន ដួត អាយុ ៥៩ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង។

**អ្នកតំណាងដោយអាណត្តិ៖** លោកមេធាវី តាន់ ម៉េងស្រ៊យ, លោក ភុន វិទ្យា និងកញ្ញា ទិត ដាវ៉ឡែន

**<u>កម្មវត្ថុបណ្ដឹង:</u>**-ប្ដឹងទាមទារដីភូមិទំហំ ១៨ម គុណ ១១ម និងផ្ទះសង់អំពីឈើលើថ្មក្រោម ទំហំ ៨ម៉ែត្រ គុណ ៨,៤ម៉ែត្រ ខ្សែកផ្កាទីនទម្ងន់ ៩ជី ២ហ៊ុន និងម៉ូតូ C125 ស៊េរី ២០០៨ មួយគ្រឿង។

## <u>អំពីអង្គហេតុ និង ចំណុចវិវាទ:</u>

### ក-<u>អំពីអង្គហេតុជាមូលហេតុនៃការទាមទារ:</u>

តាមពាក្យបណ្ដឹង ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៣ របស់ឈ្មោះ រឿន សុជាតិ បញ្ជាក់ថា: នៅឆ្នាំ ២០១០ ដើមចោទឈ្មោះ រឿន សុជាតិ រៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ដួត សាវិច ហើយបានរួមរស់ជាមួយគ្នាមានកូន ០១នាក់ ឈ្មោះ ជាតិ គីមហុង ភេទប្រុស អាយុ ០៣ឆ្នាំ បានរកស៊ីជាមួយគ្នា ទិញបានដីភូមិទំហំ ១៨ម៉ែត្រ គុណ ១១ម៉ែត្រ និងផ្ទះប្រក់ក្បឿង(ឈើខាងលើ ខាងក្រោមថ្ម) ទំហំ ៨ម៉ែត្រ គុណ ៨,៤ម៉ែត្រ ស្ថិតក្នុងភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង ដីភូមិ និងផ្ទះនេះទិញពីបងថ្លៃឈ្មោះ ដួត សារុធ មានតម្លៃ ១១.០០០ដុល្លារអាមេរិក ទិញម៉ូតូសេ ១២៥ ស៊េរីឆ្នាំ ២០០៨ មួយគ្រឿង មានតម្លៃ ៥០០ដុល្លារអាមេរិក និងខ្សែកផ្កាទីនទម្ងន់ ៩ជី ២ហ៊ុន ឯការរួមរស់នៅជាមួយគ្នា បានសេចក្ដីសុខនឹងគ្នាមិនដែលឈ្លោះប្រកែកអ្វីទេ នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៣ ប្រពន្ធដើមចោទមានជម្ងឺរលាកខួរក្បាល ក៏បានស្លាប់ទៅ បន្សល់ទុកកូនប្រុសមួយនាក់កំព្រាម្ដាយ ស្រាប់តែម្ដាយក្មេកដើមចោទយកខ្សែក ម៉ូតូសេ ១២៥ ស៊េរីឆ្នាំ ២០០៨ មួយគ្រឿង ព្រមទាំងដេញដើមចោទ និងកូនឱ្យចុះចេញពីលើផ្ទះរបស់ដើមចោទថែមទៀត។

តាមពាក្យបណ្ដឹងតប ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៣ របស់ឈ្មោះ ងន ដួត និងប្រពន្ធឈ្មោះ ណុច សារឿន បានប្ដឹងពីឈ្មោះ រឿន សុជាតិ ឱ្យចុះចេញពីផ្ទះរបស់ខ្លួន ដោយសំអាងហេតុថា៖

១-ដីភូមិ និងផ្ទះនេះ ជាកម្មសិទ្ធិរបស់ខ្លួន ពុំមានពាក់ព័ន្ធជាមួយឈ្មោះ រឿន សុជាតិ ទេ ព្រោះខ្លួនមានលិខិតបញ្ជាក់ពីកម្មសិទ្ធិរបស់ខ្លួនផ្ទាល់។

២-សុំទាមទារប្រាក់ដែលពាក់ព័ន្ធនឹងឈ្មោះ រឿន សុជាតិ មាន៖ ថ្លៃជួសជុលបន្ទប់សរុបមានចំនួន ៥០០ ដុល្លារអាមេរិក, ថ្លៃព្យាបាលជម្ងឺមុនពេលកូនស្រីរបស់ខ្លួនស្លាប់សរុបចំនួន ២.៥០០.០០០(ពីរលានប្រាំសែន)រៀល, ថ្លៃធ្វើបុណ្យក្រោយពេលស្លាប់សរុបចំនួន ១.៥០០.០០០(មួយលានប្រាំសែន)រៀល, ប្រាក់សុទ្ធចំនួន ៥.០០០.០០០ (ប្រាំលាន)រៀល, ខ្សែកផ្កាទីន ១ខ្សែ ស្មើនឹងទម្ងន់ ២ជី មានក្រោយពីពេលរៀបការរួចហើយ។

៣-ដីស្រែ ២កន្លែង គឺចំណុចត្រាំគ ទំហំ ៦០អា និងចំណុចប្រឡាយតូចទំហំ ៦០អា។

៤-ទូ ១គ្រឿង។

**បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០២ "ខ" ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង សម្រេច:**

១-ទទួលស្គាល់បណ្ដឹងទាមទាររបស់ដើមចោទឈ្មោះ រឿន សុជាតិ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-បង្គាប់ឱ្យចុងចម្លើយឈ្មោះ ណុច សារឿន ប្រគល់ម៉ូតូ ០១គ្រឿង ម៉ាកសេ ១២៥ ស៊េរីឆ្នាំ ២០០៨ និងខ្សែកផ្កាទីន, ចិញ្ចៀន, កងដៃ សរុបទម្ងន់ ៩ជី ២ហ៊ុន ឱ្យទៅឈ្មោះ រឿន សុជាតិ ជាដើមចោទវិញ នៅពេលដែលសាល-

ក្រមចូលជាស្ថាពរ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

៤-សាលក្រមនេះ ធ្វើការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ចំពោះមុខគូភាគី សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

*សាលក្រមនេះ ត្រូវបានឈ្មោះ ណុច សារឿន ប្តឹងឧទ្ធរណ៍ តាមបណ្តឹងលេខ ១២ ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។*

បានឃើញសាលដីការរដ្ឋប្បវេណីលេខ ០៤ ក្រ.IV.សស ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ របស់សាលាឧទ្ធរណ៍ សម្រេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍ របស់ចុងចម្លើយទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ និងគតិច្បាប់ខ្លះ។

២-ទទួលស្គាល់បណ្តឹងតប ចុះថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ ២០១៣ របស់ចុងចម្លើយ ណុច សារឿន និងប្តីឈ្មោះ ដន ដួត ត្រង់ចំណុចទី ១ ការទាមទារឱ្យ រឿន សុជាតិ ចុះចេញពីផ្ទះ និងដីទំនាស់ទុកជាត្រឹមត្រូវតាមច្បាប់។

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០២(ខ) ចុះថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៤ របស់សាលាដំបូងខេត្តព្រៃវែង ត្រង់សេចក្តីសម្រេចចំណុចទី ២ បង្គាប់ឱ្យចុងចម្លើយ ណុច សារឿន ប្រគល់ម៉ូតូ ០១គ្រឿង ម៉ាកសេ ១២៥ ស៊េរីឆ្នាំ ២០០៨ ឱ្យឈ្មោះ រឿន សុជាតិ ជាដើមចោទវិញ។ ចំណុចក្រៅពីនេះ ត្រូវលុបចោល។

៤-បង្គាប់ឱ្យដើមចោទឈ្មោះ រឿន សុជាតិ ចាកចេញពីផ្ទះ និងដីទំនាស់ទំហំ ១៨ម៉ែត្រ គុណ ១១ម៉ែត្រ ផ្ទះទំហំ ៨ម៉ែត្រ គុណ ៨,៤ម៉ែត្រ ឈើលើ ថ្មក្រោម ស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង និងឱ្យចុងចម្លើយឈ្មោះ ណុច សារឿន ប្រគល់ប្រាក់ចំនួន ១.០០០ដុល្លារអាមេរិក ឱ្យទៅដើមចោទឈ្មោះ រឿន សុជាតិ វិញ។

៥-សាលដីកានេះ បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសជាសាធារណៈ នាថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ បើកផ្លូវប្តឹងសាទុក្ខក្នុងរយៈពេល ០១ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

*សាលដីកានេះត្រូវបានឈ្មោះ រឿន សុជាតិ ប្តឹងសាទុក្ខតាមបណ្តឹងលេខ ១៦៣ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤ ត្រង់ចំណុច នៃសេចក្តីសម្រេចទាំងមូល។*

**ខ-<u>អំពីសេចក្តីថ្លែងការណ៍របស់គូភាគី:</u>**

ឈ្មោះ រឿន សុជាតិ ធ្វើសេចក្តីថ្លែងការណ៍ថា: ផ្ទះ និងដីនេះ ខ្លួនទិញពីបងថ្លៃឈ្មោះ ដួត សារុធ តែគ្មានលិខិតស្នាមទេ ព្រោះម៉ែក្មេកថា បងប្អូនឯងមិនបាច់ធ្វើទេ។ ខាងចុងចម្លើយក៏គ្មានលិខិតស្នាមដែរ។ ខ្លួនសុំទាមទារគ្រប់គ្រងផ្ទះ និងដីនេះ ព្រោះក្នុងការទិញលក់នេះ មានអ្នកស្រុក អ្នកភូមិដឹងឮថា ខ្លួនពិតជាទិញផ្ទះនេះមែន។ ខ្លួនបានឱ្យលុយទៅបងថ្លៃគ្រប់ចំនួនហើយ។

ចំពោះម៉ូតូ សេ ១២៥ និងមាសទម្ងន់ ៩,២ជី ខ្លួនទិញពីរនាក់ប្តីប្រពន្ធ ក្រោយពេលរៀបការ។ ថ្លៃព្យាបាលជម្ងឺ និងសោហ៊ុយធ្វើបុណ្យសពខ្លួនជាអ្នកចេញ។ ពេលប្រពន្ធខ្លួនស្លាប់ ម៉ែក្មេកខ្លួនខ្ចី ហើយយកទុករហូតតែម្តង។

ឈ្មោះ ណុច សារឿន ធ្វើសេចក្តីថ្លែងការណ៍ថា: ផ្ទះនេះខ្លួនឱ្យកូនរស់នៅបណ្តោះអាសន្នពេលកូនខ្លួននៅ

រស់ ពេលនេះ កូនខ្លួនស្លាប់ហើយ ខ្លួនសុំទាមទារយកផ្ទះខ្លួនវិញ។ ចំពោះយ៉ាបផ្ទះ ខ្លួនឱ្យដើមចោទរុះយកវិញចុះ។ ផ្ទះនេះតម្លៃ ១២.០០០ដុល្លារ ឱ្យខ្លួនបានតែ ១.០០០ដុល្លារ នៅសល់ ១១.០០០ដុល្លារ មិនទាន់ឱ្យទេ។ តាំងពីដើម មក ទល់ពេលនេះ ម្តាយខ្លួនរស់នៅខាងលើរហូត។ ចំពោះម៉ូតូខ្លួនជាអ្នកទិញឱ្យកូនជិះទៅរៀនដេរមុនរៀបការ ក្រោយរៀបការហើយ ខ្លួនឱ្យប្រាក់ដើមចោទ ១០ម៉ឺន និងអត្តសញ្ញាណប័ណ្ណ យកទៅធ្វើស្លាកលេខ តែដើមចោទធ្វើដាក់ឈ្មោះខ្លួនឯងទៅវិញ។ ថ្លៃពេទ្យ និងថ្លៃធ្វើបុណ្យសព ខ្លួនចេញទាំងអស់។

លោកស្រី ពីង ធីតា មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ រឿន សុជាតិ ធ្វើសេចក្តីថ្លែងការណ៍ថាៈ កូនក្តីខ្លួនរៀបការជាមួយកូនចុងចម្លើយក្នុងឆ្នាំ ២០១០ មានកូនប្រុសអាយុ ៣ឆ្នាំ ដោយមានមុខរបរទាំងពីរនាក់ ទើបសន្សំលុយទិញផ្ទះ និងដីពីបងថ្លៃឈ្មោះ ដួត សាវុធ តម្លៃ ១១.០០០ដុល្លារ ដោយបានប្រគល់ប្រាក់ឱ្យគ្រប់ចំនួន។ ឈ្មោះ ដួត សាវុធ បានប្រាក់នេះ យកទៅទិញដីកន្លែងផ្សេងទៀតរួចហើយ។ ម៉ូតូ កូនក្តីខ្លួនទិញតម្លៃ ១.៤៧០ដុល្លារ និងគ្រឿងអលង្ការ គឺជាទ្រព្យទិញរួមគ្នាជាមួយប្រពន្ធក្នុងចំណងអាពាហ៍ពិពាហ៍។

អង្គហេតុ ពិតជាមានការទិញលក់ពិតប្រាកដមែន ចុងចម្លើយក៏បានឆ្លើយថា បានទទួលប្រាក់ ១.០០០ដុល្លារពីដើមចោទដែរ។ ឯ ដួត សាវុធ បើពុំបានលុយពីការលក់ផ្ទះ និងដីនេះទេ ក៏ពុំមានលុយទិញដីនៅកន្លែងផ្សេងដែរ។ មានសាក្សីជាអនុភូមិ សមាជិកក្រុមប្រឹក្សាឃុំ បញ្ជាក់ថា កូនក្តីខ្លួនពិតជាបានទិញផ្ទះពីឈ្មោះ ដួត សាវុធ ពិតប្រាកដមែន។ ឯកសារកាន់កាប់របស់ចុងចម្លើយមានភាពមិនប្រក្រតី ហើយលិខិតកាន់កាប់នេះ មានអ្នកកាន់កាប់ដល់ទៅ ៤នាក់ ក្នុងនោះមានឈ្មោះ ដួត សាវុធ ដែរ ដែលស្របទៅនឹងចម្លើយដើមចោទថា បានទិញផ្ទះនេះពីឈ្មោះ ដួត សាវុធ។ ចំពោះគ្រឿងអលង្ការ គឺបានទិញក្នុងចំណងអាពាហ៍ពិពាហ៍ ឯម៉ូតូ គឺមានលិខិតទិញពីក្រុមហ៊ុនរបស់កូនក្តីខ្លួន។ កូនក្តីខ្លួនពុំបានប្រឌិតអង្គហេតុទេ។

សំណូមពរៈ សុំបដិសេធសាលដីកាសាលាឧទ្ធរណ៍ទាំងមូល។

លោក តាន់ ម៉េងស្រ៊ុយ មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ ណុច សាវឿន ធ្វើសេចក្តីថ្លែងការណ៍ថាៈ ពេលផ្សះផ្សានៅឃុំ ដើមចោទឆ្លើយថា បានប្រគល់ប្រាក់ ៨ពាន់ដុល្លារ តែនាសវនាការនេះឆ្លើយថា បានប្រគល់ឱ្យគ្រប់ចំនួន។ តាំងពីតុលាការថ្នាក់ក្រោមមក ទើបតែនៅសវនាការតុលាការកំពូលនេះទេ ដែលដើមចោទឆ្លើយថា បានចេញថ្លៃព្យាបាល និងធ្វើបុណ្យសព។ ឈ្មោះ ដួត សាវុធ បានឆ្លើយបដិសេធថា ពុំបានលក់ផ្ទះឱ្យដើមចោទទេ ព្រោះជាដីម្តាយ។ បើដើមចោទទទួលស្គាល់ថា គ្រឿងអលង្ការជាទ្រព្យរួម គឺមិនអាចទាមទារបានទេ ព្រោះម្តាយលក់យកប្រាក់ព្យាបាលជម្ងឺ និងធ្វើបុណ្យសពប្រពន្ធខ្លួនអស់ហើយ។

សំណូមពរៈ សុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកជាបានការ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមទទួលបញ្ជា

-ក្រោយពីបានស្តាប់យោបល់របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់គូភាគី និងមេធាវីតំណាងដោយអាណត្តិរបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

១-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ១៦៣ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤ របស់ឈ្មោះ **វឿន សុជាតិ** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបានតាមមាត្រា ៦៥ នៃច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ និងមាត្រា ២៨៣ មាត្រា ២៨៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

២-យល់ឃើញថា ដើមបណ្ដឹងសាទុក្ខបានអះអាងថា ដី និងផ្ទះ ដែលស្ថិតនៅភូមិមេលប់ ឃុំរកា ស្រុកពារាំង ខេត្តព្រៃវែង គឺខ្លួន និងប្រពន្ធបានទិញពីឈ្មោះ ដួត សាវុធ និងបានប្រគល់ប្រាក់ថ្លៃទិញចំនួន ១១.០០០ដុល្លារអាមេរិក គ្រប់ចំនួនរួចហើយ ទើបខ្លួន និងប្រពន្ធមានសិទ្ធិចូលទៅរស់នៅក្នុងផ្ទះនោះ និងសាងសង់បន្ទប់ តយ៉ាក ក៏ប៉ុន្តែពុំមានឯកសារណាមួយបញ្ជាក់អំពីការលក់ទិញ និងការប្រគល់ប្រាក់គ្រប់ចំនួនទេ។ម្យ៉ាងទៀត ការដែលដើម-ចោទ និងប្រពន្ធបានចូលទៅនៅក្នុងផ្ទះនោះ ដោយសារ ប្រពន្ធរបស់ដើមចោទជាកូនស្រីបង្កើតរបស់ចុងចម្លើយ ហើយចុងចម្លើយប្រគល់ផ្ទះនោះឱ្យកូនស្នាក់នៅបណ្ដោះអាសន្ន ។ លើសពីនេះទៀត ពុំមានឯកសារណាមួយដែលបញ្ជាក់ថា ដី និងផ្ទះទំនាស់ជាកម្មសិទ្ធិរបស់ឈ្មោះ ដួត សាវុធ ទេ ពីព្រោះ តាមលិខិតផ្ទេរសិទ្ធិដី ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០០៥ បង្ហាញថា ឈ្មោះ រឹម នាង បានលក់ដីទំនាស់ទៅឱ្យឈ្មោះ ដួត សាវឿន ពុំមែនលក់ទៅឱ្យ ដួត សាវុធ ទេ។ ហើយការអះអាងរបស់តំណាងដោយអាណត្តិដើមចោទថា លិខិតបញ្ជាក់កម្មសិទ្ធិ មានឈ្មោះ ដួត សាវុធ ជាម្ចាស់កម្មសិទ្ធិដែរនោះ ជាការមិនត្រឹមត្រូវទេ ពីព្រោះ តាមខ្លឹមសារនៃលិខិតនោះ បង្ហាញជាក់ច្បាស់ថា ដីទំនាស់ជាកម្មសិទ្ធិរបស់ចុងចម្លើយតែប៉ុណ្ណោះ។

៣-យល់ឃើញថា ចុងចម្លើយបានទទួលស្គាល់ថា ខ្លួនព្រមលក់ផ្ទះឱ្យកូនស្រីខ្លួនក្នុងតម្លៃ ១២.០០០ដុល្លារអាមេរិក ហើយកូនបានឱ្យប្រាក់ចំនួន ១.០០០ដុល្លារអាមេរិក នៅខ្វះចំនួន ១១.០០០ដុល្លារអាមេរិកទៀត ពេលនេះកូនខ្លួនស្លាប់ហើយ ដូចនេះ ខ្លួនឈប់លក់វិញហើយ ក្នុងករណីនេះ ចុងចម្លើយដែលជាអ្នកលក់ក៏មានសិទ្ធិក្នុងការរំលាយកិច្ចសន្យាចោលវិញដែរ ដោយសង ២ដងនៃប្រាក់កក់ទៅឱ្យអ្នកទិញវិញ យោងតាមមាត្រា ៥១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ប៉ុន្តែ ដោយសារអង្គហេតុនេះ ចូលជាស្ពាពរហើយ តុលាការកំពូលអាចសម្រេចបានដោយមិនបង្វិល តាមមាត្រា ៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤-យល់ឃើញថា នាពេលសវនាការតុលាការកំពូល ដើមចោទបានអះអាងថា ខ្លួនជាអ្នកចេញលុយព្យាបាលជម្ងឺ ចំណាយក្នុងការធ្វើបុណ្យសពប្រពន្ធខ្លួន ចំណុចនេះ ជាអង្គហេតុថ្មីមួយដែលដើមចោទទើបលើកឡើងនៅពេលនេះ ដូចនេះ តុលាការកំពូលពុំលើកយកមកពិចារណាទេ។ ផ្ទុយទៅវិញ ការដែលសាលាឧទ្ធរណ៍សម្រេចលប់ចោលការប្រគល់គ្រឿងអលង្ការទៅឱ្យដើមចោទនោះ ជាការត្រឹមត្រូវហើយ ពីព្រោះ ដើមចោទទទួលស្គាល់ថា នៅពេលប្រពន្ធខ្លួនឈឺ ចុងចម្លើយជាអ្នកដឹកយកទៅមន្ទីរពេទ្យ ដូចនេះ អាចជឿបានថា ចុងចម្លើយជាអ្នកមើលថែជម្ងឺ រហូតដល់បុណ្យសពកូនទៀត ផ្ទុយទៅវិញ ការដែលដើមចោទអះអាងថា ខ្លួនជាអ្នកមើលថែប្រពន្ធ និងចំណាយក្នុងការធ្វើបុណ្យសពនោះ ពុំមានអ្វីមកបញ្ជាក់ទេ។

៥-យល់ឃើញថា ចំពោះម៉ូតូមួយគ្រឿងម៉ាកសេ ១២៥ ស៊េរីឆ្នាំ ២០០៨ ដែលដើមចោទបានទាមទារ និងសំយ៉ាបដែលដើមចោទបានអះអាងថា ខ្លួនជាអ្នកធ្វើនោះ ចុងចម្លើយយល់ព្រមប្រគល់ឱ្យទៅដើមចោទវិញ ដូចនេះ គប្បីសម្រេចតាមគោលការណ៍នៃសិទ្ធិចាត់ចែងរបស់គូភាគី។

៦-យល់ឃើញថា ការសម្រេចសេចក្ដីរបស់សាលាឧទ្ធរណ៍ តាមសាលដីកាលេខ ០៤ក្រIV "សស" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ ត្រឹមត្រូវខ្លះ ខុសខ្លះ។

៧-យល់ឃើញថា តាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

## សេចក្ដីសម្រេចបញ្ចប់

១-ច្រានចោលផ្នែកខ្លះ នៃបណ្ដឹងសាទុក្ខលេខ ១៦៣ ចុះថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០១៤ របស់ឈ្មោះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ០៤ក្រIV "សស" ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤ របស់សាលាឧទ្ធរណ៍ លើកលែងតែចំណុច បង្គាប់ឱ្យចុងចម្លើយប្រគល់ប្រាក់ចំនួន ១.០០០(មួយពាន់)ដុល្លារអាមេរិក ទៅឱ្យដើមចោទ ត្រូវកែប្រែមកជា ឱ្យឈ្មោះ ប្រគល់ប្រាក់ចំនួន ២.០០០(ពីរពាន់)ដុល្លារអាមេរិក ទៅឱ្យដើមចោទឈ្មោះ វិញ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយឈ្មោះ ។

៤-សាលដីកានេះ បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៥ និងប្រកាសនាពេលសវនាការជាសាធារណៈនៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ។

| | |
|---|---|
| ឯកឧត្ដម | ប្រធាន |
| លោក | ចៅក្រម |
| លោក | ចៅក្រម |
| លោក | ចៅក្រម |
| លោកស្រី | ចៅក្រម |
| លោក | ក្រឡាបញ្ជី |

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០១៥
ក្រឡាបញ្ជី

បានឃើញ
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

(មានរូបមន្តអនុវត្តនៅខាងក្រោយ)

ឧបសម្ព័ន្ធទី២១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខ :

## ប្រធានតុលាការកំពូល
## ជម្រាបមក
## លោក លោកស្រី ក្រឡាបញ្ជីតុលាការកំពូល

**កម្មវត្ថុ:** សេចក្តីណែនាំស្តីពីការបញ្ជាក់ការចូលជាស្ថាពរនៃសាលដីការដ្ឋប្បវេណី និងការផ្តល់រូបមន្តអនុវត្ត

**យោង:** មាត្រា ១៩៥ មាត្រា ៣៥៤ និងមាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

កន្លងមក តុលាការកំពូលកត់សម្គាល់ឃើញថា ក្រោយពេលក្រឡាបញ្ជីចេញរូបមន្តអនុវត្តជាលិខិតមួយដាច់ដោយឡែកពីសាលដីកាស្ថាពរ ភាគីចាញ់ក្តីភាគច្រើនបានដាក់ពាក្យប្តឹងតវ៉ាចំពោះរូបមន្តអនុវត្តនោះក្នុងចេតនា រារាំងដល់ការអនុវត្តសាលដីកាស្ថាពរប្រកបដោយប្រសិទ្ធិភាព ធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ និងជំនឿទុកចិត្តលើប្រព័ន្ធតុលាការ។

ដើម្បីពង្រឹងប្រសិទ្ធិភាពនៃការអនុវត្តច្បាប់ និងជំនឿទុកចិត្តលើប្រព័ន្ធតុលាការក្នុងការអនុវត្តសាលដីកាស្ថាពរឱ្យបានសម្រេច ខ្ញុំសូមធ្វើការណែនាំ លោក លោកស្រីក្រឡាបញ្ជី ដូចតទៅ៖

នៅក្នុងសាលដីកាស្ថាពរ ក្រឡាបញ្ជីទទួលបន្ទុកសំណុំរឿងត្រូវសរសេរនៅផ្នែកខាងក្រោមនៃសាលដីកាចម្លងយថាភូត(អក្សរ khmer Kep 12 និង Khmer OS Muol 12)ដូចខាងក្រោម៖

> "យើង..................ក្រឡាបញ្ជីតុលាការកំពូល បញ្ជាក់ថា សាលដីកានេះបានចូលជាស្ថាពរ និងមានអានុភាពអនុវត្ត ចាប់ពីថ្ងៃទី..........ខែ..........ឆ្នាំ.........។"
>
> **"សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលដីកាឱ្យសម្រេចតាមសាលដីកានេះ និងឱ្យអាជ្ញាធរគ្រប់តំណែងគ្រប់ថ្នាក់ ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។"**
>
> ថ្ងៃ........ ខែ..... ឆ្នាំ..... ទោស័ក ព.ស.......
>
> រាជធានីភ្នំពេញ ថ្ងៃទី.... ខែ.... ឆ្នាំ .......
>
> **ក្រឡាបញ្ជី**

(យកកាលបរិច្ឆេទប្រកាសសាលដីកា) (សូមមើលគំរូភ្ជាប់នេះ)។

សេចក្តីបញ្ជាក់នេះ គឺជាការបញ្ជាក់អំពីការចូលជាស្ថាពរនៃសាលដីកា និងការផ្តល់រូបមន្តអនុវត្ត ដែលត្រូវចេញឲ្យភាគីនៃរឿងក្តីទាំងអស់ដែលបានដាក់ពាក្យស្នើសុំ ស្របតាមមាត្រា ៣៥៤ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ថ្ងៃពុធ ១២កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ២០២០

**ប្រធានតុលាការកំពូល**